**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីស៊ើបអង្កេត និងការស៊ើបសួររឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងខេត្តកំពត

ស្រាវជ្រាវ ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឌិន ឡាយអ៊ី**

លោក **ខេង សុខលីណា**

សាស្ត្រាចារ្យណែនាំ

លោក **ហេង ម៉ូរ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឋិន ឡាយអ៊ី** និងខ្ញុំបាទ **ខេង សុខលីណា** ជានិស្សិតផ្នែកនីតិសាស្ត្រ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៥-២០១៩ ជំនាន់ទី១៩។

សូមសម្តែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ

| | |
|---|---|
| **លោកឪពុក សំ ឿន** | **អ្នកម្តាយ ឈន មុំ** |
| **លោកឪពុក កុយ ខេង** | **អ្នកម្តាយ អ៊ុក សុគន្ធ** |

ដែលបានផ្តល់កំណើតដល់រូបខ្ញុំបាទ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានឧបត្ថម្ភគ្រប់បែបយ៉ាងតាំងពីតូចរហូតដល់ធំ គាត់បានលះបង់កម្លាំងកាយ កម្លាំងចិត្តដោយមិនគិតពីការនឿយហត់ ជាពិសេស លោកបានផ្តល់កម្លាំងចិត្ត និងការអប់រំ ទូន្មាន ប្រៀនប្រដៅ ប្រកបដោយគុណធម៌ដើម្បីឱ្យកូនបានរៀនសូត្ររហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងក្លាយទៅជាមនុស្សល្អ ជាមនុស្សដែលសង្គម និងប្រទេសជាតិត្រូវការ ។

ឯកឧត្តម **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រី សាស្ត្រាចារ្យ** ដែលបានផ្តល់នូវការអប់រំ ទាំងចំណេះដឹង សីលធម៌ និងដំបូន្មានល្អៗ ព្រមទាំងជួយពន្យល់ណែនាំ បង្ហាត់បង្រៀន ដល់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់បំផុត រហូតដល់យើងខ្ញុំឆ្លងកាត់បញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

លោក សាស្ត្រាចារ្យ **ហេង ម៉ូរ៉ា** ដែលជាសាស្ត្រាចារ្យណែនាំ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ពន្យល់ និងកែលម្អនូវចំណុចខ្វះខាតនៃសារណានេះ តាំងពីដើមរហូតដល់យើងខ្ញុំបាទទទួលបាននូវលទ្ធផលជាស្ថាពរ ។

លោក **ឡុង កេសតីរម្យ** ប្រធានតុលាការសាលាដំបូង ឯកឧត្តម **ឯក ឆេងហួត** ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពត លោក **ម៉ាន់ មូរ៉េត** ប្រធានលេខាធិការដ្ឋាន ដែលបានផ្តល់ឱកាសអនុញ្ញាតដល់យើងខ្ញុំក្នុងការស្រាវជ្រាវ និងផ្តល់ឯកសារក្នុងការសរសេរសារណារបស់យើងខ្ញុំ។

លោកស្រី **ជា ដាវី** គណៈប្រតិភូមេធាវី ប្រចាំខេត្តកំពត ដែលបានដឹកនាំចុះស្រាវជ្រាវឯកសារនៅសាលាដំបូងខេត្តកំពត។

ជាទីបញ្ចប់ ក្រុមយើងខ្ញុំសូមប្រសិទ្ធិពរជ័យ សេរីមង្គល បវរមហាប្រសើរ ជូនចំពោះអ្នកមានគុណទាំងទ្វេ ឯកឧត្តម លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុៈ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សា ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះមនុស្សទូទៅ ហើយមនុស្សនៅជុំវិញពិភពលោក តែងតែប្រាថ្នាចង់បាននូវការសិក្សារៀនសូត្រ ដើម្បីយកទៅប្រើប្រាស់ជាចាំបាច់ក្នុងគោលដៅជួយសង្គមគ្រួសារ និងបុគ្គលផ្ទាល់ខ្លួន។ ជាសក្ខីភាព បានបង្ហាញឱ្យឃើញថា លទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំកន្លងមក ពិតជាទទួលបានផ្លែផ្កាគួរជាទីគាប់ប្រសើរ ដោយបានសរសេរសារណាឆ្ពោះទៅបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៥-២០១៩ ជាមោទនៈភាពដ៏ធំធេងបំផុត ដែលយើងខ្ញុំបានខិតខំប្រឹងប្រែងកន្លងមក ធ្វើឱ្យបានសម្រេចនូវលទ្ធផលយ៉ាងត្រចះត្រចង់ ព្រមទាំងបានហែលឆ្លងនូវឧបសគ្គជាច្រើន ទម្រាំឈានដល់ដំណាក់កាលសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

យ៉ាងណាមិញ លទ្ធផលដែលទទួលបានពីការសិក្សាមួយនេះ ក៏ដោយសារមានការបណ្តុះបណ្តាល អប់រំ ទូន្មាន ប្រៀបប្រដៅ ពីសំណាក់លោកគ្រូ អ្នកគ្រូ លោក-លោកស្រី សាស្ត្រាចារ្យ ដែលជាឃ្លាំងនៃចំណេះដឹង និងជាគ្រូដ៏ឆ្នើមប្រកបដោយព្រហ្មវិហារធម៌ខ្ពង់ខ្ពស់ និងលក្ខណៈសម្បត្តិវិសេសថ្លៃថ្លាបំផុត។

ឆ្លងតាមការរយៈនៃការសិក្សាស្រាវជ្រាវកន្លងមក ក្នុងចំណោមមុខវិជ្ជាជាច្រើន ប៉ុន្តែយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកមុខវិជ្ជាតែមួយ មកសរសេរទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ ទើបយើងខ្ញុំសម្រេចយកប្រធានបទនេះគឺ « **នីតិវិធីស៊ើបអង្កេត និងការស៊ើបសួរនៅសាលាដំបូងខេត្តកំពត** » មកធ្វើការសិក្សាស្រាវជ្រាវ។

ជាមូលហេតុ ដែលយើងខ្ញុំបាទសម្រេចជ្រើសរើសយកប្រធានបទមួយនេះ យកមកសិក្សាស្រាវជ្រាវ និងចងក្រងឡើងដោយយល់ឃើញថានីតិវិធីស៊ើបអង្កេត និងការស៊ើបសួរ ជាដំណាក់កាលសំខាន់បំផុត នៅមុនដំណើការសវនាការ។ ដើម្បីឱ្យការជំនុំជម្រះមានលក្ខណៈងាយស្រួល និងទទួលបានភាពយុត្តិធម៌។ ហើយអ្វីដែលសំខាន់នោះ គឺយើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើប្រធានបទនេះផងដែរ និងទុកជាឯកសារមួយសម្រាប់បំពេញនូវតម្រូវការរបស់និស្សិតជំនាន់ក្រោយៗទៀត ដែលមានបំណងចង់ស្រាវជ្រាវបន្តទៅលើអ្វី ដែលទាក់ទងនឹងប្រធានបទនេះ។

ទោះបីជាមានការខិតខំប្រឹងប្រែង និងភាពហ្មត់ចត់យ៉ាងណាក៏ដោយក៏នៅតែមានចំណុចខ្វះខាតជាយថាហេតុមិនអាចចៀសផុតបាន។ ដូច្នេះ យើងខ្ញុំជានិស្សិតសូមទទួលយកនូវរាល់មតិរិះគន់ទាំងឡាយដោយសេចក្ដីពេញចិត្ត ក្នុងន័យស្ថាបនាដើម្បីឱ្យសមិទ្ធផលដ៏តូចមួយនេះ កាន់តែមានភាពប្រសើរឡើង និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរិះគន់ និងការចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាននូវស្នាដៃមួយនេះ។

ជាកិត្តិយសណាស់ ដែលយើងខ្ញុំបាទបានសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ហើយមានការណែនាំពីសំណាក់លោកសាស្ត្រាចារ្យ **ហេង មូរ៉ា** ដើម្បីដាក់ជូនគណៈកម្មការពិនិត្យ និងវាយតម្លៃលើស្នាដៃនៃកិច្ចការស្រាវជ្រាវ នៅពេលឡើងធ្វើបទបង្ហាញដើម្បីការពារសារណានេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរចំពោះគណៈកម្មការ លោកសាស្ត្រាចារ្យណែនាំ និងមិត្តនិស្សិតទាំងអស់ សូមឱ្យជួបតែសំណាងល្អ អនុស្សាវរីយ៍ល្អ ផាសុកភាពល្អ ប្រាជ្ញាឈ្លាសវៃ និងជោគជ័យគ្រប់ភារកិច្ច សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុៈ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ ស្ថានភាពទូទៅរបស់សាលាដំបូងខេត្តកំពត** ........ ៣

**ផ្នែកទី១ ប្រវត្តិនៃការកកើតសាលាដំបូងខេត្តកំពត** ........ ៣

**ផ្នែកទី២ សមាសភាព និងតួនាទីភារកិច្ចនៃសាលាដំបូង** ........ ៤

២.១.សមាសភាព ........ ៤

២.២. តួនាទីភារកិច្ចនៃអង្គសវនាការ ........ ៤

២.២.១.ប្រធានសាលាដំបូង ........ ៤

២.២.២.អនុប្រធានសាលាដំបូង ........ ៥

២.២.៣.ចៅក្រម ........ ៥

២.២.៤.ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ........ ៦

២.២.៥.ក្រឡាបញ្ជី ........ ៧

២.៣.លេខាធិការដ្ឋានសាលាដំបូង ........ ៨

២.៣.១.តួនាទីភារកិច្ច ........ ៨

២.៤.ហិរញ្ញវត្ថុ ........ ១៣

២.៥.រចនាសម្ព័ន្ធ ........ ១៤

**ផ្នែកទី៣ ទិន្នន័យសំណុំរឿងពីឆ្នាំ ២០១៨-២០១៩** ........ ១៤

៣.១.ទិន្នន័យសំណុំរឿងឆ្នាំ ២០១៨ ........ ១៥

៣.២.ទិន្នន័យសំណុំរឿងឆ្នាំ ២០១៩ ឆមាសទី១ ........ ១៦

**ជំពូកទី២ នីតិវិធីស៊ើបអង្កេត និងស៊ើបសួរ** ........ ១៨

**ផ្នែកទី១ ការស៊ើបអង្កេត** ........ ១៨

១.១.ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ........ ១៨

១.១.១.លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតជាក់ស្តែង ........ ១៩

១.១.២.ដំណើការស៊ើបអង្កេត ........ ២០

១.១.៣.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ២០

១.១.៣.១.ការឆែកឆេរ ........ ២១

១.១.៣.២.ការចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង..............................២២
១.១.៣.៣.ការបញ្ជាឱ្យចូលខ្លួន និងស្ដាប់ចម្លើយ...................................................២២
១.១.៣.៤.ការឃាត់ខ្លួន.....................................................................................២៣
១.១.៣.៥.ការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនដល់ព្រះរាជអាជ្ញា ..............................២៤
១.១.៤.វិធានពិសេសក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង.......................................២៧
១.២.ការស៊ើបអង្កេតបឋម.......................................................................................២៨
១.២.១.វិធាននៃការស្រាវជ្រាវ ក្នុងករណីបទល្មើសមិនជាក់ស្តែង ................................២៩
១.២.១.១.ការឆែកឆេរ និងចាប់យកវត្ថុតាង............................................................២៩
១.២.១.២.ការបញ្ជាឱ្យចូលខ្លួន និងស្ដាប់ចម្លើយ.................................................... ៣០
១.២.១.៣.ការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន ................................. ៣១
១.២.២.វិធានពិសេសក្នុងការស៊ើបអង្កេតបឋម ......................................................... ៣១
**ផ្នែកទី២ នីតិវិធីនៃការស៊ើបសួរ**.........................................................................៣១
២.១.ការបើកការស៊ើបសួរ...................................................................................... ៣១
២.១.១.បែបបទនៃបណ្ដឹង ................................................................................... ៣១
២.១.១.១.សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ .................................................. ៣១
២.១.១.២.បណ្ដឹងរបស់ជនរងគ្រោះដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ៣២
២.១.២.អានុភាពនៃបណ្ដឹង....................................................................................៣៣
២.១.២.១.កាតព្វកិច្ចស៊ើបសួរ...............................................................................៣៣
២.១.២.២.វិសាលភាពនៃបណ្ដឹង ........................................................................... ៣៤
២.២.ការបិទការស៊ើបសួរ....................................................................................... ៣៦
២.២.១.ការជូនដំណឹងបិទការស៊ើបសួរ .................................................................... ៣៦
២.២.២.ការបិទការស៊ើបសួរតាមបណ្ដឹងរបស់ភាគី........................................................ ៣៨
២.២.៣.ដីកាដំណោះស្រាយ .................................................................................. ៣៨
២.៣.អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ ...................................................................៤១
២.៣.១.ការស្វែងរកជាបឋមនូវជនល្មើស...................................................................៤២
២.៣.១.១.ការចេញដីកា ......................................................................................៤១
២.៣.១.២.ការអនុវត្តដីកា......................................................................................៤៥
២.៣.២.ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ............................................................៤៦

២.៣.២.១.បុគ្គលដែលអាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ................................... ៤៦
២.៣.២.២.ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ........................... ៤៦
២.៣.២.៣.អានុភាពនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ................................... ៤៧
២.៣.៣.ការរក្សាជនត្រូវចោទស្ថិតក្រោមការចាត់ចែងរបស់តុលាការ .......................... ៤៨
២.៣.៣.១.ការឃុំខ្លួនបណ្ដោះអាសន្ន ................................................................ ៤៨
ក-មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ...................................................... ៤៩
ខ-លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន ...................................................... ៤៩
គ-ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........................................................ ៥០
ឃ-អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ...................................................... ៥២
២.៣.៣.២.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ................................................ ៥២
ក-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ........ ៥២
ខ-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមការប្ដឹងសុំរបស់ព្រះអាជ្ញា............ ៥៣
គ-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយជនត្រូវចោទ ........................... ៥៣
២.៣.៣.៣.ការត្រួតពិនិត្យតាមផ្លូវតុលាការ .......................................................... ៥៤
ក-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ....... ៥៥
ខ-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា.......................... ៥៥
គ-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ........................... ៥៥
ឃ-ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ............................ ៥៦
២.៣.៤.អំណាចនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ........................................ ៥៨
២.៣.៤.១.អំណាចរបស់ចៅក្រមស៊ើបសួរ.......................................................... ៥៨
ក-ការសួរចម្លើយជនត្រូវចោទ ..................................................................... ៥៨
ខ-ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ........................................ ៦០
គ-ការសួរតទល់......................................................................................... ៦១
ឃ-ការចុះដល់ទីកន្លែងកើតហេតុ................................................................... ៦១
ង-ការឆែកឆេរ ........................................................................................ ៦១
ច-ការចាប់យកវត្ថុតាង ............................................................................... ៦២
ឆ-កោសល្យវិច័យ..................................................................................... ៦៣
ជ-ការស្ដាប់ទូរស័ព្ទ .................................................................................. ៦៣

២.៣.៤.២.ការផ្ទេរអំណាច ឬដីកាចាត់ឱ្យស៊ើបសួរជំនួស ........................................ ៦៤
២.៣.៤.៣.មោឃភាពកិច្ចស៊ើបសួរ ........................................ ៦៥
ក-អ្នកដែលមានសិទ្ធិសុំមោឃភាពក្នុងកិច្ចនីតិវិធី ........................................ ៦៧
ខ-ភាពដែលមិនអាចទទួលយកបាននៃពាក្យសុំមោឃភាព ........................................ ៦៨
**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ** ........................................ ៦៩
**ផ្នែកទី១ បញ្ហាប្រឈម នៃនីតិវិធីស៊ើបអង្កេត និងការស៊ើបសួរ** ........................................ ៦៩
១.១.បញ្ហាប្រឈមនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................ ៦៩
១.១.១.ការធ្វេសប្រហែសគួបផ្សំនឹងការខ្វះសម្ភារ និងមធ្យោបាយ ........................................ ៦៩
១.១.២.មន្ត្រីនគរបាលយុត្តិធម៌xមានអាណាព្យាបាលពីរ ........................................ ៦៩
១.១.៣.សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ ........................................ ៧០
១.២.បញ្ហាប្រឈមនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ........................................ ៧០
១.២.១.ការធ្វេសប្រហែស និងភាពយឺតយ៉ាវ ........................................ ៧០
១.២.២.ការឃុំខ្លួនបណ្ដោះអាសន្ន ........................................ ៧១
**ផ្នែកទី២ ដំណោះស្រាយ** ........................................ ៧១
២.១.ដំណោះស្រាយផ្នែកស៊ើបអង្កេត ........................................ ៧១
២.១.១.យន្តការបណ្ដុះបណ្ដាលជំនាញ និងច្បាប់ ........................................ ៧១
២.១.២.បែងចែកសមត្ថកិច្ចរវាងមន្ត្រីនគរបាលជាតិ និង មន្ត្រីកងរាជអាវុធហត្ថ ........................................ ៧២
២.១.៣.យន្តការពង្រឹងការអនុវត្តច្បាប់ ........................................ ៧២
២.១.៣.១.ការលុបបំបាត់អំពើពុករលួយ ........................................ ៧២
២.១.៣.២.ការលុបបំបាត់វប្បធម៌អន្តរាគមន៍ ........................................ ៧២
២.១.៣.៣.ការលុបបំបាត់វប្បធម៌និទណ្ឌភាព ........................................ ៧៣
២.២.ដំណោះស្រាយផ្នែកស៊ើបសួរ ........................................ ៧៣
២.២.១.បង្កើតឱ្យមានវគ្គបណ្ដុះបណ្ដាលបច្ចេកទេស ........................................ ៧៣
២.២.២.ការពង្រឹងការអនុវត្តច្បាប់ ........................................ ៧៣
**សេចក្ដីសន្និដ្ឋាន** ........................................ ៧៥
**អនុសាសន៍** ........................................ ៧៨
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជា ជាប្រទេសមួយប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេសឱ្យមានភាពរីកចម្រើន ហើយការអនុវត្តគោលការណ៍ច្បាប់ គឺជាមូលដ្ឋានគ្រឹះនៃការគោរពសិទ្ធិមនុស្ស។ ទន្ទឹងនឹងការរីកចម្រើន និងអភិវឌ្ឍឥតឈប់ឈរលើគ្រប់វិស័យដែលជាកត្តាធ្វើឱ្យមនុស្សមានការប្រកួតប្រជែងដណ្ដើមផលប្រយោជន៍គ្នា ដើម្បីបំពេញនូវសេចក្ដីត្រូវការឥតព្រំដែនយ៉ាងអនាធិបតេយ្យ គ្មានសណ្ដាប់ធ្នាប់ បាត់បង់សាមគ្គី ដែលជាហេតុបណ្ដាលឱ្យសង្គមកើតមាននូវអំពើល្មើសជាច្រើនដូចជា៖ លួច ប្លន់ កាប់សម្លាប់ ការចាប់ជម្រិត គ្រឿងញៀន និងអំពើផ្សេងៗជាច្រើន ដែលបង្កឱ្យមានផលវិបាកដល់សង្គមជាតិ។ ដោយយោងនៅក្នុងន័យនេះហើយដើម្បីទប់ស្កាត់នូវអំពើអសកម្មទាំងនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានតាក់តែងដោយទទួលបានការអនុម័តពីរដ្ឋសភា មានការយល់ព្រមពីព្រឹទ្ធសភា និងមានការឡាយព្រះហត្ថលេខាដោយព្រះមហាក្សត្រ។

នីតិវិធីព្រហ្មទណ្ឌសំដៅដោយផ្ទាល់ដល់រឿងក្ដីព្រហ្មទណ្ឌ ពោលគឺរបៀបរៀបចំដំណើការនៃការប្រព្រឹត្ត ឬប្រតិបត្តិរបស់សង្គមមនុស្សតបទៅនឹងអំពើ ឬភាពរឹករវ សកម្មភាព ដែលច្បាប់បញ្ញត្តិថាជាបទល្មើស។ នីតិវិធីព្រហ្មទណ្ឌ មិនកំណត់ត្រឹមវិធានដែលអនុវត្ត ទៅលើដំណើការនីតិវិធីនូវមុខសាលាជម្រះក្ដីប៉ុណ្ណោះទេ តាមពិតវាជាបណ្ដុំនៃវិធានដែលកំណត់ពីបុគ្គលិក និងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌ ចាប់តាំងពីពេលដែលមានការសង្ស័យពីការប្រព្រឹត្តបទល្មើសរហូតដល់ពេលដែលចារីត្រូវបានកំណត់ដោយអត្តសញ្ញាណ ដោយធ្វើការស៊ើបអង្កេត ស៊ើបសួរ ជំនុំជម្រះផ្តន្ទាទោស និងអនុវត្តទោស។ នីតិវិធីព្រហ្មទណ្ឌមានគោលដៅទាក់ទងទៅនឹងការកំណត់សមត្ថកិច្ច និងការប្រព្រឹត្តទៅនៃយុត្តាធិការព្រហ្មទណ្ឌ ក៏ដូចជាការស៊ើបអង្កេតស្វែងរកជនល្មើស និងវត្ថុតាំង ( **មន្ត្រីនគរបាលយុត្តិធម៌** ) បែបបទនៃការត្រួតពិនិត្យនីតិវិធីនៃការចោទប្រកាន់បទល្មើស ( **អយ្យការ** ) ការស៊ើបសួរស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ( **ចៅក្រមស៊ើបសួរ** ) នីតិវិធីនៃការជំនុំជម្រះ ( **ចៅក្រមជំនុំជម្រះ** ) និងនីតិវិធីនៃសភាស៊ើបសួរ ( **សាលាឧទ្ធរណ៍** ) ដែលហៅថាតុលាការព្រហ្មទណ្ឌ។ នៅដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ គឺជាដំណាក់កាលសំខាន់បំផុត នៅមុនដំណើការសវនាការ ដើម្បីឱ្យការជំនុំជម្រះមានលក្ខណៈងាយស្រួល និងទទួលបានភាពយុត្តិធម៌ ហើយមិនខុសទៅនឹងបញ្ញត្តិច្បាប់ថែមទៀត។ នីតិវិធីនៃការស៊ើបអង្កេត និងស៊ើបសួរ គឺចង់ស្វែងរកការពិតណាមួយ ដើម្បីផ្ដល់យុត្តិធម៌ជូនជនសង្ស័យ ឬជនរងគ្រោះ ឬជនដែលមានការពាក់ព័ន្ធក្នុងរឿងព្រហ្មទណ្ឌដែលបានកើតឡើងតាមរយៈការស្វែងរកភស្តុតាង និងពិរុទ្ធភាពតាមនីតិវិធីច្បាប់។ យោងតាមមូលហេតុ ដែលបានរៀបរាប់ខាងលើ ទើបជម្រុញឱ្យក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវអំពី

ប្រធានបទ « **នីតិវិធីស៊ើបអង្កេត និងការស៊ើបសួររឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូងខេត្តកំពត** » នៅពេលដែលបទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង តើស្ថាប័នណាខ្លះមានសមត្ថកិច្ចស៊ើបអង្កេត និងស៊ើបសួរ មានបញ្ហាប្រឈមយ៉ាងដូចម្ដេច ហើយយើងត្រូវមានដំណោះស្រាយយ៉ាងណាទៅលើបញ្ហាប្រឈមទាំងនោះ?

ការស្រាវជ្រាវនេះមានគោលបំណង ចង់បង្ហាញពីការអនុវត្តនីតិវិធីស៊ើបអង្កេត និងស៊ើបសួរនៅសាលាដំបូងខេត្តកំពត ឆ្លុះបញ្ចាំងអំពីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្ដែង ឬបទល្មើសព្រហ្មទណ្ឌមិនជាក់ស្ដែង គោលបំណងចង់បង្ហាញអំពីតួនាទី សិទ្ធិ អំណាចមន្ត្រីនគរបាលយុត្តិធម៌ ចង់បង្ហាញអំពីតួនាទី ភារកិច្ច ឬសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួក្នុងការស៊ើបសួរពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ នៅពេលដែលព្រះរាជអាជ្ញាគាត់ចោទប្រកាន់មក។ សិក្សាអំពីបញ្ហាប្រឈមរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត និងបញ្ហាប្រឈមរបស់ចៅក្រមស៊ើបសួរ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ហើយចង់បង្ហាញពីដំណោះស្រាយ តើយើងគួរតែមានវិធានការបែបណាដើម្បីដោះស្រាយទៅលើបញ្ហាប្រឈម ដែលមន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរនៅក្នុងការអនុវត្តមុខងារជាក់ស្ដែង? និងដើម្បីទុកឯកសាឱ្យមន្ត្រីអនុវត្តច្បាប់ដូចជាមន្ត្រីនគរបាលយុត្តិធម៌ ឬក៏ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា មន្ត្រីតុលាការ បុគ្គលិកតុលាការ ឬក៏និស្សិតច្បាប់ជំនាន់ក្រោយធ្វើជាមូលដ្ឋានក្នុងការស្រាវជ្រាវបន្តនៅប្រធានបទនេះ។

ដែនកំណត់និងទំហំនៃការស្រាវជ្រាវ វាមានទំហំធំធេងណាស់ដោយហេតុថាយើងជ្រើសរើសសាលាដំបូងខេត្តកំពត ជាទីតាំងនិងការសិក្សាស្រាវជ្រាវឱ្យជាមូលដ្ឋានដូចគម្រូនៃការស្រាវជ្រាវដោយសារតែនៅក្នុងខេត្តកំពតកើតមានបទល្មើសព្រហ្មទណ្ឌច្រើន ហើយវាជាកន្លែងមួយដែលទីប្រជុំដើម្បីឱ្យយើងបានងាយស្រួលក្នុងការប្រមូលឯកសារ ប្រមូលទិន្នន័យពាក់ព័ន្ធ និងបទល្មើសប្រមូលនីតិវិធីទាំងអស់យកមកវិភាគ ហើយពាក់ព័ន្ធទំហំដែនកំណត់យើងធ្វើការសិក្សាស្រាវជ្រាវត្រឹមតែពីឆ្នាំ២០១៨ មកដល់២០១៩ ក្នុង ឆមាសទីមួយ។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងសារណាដែលបែងចែកជា ០៣ជំពូក៖

ជំពូកទី១៖ ស្ថានភាពទូទៅរបស់សាលាដំបូងខេត្តកំពត

ជំពូកទី២៖ នីតិវិធីស៊ើបអង្កេត និងនីតិវិធីនៃការស៊ើបសួរ

ជំពូកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី១ ស្ថានភាពទូទៅរបស់សាលាដំបូងខេត្តកំពត

## ផ្នែកទី១ ប្រវត្តិនៃការកកើតសាលាដំបូងខេត្តកំពត

នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធតុលាការត្រូវបានផ្លាស់ប្តូរជាច្រើនសម័យកាល គឺចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់ឆ្នាំ១៩៨៥ នៅកម្ពុជាមានតុលាការតែមួយថ្នាក់ប៉ុណ្ណោះ គឺតុលាការខេត្ត-ក្រុង ដែលដើរតួនាទីជាតុលាការដំបូងក្នុងការកាត់ក្តី ឬជំនុំជម្រះក្តីលើកទីមួយ និងចុងក្រោយបង្អស់។ មានន័យថាគ្រប់សាលក្រមទាំងអស់ដែលចេញដោយតុលាការនេះ មានប្រសិទ្ធិភាពក្នុងការអនុវត្ត ហើយសាលក្រមទាំងនេះត្រូវមានការត្រួតពិនិត្យពីក្រសួងយុត្តិធម៌ និងសម្រេចចុងក្រោយដោយក្រុមប្រឹក្សារដ្ឋ ប្រសិនបើមានការស្នើសុំរបស់ក្រសួងយុត្តិធម៌ បើរកឃើញថាមានកំហុស។ លុះមកដល់សម័យអ៊ុនតាក់ តុលាការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងឱ្យមានពីរជាន់ បីថ្នាក់ គឺតុលាការជាន់ទាប ដែលមានតុលាការខេត្ត-ក្រុង តុលាការយោធា និងតុលាការជាន់ខ្ពស់ ដែលមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពត បង្កើតឡើងនៅឆ្នាំ១៩៨២ មានទីតាំងស្ថិតនៅភូមិ ០១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត មានសមត្ថកិច្ចជំនុំជម្រះក្តីលើទឹកដីខេត្តកំពត និងក្រុងកែប។ ការដាក់ឱ្យដំណើរការសាលាដំបូងត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ សាលាដំបូងខេត្តកំពតត្រូវបានចែកជា តុលាការជំនាញ ហើយក៏ជាសាលាជម្រះក្តីទូទៅ ដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តី ដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក[1]។

សាលាដំបូងបំពេញតួនាទីរបស់ខ្លួនលើសមត្ថកិច្ចដែនដី ដោយផ្អែកលើគោលការណ៍ឯករាជ្យ មិនចំណុះឱ្យស្ថាប័នណាមួយឡើយ ក្នុងគោលបំណងរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងសង្គម ជាពិសេសមានតួនាទីចម្បងក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់នូវជាតិសាសន៍ សាសនា ពណ៌សម្បុរ ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ភេទ ភាសា ឋានៈសង្គម និន្នាការនយោបាយ ឬស្ថានភាពណាមួយឡើយ។

ប្រធានតុលាការខេត្តកំពតពីឆ្នាំ១៩៨២ ដល់បច្ចុប្បន្នមាន០៤ រូប ៖

- លោក **ហ៊ឹម អ៊ី** (១៩៨២-២០០៥)
- លោក **ហួន ម៉ានី** (២០០៥-២០១០)
- លោក **គាំ ឈាន** (២០១០-២០១៧)
- លោក **ឡុង កេសផិរម្យ** (២០១៧-បច្ចុប្បន្ន)

[1] មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤

ព្រះអាជ្ញាខេត្តកំពតពីឆ្នាំ១៩៨២ ដល់បច្ចុប្បន្នមាន០៣រូបៈ

- ឯកឧត្តម **អ៊ុក គឹមសិទ្ធិ** (១៩៨២-២០០៨)
- លោក **ជុំ សំបាន** (២០០៨-២០១៤)
- ឯកឧត្តម **ឯក ឆេងហួត** (២០១៤-បច្ចុប្បន្ន)

## ផ្នែកទី២ សមាសភាព និងតួនាទីភារកិច្ចនៃសាលាដំបូង

### ២.១.សមាសភាព

**សមាសភាពសាលាដំបូងរួមមាន[2]៖**

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្រ្តីរដ្ឋបាល និងមានមន្រ្តីជំនាញផ្នែកច្បាប់ផ្សេងៗទៀតជាជំនួយការចាំបាច់។

**(នៅអមសាលាដំបូងរាជធានីខេត្តមាន អយ្យការអមសាលាដំបូង)**

**សមាសភាពអយ្យការអមសាលាដំបូងមាន[3]៖**

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្រ្តីរដ្ឋបាល និងមានមន្រ្តីជំនាញផ្នែកច្បាប់ផ្សេងៗទៀតជាជំនួយការចាំបាច់។

### ២.២. តួនាទីភារកិច្ចនៃអង្គសវនាការ

#### ២.២.១.ប្រធានសាលាដំបូង

ប្រធានសាលាដំបូង គឺជាអ្នកមានអំណាចក្នុងការដឹកនាំ គ្រប់គ្រងនូវរាល់វិធានទាំងឡាយសម្រាប់ដំណើការជំនុំជម្រះរបស់សាលាដំបូង។ ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បី[4]៖

---

[2] មាត្រា ១៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤
[3] មាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤
[4] មាត្រា ១៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤

- ចាត់តាំងអនុប្រធានសាលាដំបូងម្នាក់ ឬចៅក្រមណាម្នាក់ឱ្យចាត់ចែងការងារជំនួសខ្លួនក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាដំបូងឱ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗ ដោយផ្អែកតាមជំនាញ ឬបទពិសោធន៍ការងារ។ ក្នុងករណីខ្លះ ឬពុំមានអនុប្រធាន ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមណាម្នាក់ ដែលមានឋានន្តរសក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើន ទើបឱ្យធ្វើជាប្រធានតុលាការជំនាញបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ និងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង ឬផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង
- ប្រធានសាលាដំបូង មានភារកិច្ចត្រួតពិនិត្យសំណុំរឿង កំណត់កាលបរិច្ឆេទបើកសវនាការ និងធ្វើការបែងចែកសំណុំរឿងទៅចៅក្រមទាំងអស់ដែលនៅក្នុងសាលាដំបូង។

### ២.២.២.អនុប្រធានសាលាដំបូង

អនុប្រធានសាលាដំបូង គឺជាអ្នកជួយសម្រួលការងារមួយផ្នែករបស់ប្រធានសាលាដំបូង ដោយស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាន ហើយមានតួនាទី និងភារកិច្ចប្រហាក់ប្រហែលនឹងប្រធានសាលាដំបូងដែរ។

### ២.២.៣.ចៅក្រម

ចៅក្រម គឺជាអ្នកដែលមានសិទ្ធិក្នុងការជំនុំជម្រះក្តី និងមានសិទ្ធិក្នុងការចេញក្តីសម្រេចរបស់តុលាការ។ ចៅក្រមត្រូវបំពេញភារកិច្ចដោយឯករាជ្យដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ ឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[5]។ ចៅក្រមមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងត្រូវគោរពឱ្យបានហ្មត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ ការជម្រះក្តីត្រូវធ្វើឡើងដោយយុត្តិធម៌ក្នុងនាមជាប្រជារាស្រ្តខ្មែរ។ ចៅក្រម ត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍សេរី និងយុត្តិធម៌តាមនីតិវិធីច្បាប់ជាធរមាន មិនទទួលការកៀបសង្កត់ ការគម្រាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីក្នុងរឿងក្តី ឬពី

[5] មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤

បុគ្គលណាមួយឡើយ[6]។ ចៅក្រមត្រូវបានចាត់តាំងឱ្យបំពេញការងារនៅសាលាជម្រះក្តីណាមួយសម្រាប់រយៈ ០៤ឆ្នាំ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចផ្លាស់ប្តូរចៅក្រមឱ្យទៅបំពេញការងារកន្លែងណាមួយផ្សេងទៀតបាន ក្នុងករណីចៅក្រមនោះមានទោសវិន័យថ្នាក់ទី០២ ដូចមានចែងក្នុងមាត្រា៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឬទៅតាមតម្រូវការចាំបាច់ដើម្បីដំណើការល្អនៃយុត្តិធម៌[7]។

### ២.២.៤.ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ[8]។ ព្រះរាជអាជ្ញាមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងត្រូវគោរពឱ្យបានហ្មត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ អង្គការអយ្យការ គឺជាម្ចាស់បណ្តឹងអាជ្ញា ជាស្ថាប័នតំណាងឱ្យរដ្ឋជាស្ថាប័នការពារនូវសិទ្ធិសេរីភាពបុគ្គល ការពារផលប្រយោជន៍ជាសាធារណៈដែលស្ថាប័ននេះមានតួនាទីក្នុងការចោទប្រកាន់ដោយធ្វើឡើងតាមរយៈ ការធ្វើបណ្តឹងអាជ្ញា ចំពោះសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញានេះដែរ គឺមានតែអង្គការអយ្យការតែមួយប៉ុណ្ណោះដែលមានសិទ្ធិ[9]។

ព្រះរាជអាជ្ញា គឺជាអ្នកទទួលបណ្តឹងបរិហារ ឬបណ្តឹងទាមទារពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ត្រូវចាត់វិធានការលើពាក្យបណ្តឹងព្រហ្មទណ្ឌដែលទទួលបានពីបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា ត្រូវចាត់វិធានការលើពាក្យបណ្តឹងព្រហ្មទណ្ឌដែលទទួលបានដោយផ្ទាល់ពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌តាមនីតិវិធី ដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទនៃបទល្មើសព្រមទាំងវត្ថុតាងដែលពាក់ព័ន្ធដើម្បីដាក់បន្ទុក។

ព្រះរាជអាជ្ញា មានសិទ្ធិក្នុងការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំឱ្យតុលាការដាក់ទោសជនជាប់ចោទដោយអនុវត្តតាមច្បាប់ ទាំងនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។

តំណាងអយ្យការត្រូវមានវត្តមាននៅពេលសវនាការរឿងព្រហ្មទណ្ឌជានិច្ច និងធានាការអនុវត្តសេចក្តីសម្រេចរឿងព្រហ្មទណ្ឌ និងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។

[6] មាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤
[7] មាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤
[8] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[9] មាត្រា ១៣ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤

ក្រៅពីសិទ្ធិទាំងអស់ខាងលើ ព្រះរាជអាជ្ញាអាចដឹកនាំ និងសម្របសម្រួលសកម្មភាពបំពេញការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ការអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចទាំងអស់ដែលនីតិវិធីព្រហ្មទណ្ឌ បានទទួលស្គាល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

ព្រះរាជអាជ្ញា អាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ ពិសេសព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ។

ព្រះរាជអាជ្ញាអាចអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយអាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[10]។

ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[11]។

### ២.២.៥.ក្រឡាបញ្ជី

ក្រឡាបញ្ជី គឺជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ដែលមានតួនាទីជំនួយការរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ ក្រឡាបញ្ជីមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងត្រូវគោរពឱ្យបានហ្មត់ចត់នូវក្រមសីលធម៌របស់ខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់តួនាទីចម្បងដល់ក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុស្តាប់ចម្លើយនៅដំណាក់កាលអយ្យការ កំណត់ហេតុស្តាប់ ឬសួរចម្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងជាអ្នកធ្វើកំណត់ហេតុសវនាការនៅដំណាក់កាលជំនុំជម្រះ និងការប្រកាសសាលក្រម។

ក្រឡាបញ្ជី ជាអ្នកកត់ត្រារាល់ព័ត៌មានតាមរយៈការសាកសួរ ឬស្តាប់ចម្លើយរបស់ជនជាប់ចោទ ឬដើមបណ្តឹង ឬសាក្សី ក្នុងកំណត់ហេតុដែលមានការដឹកនាំធ្វើកំណត់ហេតុដោយព្រះរាជអាជ្ញា។ នៅលើកំណត់ហេតុត្រូវមានចុះហត្ថលេខារបស់ក្រឡាបញ្ជីអមតំណាងអយ្យការ។

ក្រឡាបញ្ជី ជាអ្នកអមចៅក្រមស៊ើបសួរជានិច្ច ដើម្បីសម្រួលការងារចៅក្រមស៊ើបសួរ។ ប៉ុន្តែក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបាន

[10] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[11] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ទេ[12]។ ក្រឡាបញ្ជីជាអ្នករក្សាទុកសំណុំរឿងស៊ើបសួរ ដែលចៅក្រមស៊ើបសួររបស់ខ្លួនបានធ្វើចំណាត់ការ។ កាលណាសំណុំរឿងបាត់ ក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវដោយអាចប្រឈមនឹងវិន័យរដ្ឋបាលពីក្រសួងយុត្តិធម៌។ សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន។

សំណុំរឿង និងសំណុំលិខិតដែលបង្ការទុកត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៅមន្ទីរចៅក្រមស៊ើបសួរ ឬនៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានសន្តិសុខគ្រប់គ្រាន់។

គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ[13]។

ក្រឡាបញ្ជី ក៏ជាអ្នកថតសំណុំរឿងឱ្យទៅមេធាវី ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ហើយមេធាវីជាអ្នកបង់សោហ៊ុយថតចម្លង។

ក្រឡាបញ្ជី ជាអ្នកកត់ត្រានូវកំណត់ហេតុសវនាការនូវរាល់សំណួរ-ចម្លើយចាប់តាំងពីពេលសវនាការរហូតដល់បញ្ចប់។ ក្រឡាបញ្ជី ត្រួតពិនិត្យមើលវត្តមានភាគីពាក់ព័ន្ធនៅពេលមុនសវនាការអានកំណត់ហេតុនានា ដើម្បីអាចឱ្យសាធារណៈជនបានដឹងពីអង្គហេតុ។

### ២.៣.លេខាធិការដ្ឋានសាលាដំបូង

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើការងារនេះ។

#### ២.៣.១.តួនាទីភារកិច្ច

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឱ្យសាលាដំបូង និងអយ្យការអមសាលាដំបូងលើការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបំពេញភារកិច្ចមួយចំនួនដូចខាងក្រោម[14]៖

- គ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រាយការណ៍អំពីការងារ បុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា

[12] មាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[13] មាត្រា ១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[14] មាត្រា ៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

• សម្របសម្រួលសកម្មភាពគ្រប់ផ្នែក រវាងសាលាដំបូង និងអយ្យការអមសាលាដំបូងជាមួយនិងក្រសួងយុត្តិធម៌

• ទំនាក់ទំនងការងារសាធារណៈ

• បញ្ជូនសាលក្រម និងសេចក្តីសម្រេចនានារបស់សាលាដំបូង ជូនទៅក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់

• រៀបចំផែនការសកម្មភាព និងផែនការចាំបាច់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ក្រសួងយុត្តិធម៌ និងគោលការណ៍ហិរញ្ញវត្ថុជាធរមាន ហើយត្រូវផ្ញើផែនការទាំងនោះមកក្រសួងយុត្តិធម៌ ដើម្បីប្រមូលផ្តុំដាក់ក្នុងកញ្ចប់ថវិការួម

• អនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត

• អនុវត្តតាមការណែនាំរបស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

• ធ្វើរបាយការណ៍លម្អិត និងដាច់ដោយឡែកពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុជូនក្រសួងយុត្តិធម៌

• លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលាដំបូង អយ្យការសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង។

• រៀបចំ និងបញ្ជូនរបាយការណ៍បុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស ០៩ ខែ និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌

• បំពេញភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងប្រគល់ឱ្យ។

ដើម្បីធានាដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការការងារ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមាន « ***ត្រាផ្លូវការ*** » សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានការិយាល័យចំណុះចំនួន០៤[15](បួន)ដូចខាងក្រោម

- ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- ការិយាល័យកិច្ចការហិរញ្ញវត្ថុ
- ការិយាល័យកិច្ចការតុលាការ
- ការិយាល័យកិច្ចការអយ្យការ។

[15] មាត្រា ៦ នៃអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

ការិយាល័យនីមួយៗនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ការិយាល័យ នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានថ្នាក់កណ្តាលនៃក្រសួងយុត្តិធម៌។

**១-ការិយាល័យកិច្ចរដ្ឋបាល និងបុគ្គលិក ទទួលបន្ទុក ៖**

- ទទួល និងចាត់ចែងឯកសារចេញរបស់សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋារដ្ឋបាលសាលាដំបូង
- គ្រប់គ្រងការងាររដ្ឋបាលទូទៅ និងការងារបុគ្គលិកសាលាដំបូង និងអយ្យការអម សាលាដំបូង
- ទទួលគ្រប់គ្រង ធ្វើចរាចរឯកសាររដ្ឋបាលផ្សេងៗ និងរក្សាប្រព័ន្ធសន្តិសុខឯកសារ
- ទទួល និងចុះបញ្ជីពាក្យបណ្តឹង និងចាត់ចែងបន្តតាមនីតិវិធី
- គ្រប់គ្រងសំណុំរឿងដែលចាត់ការរួច ទិន្នន័យសាលក្រម និងព្រឹត្តិបត្រ
- គណនាកំណត់ចំនួនប្រាក់ពន្ធដាក់ពាក្យសុំ និងប្រាក់ផ្សេងទៀតតាមច្បាប់កំណត់
- តម្កល់ឯកសាររឿងក្តីសំណៅដើម និងថតចម្លងឯកសាររឿងក្តី ជូនអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ដំណើការរដ្ឋបាល និងរដ្ឋបាលនិតីវិធីសំណុំរឿង
- ចាត់ចែង និងសម្របសម្រួលការបញ្ជូនដីកា សាលក្រម ឬលិខិតផ្សេងៗដល់ភាគី និងអ្នកពាក់ព័ន្ធក្នុងរឿងក្តីស្របតាមនីតិវិធី
- សម្របសម្រួល និងទំនាក់ទំនងសេវាបកប្រែ និងសេវាចាំបាច់ផ្សេងៗ
- សម្របសម្រួលការរក្សាជនល្មើស សាក្សី និងអ្នកពាក់ព័ន្ធ
- គ្រប់គ្រង ថែរក្សាវត្ថុតាងដែលមិនទាន់ចូលជាស្ថាពរ និងសម្របសម្រួលចលនាវត្ថុតាងតាមដំណើការរឿងក្តី ក្រោមការទទួលខុសត្រូវរបស់សាលាដំបូង ឬអយ្យការសាលាដំបូងតាមច្បាប់កំណត់
- គ្រប់គ្រងត្រារបស់លេខាធិការដ្ឋានរដ្ឋបាល
- គ្រប់គ្រង រៀបចំការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យទូទៅ
- គ្រប់គ្រង រៀបចំ ទីតាំង អគារ សួនច្បារ អគ្គិសនី ទឹក និងកែលម្អសោភ័ណភាពផ្សេងៗ
- ផ្តល់ព័ត៌មានអំពីនីតិវិធីបឋមនៃសេវាសាធារណៈដល់សាធារណៈជន និងអង្គភាពពាក់ព័ន្ធ
- ស្រាវជ្រាវ និងលើកយោបល់ធ្វើទំនើបកម្មអំពីការផ្តល់សេវាយុត្តិធម៌
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យ
- ប្រមូលផ្តុំព័ត៌មាន ចងក្រងឯកសារ រូបភាព វីដេអូ និងឯកសារសំខាន់ៗសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ប្រសិទ្ធិភាពការងាររបស់អង្គការតុលាការ និងអង្គការអយ្យការ

- ចាត់ចែង សម្របសម្រួល និងសហការបញ្ជូនសាលក្រម សេចក្ដីសម្រេច និងឯកសារផ្សេងៗ ជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- រៀបចំកិច្ចប្រជុំ សន្និបាទ សិក្ខាសាលា កិច្ចការពិធីការ និងពិធីបុណ្យផ្សេងៗ
- គ្រប់គ្រងបុគ្គលិក រៀបចំផែនការ តារាងបៀវត្ស ស្ថិតិបុគ្គលិក ព្រមទាំងរៀបចំសំណុំរឿងលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព
- រៀបចំសំណើជ្រើសរើស ដំឡើងថ្នាក់ និងឋានន្តរសក្តិ ព្រមទាំងរៀបចំសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗ
- ចូលរួមរៀបចំផែនការ ប្រមូលផ្តុំព័ត៌មានគ្រប់គ្រងធនធានមនុស្ស កម្មវិធីការងារទូទៅ និងកម្មវិធីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក
- រៀបចំ និងបូកសរុបរបាយការណ៍របស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

**២-ការិយាល័យកិច្ចការហិរញ្ញវត្ថុ ទទួលបន្ទុក៖**

- គ្រប់គ្រងការងារផែនការ ថវិកា លទ្ធកម្ម បេឡា គណនេយ្យ សារពើភណ្ឌ និងការងារហិរញ្ញវត្ថុ ទាំងឡាយរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ទទួល និងបូកសរុបផែនការសកម្មភាព និងផែនការថវិកាពីគ្រប់ការិយាល័យ និងអង្គភាពនានា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រៀបចំ និងគ្រប់គ្រង ការអនុវត្តថវិកា ដោយមានចុះកិច្ចបញ្ជីការគណនេយ្យ
- រៀបចំបែបបទ សម្របសម្រួល គ្រប់គ្រង និងអនុវត្តលទ្ធកម្មសាធារណៈតាមនីតិវិធី ជាធរមាន
- រៀបចំបែបបទទូទាត់កិច្ចចំណាយដំណើរការរដ្ឋបាលផ្សេងៗ និងចំណាយកិច្ចលទ្ធកម្ម
- គ្រប់គ្រង តាមដាន និងធ្វើបញ្ជីបេឡាជាប្រចាំ
- រៀបចំបើកប្រាក់បៀវត្ស ប្រាក់បេសកកម្ម ប្រាក់ឧបត្ថម្ភផ្សេងៗ និងរៀបចំបែបបទទូទាត់
- គ្រប់គ្រងបញ្ជីសលាកបត្រ និងគណនេយ្យរូបធាតុ
- ទទួល ប្រមូល គ្រប់គ្រង និងចាត់ចែងប្រាក់ពន្ធ ប្រាក់ប្រដាប់ក្តី ប្រាក់ពិន័យ និងប្រាក់ចំណូលផ្សេងទៀត ព្រមទាំងបញ្ចូលសាច់ប្រាក់ តាមបទដ្ឋាគតិយុត្តជាធរមាន និងធ្វើរបាយការណ៍ ជាប្រចាំ
- សម្របសម្រួល ប្រមូលផ្តុំ និងគ្រប់គ្រងរាល់ចំណូល ប្រាក់តម្កល់ ប្រាក់ប្រាតិភោគ ឬប្រាក់ផ្សេងៗទៀតរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង

- គ្រប់គ្រង និងបើកប្រាក់រង្វាន់ ក្រោមការទទួលខុសត្រូវរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង តាមបទដ្ឋានគតិយុត្តជាធរមាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំ គ្រប់គ្រង និងបែងចែកតាមតម្រូវការនូវសម្ភារ បរិក្ខាបច្ចេកទេស ប្រេងឥន្ធនៈ និងតម្រូវការផ្សេងៗ
- សម្របសម្រួល គ្រប់គ្រង និងថែរក្សាវត្ថុតាងដែលមានសាលក្រម ឬសាលដីកាស្ថាពរ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

**៣-ការិយាល័យកិច្ចការតុលាការ ទទួលបន្ទុកៈ**

- ទទួល និងចាត់ចែងបន្តលើសំណុំរឿងទាំងឡាយក្នុងសមត្ថកិច្ចសាលាដំបូង ពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើការនីតិវិធីសំណុំរឿងក្តីរបស់សាលាដំបូង
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធរំលឹក ឬដាស់តឿនអំពីការឃុំខ្លួន
- សម្របសម្រួល រៀបចំកម្មវិធីសវនាការ និងគ្រប់គ្រងកិច្ចការរដ្ឋបាលនីតិវិធីនៃសវនាការដើម្បីធានាកិច្ចដំណើការល្អ
- ទំនាក់ទំនងថៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើការរឿងក្តី
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្តី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- សហការជាមួយផ្នែកព័ត៌មានវិទ្យាសាលាដំបូង ដើម្បីចុះទិន្នន័យសំណុំរឿងបឋម និងស្ថាពរដែលទាក់ទងដល់នីតិវិធីនៃចំណាត់ការរឿងក្តី
- ប្រមូល និងចងក្រងសាលក្រមស្ថាពរ និងរូបមន្តអនុវត្តផ្សេងៗ
- រៀបចំការបញ្ជូនសាលក្រម សេចក្តីព្យាយាម សេចក្តីសម្រេច និងឯកសារផ្សេងៗជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ

- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

**៤-ការិយាល័យកិច្ចអយ្យការ ទទួលបន្ទុក ៖**

- គ្រប់គ្រងនិងចាត់ចែងបន្តលើសំណុំរឿង និងការងារទាំងឡាយក្នុងសមត្ថកិច្ចអយ្យការអមសាលាដំបូងពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីព្រហ្មទណ្ឌ
- រៀបចំការបញ្ជូនសាលក្រមស្ថាពរទៅសាលាជម្រះក្តី និងពន្ធនាគារដែលមានសមត្ថកិច្ច
- សម្របសម្រួលជាមួយចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយ យុត្តិធម៌ អ្នកជំនាញការ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើការរឿងក្តី
- ចូលរួមរក្សា និងតម្កល់រឿងក្តី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- ប្រមូល និងចងក្រងសាលក្រមស្ថាពរក្នុងរឿងព្រហ្មទណ្ឌ
- សម្របសម្រួលរៀបចំកម្មវិធីសវនាការព្រហ្មទណ្ឌ ដើម្បីធានាកិច្ចដំណើការល្អ
- សម្របសម្រួលការថតចម្លងឯកសាររឿងក្តីព្រហ្មទណ្ឌ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិកាដ្ឋានប្រគល់ឱ្យ។

**២.៤.ហិរញ្ញវត្ថុ**

សាលាដំបូង នឹងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។ ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជាអាណាប័កទទួលសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការគ្រប់គ្រងនិងចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ[16]។

[16] មាត្រា ៧៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤

## ២.៥.រចនាសម្ព័ន្ធ


រចនាសម្ព័ន្ធ សាលាដំបូងខេត្តកំពត និងអយ្យការអមសាលាដំបូងខេត្តកំពត
ប្រធានសាលាដំបូង ១.ឡុង គេសតិរម្យ
អនុប្រធាន ២.គីម វ៉ាវី
ចៅក្រម ៣.លី សុជាណែត
៤.អាំង សុភា
៥.យី សុខឌួច
៦.ហុង សុគុណាវឌ្ឍនា
៧.តុប ឈុនសុខ
៨.យន ចាន់ធឿន
៩.ខូច ចាន់ធូ
១០.លាង ឈន
ក្រឡាបញ្ជី
១-សុខ សុគន្ធវ័ត្ត
២-ឈឿន បារាំង
៣-សំរិទ្ធិ សុធារិទ្ធ
៤-នួន សុផុន
៥-កន នៀងសាវ៉ារុធ
៦-អ៊ូ តារាវត្តី
៧-សុខ បូណា
៨-ចាន់ ណារិន
៩-ឃិន សុធី
១០-ហាង់ ចរិយា
១១-ចៅ ឃឹម
១២-ឆាយ ផាន
១៣-ពេជ្រ សារុធ
ប្រធានលេខាធិការដ្ឋាន ម៉ាន់ បូរេត
អនុប្រធានលេខាធិការដ្ឋាន សូត្រ ឆា
ព្រះរាជអាជ្ញា ១-ឯក ឆេងហួត
ព្រះអាជ្ញារង ២-ខាន់ សុផល
៣-ខៃ សម្ផស្ស
៤-ម៉ុត ដារ៉ា
៥-ខា ដែនណា
ក្រឡាបញ្ជី
១-សៃ អូន
២-ផន សុគន្ធា
៣-គង់ វ៉ាវន
៤-គុយ ជិ
៥-សំ ថា
៦-អ៊ំ វិទូ
ការិយាល័យកិច្ចសន្យាហិរញ្ញវត្ថុ
១-ស សៅរឿង (មន្ត្រី)
២-កន កែវមរកត (មន្ត្រី)
៣-សុខ កាន់ណារី (មន្ត្រីកិច្ចសន្យា)
៤-សុខ សុគន្ធវ័ត្ត (មន្ត្រីកិច្ចសន្យា)
ការិយាល័យរដ្ឋបាល &បុគ្គលិក
១-គង់ ឈឿន (ប្រធានការិយាល័យ)
២-សូ គីមលេង (មន្ត្រី)
៣-ង៉ែត សាយ (មន្ត្រីកិច្ចសន្យា)
ការិយាល័យកិច្ចការតុលាការ
១-ពៅ ភារិន (មន្ត្រី)
២-ប៉ែន សត្យា (មន្ត្រី)
៣-ថោ ចិន្តា (មន្ត្រីកិច្ចសន្យា)
៤-សាង ស៊ីខៀវ (មន្ត្រីកិច្ចសន្យា)
៥-ង៉ែត រិន (មន្ត្រីកិច្ចសន្យា)
ការិយាល័យកិច្ចការអយ្យការ
១-ណុប សុផល (ប្រធានការិយាល័យ)
២-សុទ្ធ ឡៃយ៉ាក្វ (មន្ត្រី)
៣-ឫទ្ធី សុភា (មន្ត្រី)
៤-សាយ មករា (មន្ត្រី)
៥-ឈឹម សុភា (មន្ត្រី)
៦-ទន កៅ (មន្ត្រីកិច្ចសន្យា)
៧-ជួន ស៊ីណាត (មន្ត្រីកិច្ចសន្យា)
៨-ចំរើន ធារ័ត្ន (មន្ត្រីកិច្ចសន្យា)

# ផ្នែកទី៣ ទិន្នន័យសំណុំរឿងពីឆ្នាំ ២០១៨-២០១៩

## ៣.១.ទិន្នន័យសំណុំរឿងឆ្នាំ ២០១៨

| ល.រ | ឈ្មោះ ព្រះរាជអាជ្ញា-រង | បន្ទប់ | សំណុំរឿងសល់ពីមុន | សំណុំរឿងចូលថ្មី | សំណុំរឿងចាត់ការរួច | | | | | | រឿងសល់កំពុងចាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | បញ្ជូនសំណុំរឿងទៅស៊ើបសួរ | បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់ | នីតិវិធីបង្ហាញខ្លួនភ្លាម | តម្កល់សំណុំរឿងទុកឥតចាត់ការ | ផ្ទេរសមត្ថកិច្ច | បញ្ជូនរឿង | | |
| **០១** | **០២** | **០៣** | **០៤** | **០៥** | **០៦** | **០៧** | **០៨** | **០៩** | **១០** | **១១** | **១២** | **១៣** |
| ០១ | **លោក ឯក ឆេងហួត** | **ក** | ១០៩ | ២៣៧ | ១៤០ | ៣៥ | ០០ | ១១៣ | ០០ | ០២ | ៥៥ | ស្រូបទោស ១រឿង |
| ០២ | **លោក ខាន់សុផល** | **ខ** | ៣០ | ១៣៥ | ៩៦ | ១៦ | ០០ | ២៤ | ០០ | ០១ | ២៨ | |
| ០៣ | **លោក ជ័យ រិទ្ធី** | **គ** | ១១ | ១៥២ | ៩០ | ១៤ | ០០ | ២១ | ០០ | ០១ | ៣៧ | |
| ០៤ | **លោក ម៉ុត ដារ៉ា** | **ឃ** | ២១ | ១៦៥ | ៩៨ | ១៨ | ០០ | ៣១ | ០០ | ០៣ | ៣៦ | |
| ០៥ | **លោក ខា ដែនណា** | **ង** | ២៨ | ១២៥ | ៨១ | ០៤ | ០០ | ២២ | ០១ | ០២ | ៤៣ | |
| **សរុប** | | | **១៩៩** | **៨១៤** | **៥០៥** | **៨៧** | **០០** | **២១១** | **០១** | **០៩** | **១៩៩** | **០១** |

- សំណុំរឿងសល់ពីមុន ១៩៩
- សំណុំរឿងចូលថ្មី ៨១៤
- សំណុំរឿងសរុប ១០១៤
- បញ្ជូនសំណុំរឿងទៅស៊ើបសួរ ៤៩,៨០%
- បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់ ៨,៥៧%
- នីតិវិធីបង្ហាញខ្លួនភ្លាម ០០%

- តម្កល់សំណុំរឿងទុកឥតចាត់ការ ២០,៨០%
- ផ្ទេរសមត្ថកិច្ច ០,០៩%
- បញ្ជូនរឿង ០,៨៨%
- រឿងសល់កំពុងចាត់ការ ១៩,៦២%
- ស្រូបទោស ០,០៩%

### ៣.២.ទិន្នន័យសំណុំរឿងឆ្នាំ ២០១៩ ឆមាសទី១

| ល.រ | ឈ្មោះ ព្រះរាជអាជ្ញា-រង | បន្ទប់ | សំណុំរឿងសល់ពីមុន | សំណុំរឿងចូលថ្មី | សំណុំរឿងចាត់ការរួច | | | | | | រឿងសល់កំពុងចាត់ការ | **ផ្សេងៗ** |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | បញ្ជូនសំណុំរឿងទៅស៊ើបសួរ | បញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ | នីតិវិធីបង្គាប់បញ្ជូនខ្លួនឯង | តម្កល់សំណុំរឿងទុកឥតចាត់ការ | ផ្ទេរសមត្ថកិច្ច | បញ្ជូនរឿង | | |
| **០១** | **០២** | **០៣** | **០៤** | **០៥** | **០៦** | **០៧** | **០៨** | **០៩** | **១០** | **១១** | **១២** | **១៣** |
| ០១ | **លោក ឯក ឆេងហួត** | **ក** | ៥៥ | ៤៩ | ២៦ | ១២ | ០០ | ១០ | ០០ | ០០ | ៥៥ | ស្រូបទោសសាលក្រមព្រហ្មទណ្ឌ ០១រឿង |
| ០២ | **លោក ខាន់ សុផល** | **ខ** | ២៨ | ៣៦ | ២១ | ០១ | ០០ | ០៣ | ០០ | ០០ | ៣៩ | |
| ០៣ | **លោក ជ័យ រិទ្ធី** | **គ** | ៣៧ | ២២ | ១៨ | ០០ | ០០ | ១០ | ០០ | ០០ | ៣០ | |
| ០៤ | **លោក ម៉ុត ដារ៉ា** | **ឃ** | ៣៦ | ៤៧ | ៣៨ | ០២ | ០០ | ១៧ | ០០ | ០០ | ២៦ | |
| ០៥ | **លោក ខា ដែនណា** | **ខ** | ៤៣ | ៥១ | ២៧ | ០០ | ០០ | ០៥ | ០០ | ០០ | ៦២ | |
| **សរុប** | | | **១៩៩** | **២០៥** | **១៣០** | **១៦** | **០០** | **៤៥** | **០០** | **០០** | **២១២** | **០១** |

- សំណុំរឿងសល់ពីមុន ១៩៩
- សំណុំរឿងចូលថ្មី ២០៥
- សំណុំរឿងសរុប ៤០៥
- បញ្ជូនសំណុំរឿងទៅស៊ើបសួរ ៣២,០៩%
- បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់ ៣,៩៥%
- នីតិវិធីបង្ហាញខ្លួនភ្លាម ០០%
- តម្កល់សំណុំរឿងទុកឥតចាត់ការ ១១,១១%
- ផ្ទេរសមត្ថកិច្ច ០០%
- បញ្ជូនរឿង ០០%
- រឿងសល់កំពុងចាត់ការ ៥២,៣៤%
- ស្រ្សូបទោស ០,២៤% ។

# ជំពូកទី២ នីតិវិធីស៊ើបអង្កេត និងស៊ើបសួរ

## ផ្នែកទី១ ការស៊ើបអង្កេត

រាល់ការស៊ើបអង្កេតដែលធ្វើដោយមន្ត្រីនគបាលយុត្តិធម៌ ត្រូវជាការសម្ងាត់ ( គោលការណ៍សម្ងាត់នៃការស៊ើបអង្កេត )។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបអង្កេតជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ត្រូវរក្សាការសម្ងាត់ខាងវិជ្ជាជីវៈ។ ហើយការបំពានការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[17]។

ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានភាពខុសគ្នានៃអំណាចស៊ើបអង្កេតទៅតាមពេលវេលាដែលមន្ត្រីនគរបាលយុត្តិធម៌ បម្រើការក្នុងក្របខណ្ឌនៃការស៊ើបអង្កេតលើករណីជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមនៃបទល្មើស។

តាមប្រយោគខាងលើនេះ យើងឃើញថាអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌មានភាពខុសគ្នាទៅតាមការស៊ើបអង្កេត ដែលត្រូវបែងចែកជា០២ (ពីរ) ប្រភេទ គឺការស៊ើបអង្កេតក្នុងករណីជាក់ស្តែង និងការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម។

តើអ្វីទៅជាការស៊ើបអង្កេតករណីជាក់ស្តែង? ហើយអ្វីទៅជាការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម?

### ១.១.ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេត គឺជាភាពបន្ទាន់ដែលតម្រូវឱ្យមានការប្រមូលនូវភស្តុតាងនៃបទល្មើសដែលនៅមាននៅឡើយ ដែលវាទើបត្រូវបានប្រព្រឹត្តថ្មីៗ។ ដើម្បីឆ្លើយតបនឹងភាពរហ័សភាពចាំបាច់ នៃកិច្ចស៊ើបអង្កេតទើបក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ បានបង្កើតនូវវិធានដែលរហ័ស និងបង្កើតអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌។

ការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាដំណាក់កាលដែលពុំអាចឱ្យពេលវេលាណាមួយត្រូវបានបាត់បង់ឡើយ។ ការយឺតយ៉ាវតែបន្តិចបន្តួចអាចជាមូលហេតុនៃការបាត់បង់តម្រុយនៃពិរុទ្ធភាព ឬពិរុទ្ធជន និងស្លាកស្នាមនៃបទល្មើស។ ហេតុនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ បានផ្តល់ឱ្យកម្លាំងសាធារណៈដែលត្រូវប្រឈមនឹងបទល្មើសដែលទើបតែកើតឡើងភ្លាមៗ នូវមធ្យោបាយ

[17] មាត្រា ៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ដ៏មានប្រសិទ្ធភាពមួយដើម្បីឆ្លើយតបនឹងល្បឿននៃការបាត់បង់នូវតម្រុយភស្តុតាង និងការរត់គេចខ្លួនរបស់ជនប្រព្រឹត្តបទល្មើស ឬអ្នកចូលរួមប្រព្រឹត្តបទល្មើស។

**១.១.១.លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតជាក់ស្តែង**

យោងតាមបញ្ញត្តិមាត្រា៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ បានចែងថា ៖

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពតាមបទបញ្ញត្តិនៃមាតិកានេះ។

មានន័យថា នៅចំពោះស្ថានភាពជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពនូវលក្ខខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងក្នុងករណីដែលមានបទល្មើស ប្រព្រឹត្តជាប្រភេទបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។

តើអ្វីដែលទៅជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង?

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គឺជាបទល្មើសដែលកំពុងប្រព្រឹត្ត ឬទើបប្រព្រឹត្តរួចភ្លាម។

ក្នុងនោះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់និយមន័យបទល្មើសដែលត្រូវចាត់ទុកថាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមកជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬ ស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស[18]។

ត្រូវចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណាបទល្មើសដែលត្រូវបានប្រព្រឹត្តនោះនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ។ ហើយភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ [19]។

[18] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[19] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីដែលមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត[20]។

### ១.១.២.ដំណើរការស៊ើបអង្កេត

ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

ចិរវេលានៃការស៊ើបអង្កេតនៃបទល្មើសជាក់ស្តែង មិនអាចលើសពី ០៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងចិរវេលានេះ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា[21] ។

បញ្ញត្តិនៃមាត្រា១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាផ្នែកមួយនៃវិធាន និងទម្រង់ដែលបានចែងនឹងនាំឱ្យមានមោឃភាពក្នុងករណីមិនគោរព (មាត្រា១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងអំឡុងពេលស៊ើបអង្កេត គ្រប់កិច្ចទាំងអស់ត្រូវកត់ត្រានៅនឹងកន្លែងកើតហេតុ ដោយមន្ត្រីនគរបាលយុត្តិធម៌ដែលដឹកនាំការស៊ើបអង្កេតនេះ។

ឧទាហរណ៍៖ កំណត់ហេតុឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុស្តីពីការចាប់យកវត្ថុតាង កំណត់ហេតុស្តីពីការឆែកឆេរ កំណត់ហេតុស្តីពីការពិនិត្យកន្លែងកើតហេតុជាដើម។

### ១.១.៣.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រង រក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើសរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។

ប្រសិនបើយល់ឃើញថា មានប្រយោជន៍ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត។

[20] មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[21] មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ[22]។

**១.១.៣.១.ការឆែកឆេរ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយបានទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនោះធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរក្តី ការឆែកឆេរនេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែងបើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

ចំពោះការឆែកឆេរនេះ មន្ត្រីនគរបាលយុត្តិធម៌មិនផ្តើមការឆែកឆេរនៅមុនម៉ោង០៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាចឡើយ។ តែចំពោះករណីដែលមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ឬក្នុងករណីដែលចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយពុំចាំបាច់អនុលោមតាមលក្ខខណ្ឌខាងលើនេះទេ។ ក្រៅពីនេះក្នុងករណីដែលមានសម្រែកស្រែកឱ្យគេជួយពីក្នុងកន្លែង ក្នុងករណី ដែលពេលម៉ោងបើកចំហដល់សាធារណៈជន ក្នុងករណីដែលកន្លែងនោះជាកន្លែងដែលផលិតរក្សាទុក ជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន មន្ត្រីនគរបាលអាចធ្វើការឆែកឆេរដោយពុំចាំបាច់គោរពពេលខាងលើនេះឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបាននោះទេ ការឆែកឆេរនេះ អាចត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដោយធ្វើឡើងនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

ក្រៅពីការហាមឃាត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏មិនអាចធ្វើការឆែកឆេរបានផងដែរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសព័ត៌មានសោទស្សន៍ គឺអាចធ្វើទៅបាននៅចំពោះមុខនៃព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែម្នាក់ប៉ុណ្ណោះ។ ហើយព្រះរាជ-អាជ្ញា ឬចៅក្រមស៊ើបសួរត្រូវធានាដល់ការឆែកឆេរ មិនត្រូវឱ្យប៉ះពាល់ដល់ការប្រកបមុខរបរដោយ

[22] មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

សេរីនៃរបបអ្នកសារព័ត៌មាន និងមិនត្រូវធ្វើឱ្យមានការយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះឡើយ [23]។

**១.១.៣.២.ការចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង**

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់យក ( វត្ថុតាង ) នោះ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួច ធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ[24]។

**១.១.៣.៣.ការបញ្ជាឱ្យចូលខ្លួន និងស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស។ ការស្តាប់ចម្លើយ ( សួរយកចម្លើយ ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីដែលជនត្រូវបាន ស្តាប់ចម្លើយជាជនបរទេសគថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីបានស្តាប់ចម្លើយរួចហើយ ត្រូវអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ ( និងអ្នកបកប្រែបើមាន ) ហើយឱ្យចុះហត្ថលេខា ឬផ្តិតខ្មៅដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណីដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតស្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវ ចុះនិទ្ទេសនៅក្នុងកំណត់ហេតុអំពីហេតុការណ៍នេះ។

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនិងការកោះហៅនេះមន្ត្រីនគរបាលអាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឱ្យចេញដីកាបញ្ជាឱ្យចូលខ្លួន ដែលដីកានេះអនុញ្ញាឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួនបាន[25]។

[23] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[24] មាត្រា ៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[25] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ហើយក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ដែលមាននៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ តែបើអ្នកជំនាញពុំស្ថិតនៅក្នុងបញ្ជីថ្នាក់ជាតិទេនោះ អ្នកជំនាញនោះត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន និងជួយដោយភក្តីភាពដល់តុលាការ[26]។

**១.១.៣.៤.ការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការឃាត់ខ្លួននូវបុគ្គលដែលសង្ស័យថា បានចូលរួមប្រព្រឹត្តបទល្មើស ក្រៅពីបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស បុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីបទល្មើស ឬដំណើររឿងហេតុបានដែរ។ ក្នុងករណីដែលបុគ្គលនោះអាចផ្តល់ព័ត៌មាន បានតែប្រកែកមិនព្រមផ្តល់ព័ត៌មាន ដោយមានការយល់ព្រមអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

រយៈពេលនៃការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំ) ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

តែក្នុងបទឧក្រិដ្ឋដែលតម្រុយភស្តុតាងបានបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ហើយវិធានការនៃការឃាត់ខ្លួនជាភាពចាំបាច់ដើម្បីធ្វើការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ហើយផុតរយៈដូចបានកំណត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំធ្វើការពន្យាពេលនៃការឃាត់ខ្លួនបុគ្គលនេះបន្ថែម តែមិនឱ្យលើសពី ២៤ ម៉ោងនោះទេ ហើយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា។ លិខិតដែលអនុញ្ញាតនេះត្រូវមានសំអាងហេតុ និងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

ការពន្យាពេលនៃការឃាត់ខ្លួន មិនអាចធ្វើការពន្យាពេលបានឡើយ ប្រសិនបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន ហើយរយៈពេលនៃការឃាត់ខ្លួនអនីតិជនអាចត្រូវធ្វើទៅបានក្នុងករណីដូចខាងក្រោមនេះ[27] ៖

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងឡើយ
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ២៤ម៉ោងឡើយ

[26] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[27] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោងឡើយ
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងឡើយ។

ដោយឡែកអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនត្រូវបានធ្វើការឃាត់ខ្លួននោះទេ។

គ្រប់បុគ្គលដែលត្រូវបានឃាត់ខ្លួន មានសិទ្ធិក្នុងការទទួលបានជំនួញពីមេធាវី ដែលមេធាវី ឬអ្នកដែលបុគ្គលត្រូវបានជ្រើសរើសដោយបុគ្គលដែលគេឃាត់ខ្លួន (បុគ្គលដែលពុំជាប់ពាក់ព័ន្ធនឹងរឿងក្តី) អាចធ្វើការសន្ទនាជាមួយនឹងបុគ្គលដែលត្រូវបានគេឃាត់ខ្លួនរយៈពេល ៣០នាទីក្នុងលក្ខខណ្ឌសម្ងាត់ក្រោយពេលដែលបុគ្គលនេះត្រូវបានគេឃាត់ខ្លួនរយៈ ២៤ម៉ោងរួចមក[28]។

ប្រសិនបើមានការចាំបាច់ដើម្បីពិនិត្យសុខភាពនោះ មន្រ្តីនគរបាលយុត្តិធម៌អាចសុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គល ដែលបានឃាត់ខ្លួនបានគ្រប់ពេលវេលា។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពបុគ្គលដែលបានឃាត់ខ្លួនសមស្របនឹងការឃាត់ខ្លួនដែរ ឬទេ? ប្រសិនបើគ្រូពេទ្យយល់ឃើញថាស្ថានភាពបុគ្គលដែលបានឃាត់ខ្លួនពុំសមស្របនឹងការឃាត់ខ្លួនទេនោះ មន្រ្តីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យត្រូវចេញវិញ្ញាបនបត្របញ្ជាក់សុខភាពភ្ជាប់ជាមួយសំណុំរឿង[29]។

ចំពោះអនីតិជនដែលត្រូវបានឃាត់ខ្លួន មន្រ្តីនគរបាលយុត្តិធម៌ត្រូវធ្វើការជូនដំណឹងដល់ឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកដែលទទួលភារកិច្ចលើអនីតិជននោះ[30]។

ការឃាត់ខ្លួននេះ មន្រ្តីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួនដាក់បញ្ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ[31]។

### ១.១.៣.៥.ការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនដល់ព្រះរាជអាជ្ញា

ក្រោយពីផុតរយៈនៃការឃាត់ខ្លួនហើយ មន្រ្តីនគរបាលយុត្តិធម៌ ត្រូវធ្វើការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា បើពុំនោះទេត្រូវដោះលែងជនដែលត្រូវបានឃាត់ខ្លួនឱ្យមានសេរីភាព

[28] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[29] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[30] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[31] មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ឡើងវិញ ហើយសេចក្ដីសម្រេចនៃការដោះលែងជនត្រូវឃាត់ខ្លួន ត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា[32]។

ការបញ្ជូនខ្លួនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា មានន័យថាបុគ្គលនោះត្រូវបានគេនាំយកទៅបង្ហាញខ្លួនភ្លាមនៅចំពោះមុខព្រះរាជអាជ្ញា។ ហើយករណីដែលការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនធ្វើការបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ពុំអាចធ្វើឡើងក្នុងថ្ងៃតែមួយបាននោះទេ ដោយសារមូលហេតុលំបាកនៃការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកបញ្ជូននោះរយៈពេលបន្ថែមអាចត្រូវបន្ថែមឱ្យដោយព្រះរាជអាជ្ញាបាន។ ហើយការបង្ហាញខ្លួននេះ ត្រូវធ្វើឡើងក្នុងរយៈពេលដ៏ឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន[33]។

មូលហេតុនៃការឃើតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

❖ **ជាបទពិសោធអនុវត្តជាក់ស្ដែងនៅសាលាដំបូងខេត្តកំពត**

មន្ត្រីនគរបាលយុត្តិធម៌នៅ ស្នងការដ្ឋាននគបាលខេត្តកំពត ផ្នែកប្រឆាំងគ្រឿងញៀនបានទទួលបញ្ជាផ្ទាល់មាត់ និងចូលរួមដឹកនាំដោយផ្ទាល់ពីលោកព្រះរាជអាជ្ញានៃអយ្យការខេត្តកំពត បានធ្វើការឆែកឆេរលំនៅដ្ឋានរបស់ឈ្មោះ **ក** ភេទស្រី អាយុ ៥៥ឆ្នាំ នៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបនាទី ការឆែកឆេរបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំមួយ និងសែសិបនាទី នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧[34]។

បានរកឃើញវត្ថុតាំងមួយចំនួនមានដូចខាងក្រោមៈ

១-ម្សៅក្រាមពណ៌ថ្លាចំនួន ០៤ កញ្ចប់ធំ និង ០២កញ្ចប់តូច

២-ថ្នាំយ៉ាម៉ាពណ៌ផ្កាឈូក ០៥ គ្រាប់កន្លះ

៣-ជញ្ជីងថ្លឹងគ្រឿងញៀនចំនួនមួយ

៤-ឧបករណ៍ជក់មួយកំប្លេ

៥-ទូរស័ព្ទដៃ ០៥គ្រឿង

៦-ថ្នាំសម្រើប ០៩ប្រអប់

[32] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[33] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[34] កំណត់ហេតុឆែកឆេរលំនៅដ្ឋាន និងចាប់យកវត្ថុតាំងនៅក្នុងឧបសម្ព័ន្ធ

៧-លិង្គសិប្បនិមិត្ត ០១

៨-ឡៃបថប ០២គ្រឿង

៩-ប្រាក់រៀល ៥០ម៉ឺន

១០-ប្រាក់ដុល្លារ ៣០០ ដុល្លារ

១១-កេះដែក ០១

១២-ប៉ាស្តរ ០១

១៣-ស្បោងផ្លាស្ទិចច្រកគ្រឿងញៀនមួយចំនួន[35]។

ក្រោយពីបានដកហូតវត្ថុតាងខាងលើ មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីបច្ចេកទេសនៃស្នងការនគរបាលខេត្តកំពត បានដំណើការធ្វើតេស្ត និងវេចខ្ចប់វត្ថុតាងខុសច្បាប់ខាងលើនៅចំពោះមុខជនសង្ស័យ ដាក់បញ្ចូលក្នុងស្រោមសំបុត្រប្រភេទ$A_2$មានភិនភាគពណ៌ខ្លាញ់ក្តាម បិទដោយស្កុតពណ៌សដែលដកហូតបានពីជនសង្ស័យឈ្មោះ **ខ** និងជនសង្ស័យឈ្មោះ **គ**។ ក្រោយពីបានកំណត់ហេតុចាប់យកវត្ថុតាងរួច មន្ត្រីនគរបាលយុត្តិធម៌ បានអានឱ្យសាមីខ្លួនស្តាប់ និងពិនិត្យឡើងវិញ ដោយបញ្ជាក់ថាត្រឹមត្រូវ និងយល់ព្រមផ្តិតម្រាមដៃសាមីជនម្ចាស់វត្ថុតាង[36]។

នៅក្នុងដំណើការឆែកឆេរលំនៅដ្ឋានរបស់ឈ្មោះ **ក** ភេទស្រី អាយុ ៥៥ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌បានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ សញ្ជាតិអូស្ត្រាលី និងឈ្មោះ **គ** ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ កំពុងប្រព្រឹត្តបទល្មើស នៅចំណុចភូមិសុវណ្ណសាគរ សង្កាត់ កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត។ ក្នុងបទល្មើសជាក់ស្តែងករណីជួញដូរ និងប្រើប្រាស់គ្រឿងញៀន[37]។ និងបានសួរយកចម្លើយជនសង្ស័យះ

១-ឈ្មោះ **ខ** ឆ្លើយថាខ្ញុំសូមរៀបរាប់ប្រាប់សមត្ថកិច្ចថា ខ្ញុំចូលមករស់នៅកម្ពុជាតាំងពីឆ្នាំ២០០៩គិតមកដល់ពីនេះមានរយៈ ៩ឆ្នាំ ហើយ។ ក្រោយមកខ្ញុំធ្លាប់ទិញថ្នាំញៀនពីស្រីខ្មែរឈ្មោះ **ង** ជាស្រីធ្វើការនៅហាងខារ៉ាអូខេ និងធ្លាប់ទិញថ្នាំញៀនពីអ្នករត់ម៉ូតូកង់បី ទិញម្តងៗតំលៃចាប់ពី ១០០ ដុល្លារទៅ៣០០ ដុល្លារ ហើយខ្ញុំបានទិញជញ្ជីងសម្រាប់ថ្លឹងថ្នាំមួយតំលៃ ៣០ដុល្លារ ទុកសម្រាប់ថ្លឹងថ្នាំជក់ជាមួយសង្សារ និងមិត្តភក្រ្តផ្សេងទៀត។ ក្នុងខែមេសា ឆ្នាំ២០១៧ ខ្ញុំបានមករស់នៅខេត្តកំពត នៅថ្ងៃទី

[35] កំណត់ហេតុឆែកឆេរលំនៅដ្ឋាន និងចាប់យកវត្ថុតាំងនៅក្នុងឧបសម្ព័ន្ធ

[36] កំណត់ហេតុឆែកឆេរលំនៅដ្ឋាន និងចាប់យកវត្ថុតាំងនៅក្នុងឧបសម្ព័ន្ធ

[37] កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែងនៅក្នុងឧបសម្ព័ន្ធ

១៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៦ និង ៣០នាទី ក៏ត្រូវបានសមត្ថកិច្ចចុះមកបង្ក្រាប ហើយឆែកឆេររកឃើញថ្នាំញៀនជាច្រើន និងឃាត់ខ្លួនខ្ញុំ និងសង្សាររបស់ខ្ញុំមកទាំងអស់គ្នា។

២-ឈ្មោះ **គ** បានឆ្លើយថា នាងខ្ញុំចេះប្រើគ្រឿងញៀនតាំងពីអាយុ ១៧ឆ្នាំមកម្លេះ។ កាលមុននាងខ្ញុំធ្លាប់ទៅយកថ្នាំញៀននៅភ្នំពេញ ក្នុង១ជី តំលៃ ១២០ ដុល្លារ ឱ្យឈ្មោះ **ឃ** ហើយគាត់ឱ្យនាងខ្ញុំចាយ ១០ដុល្លារ ក្នុងតំលៃថ្នាំ ១២០ដុល្លារ ឈ្មោះ **ច** គាត់ឱ្យនាងខ្ញុំចាយ ១០ដុល្លារដែរ។ ក្រោយមកទៀតនាងខ្ញុំបានតេសួរឈ្មោះ **ឃ** ថាត្រូវការថ្នាំបន្ថែមទៀតអត់ គាត់ថាមានច្រើនហើយ ទិញពីឈ្មោះ **ឆ** ក្នុង ០១ជី តែ ១០០ដុល្លារ ទិញមួយដង ៣ជី ស្មើ ៣០០ដុល្លារ ហើយនាងខ្ញុំទើបតែមករស់ជាមួយគាត់នៅកំពត ទើបតែបានរយៈពេល ០១ខែប៉ុណ្ណោះ។ ចំពោះនាងខ្ញុំ ពេលធ្វើការងារ ហើយខ្ញុំសុំគាត់លេងគាត់លេងថ្នាំ លុះមកដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៧ ស្រាប់តែសមត្ថកិច្ចចាប់ឃាត់ខ្លួននាងខ្ញុំមកកាន់ស្នងការតែម្តង។

ក្រោយពីបានសួរយកចម្លើយជនសង្ស័យកំណត់ហេតុរួច មន្ត្រីនគរយុត្តិធម៌បានអានសារឡើងវិញដោយ និងអះអាងថាពិតជាត្រឹមត្រូវ និងយល់ព្រមផ្តិតម្រាមដៃជនសង្ស័យ[38]។

ឆ្លងតាមការស៊ើបអង្កេត ដែលបានធ្វើឡើងបានបង្ហាញឱ្យឃើញថា៖ ជនសង្ស័យពិតជាបានជួញដូរ និងប្រើប្រាស់សារធាតុញៀន និងប្រើប្រាស់ពិតប្រាកដមែន មន្ត្រីនគរយុត្តិធម៌បានកសាងសំណុំរឿង រួចបញ្ជូនជនសង្ស័យ ចំនួន០២នាក់ និងវត្ថុតាងពាក់ព័ន្ធករណី ជួញដូរ និងប្រើប្រាស់សារធាតុញៀនមួយករណី ស្ថិតនៅ ភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពតប្រគល់ជូន ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពត ដើម្បីចាត់ការតាមនីតិវិធីច្បាប់[39] ។

នៅដំណាក់កាលសួរយកចម្លើយជនសង្ស័យឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ សញ្ជាតិអូស្ត្រាលី ឈ្មោះ**ប** អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកបកប្រែ បានស្ម័គ្រចិត្តធ្វើជាអ្នកបកប្រែ និងបានធ្វើសម្បថ[40]។

### ១.១.៤.វិធានពិសេសក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចក្នុងការបង្គាប់ឱ្យស្តាប់ និងថតសំឡេងការសន្ទនាតាមទូរស័ព្ទ ថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ( ដូចជាសារតាមទូរសា ឬ សារតាមអិនធើណែត ) នោះឡើយ[41]។

[38] កំណត់ហេតុលើការស្តាប់ចម្លើយនៅក្នុងឧបសម្ព័ន្ធ

[39] របាយការណ៍លេខ: ១២៧១ របស់ស្នងការដ្ឋាននគរបាលខេត្តកំពតក្នុងឧបសម្ព័ន្ធ

[40] កំណត់ហេតុសួរចម្លើ និងកំណត់ហេតុស្តីពីការធ្វើសម្បថនៅក្នុងឧបសម្ព័ន្ធ

ក្រោយបញ្ចប់ការស៊ើបអង្កេតជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ ការបញ្ជូនកំណត់ហេតុ និងវត្ថុចាប់យកទាំងអស់ទៅព្រះរាជអាជ្ញា។ ហើយបុគ្គលដែលត្រូវបាន បញ្ជូនទៅព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនទាំងមនុស្ស និងកំណត់ហេតុរួម នឹងវត្ថុតាងទៅផងដែរ [42]។

មន្ត្រីនគរបាលយុត្តិធម៌ដែលពុំគោរពតាមវិធាន និងទម្រង់នៃការស៊ើបអង្កេតជាក់ស្តែងខាងលើនេះទេដែលមាន[43] ៖

- កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការឆែកឆេរក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការបិទស្លាកបោះត្រាលើវត្ថុតាងក្នុងការស៊ើបអង្កេតជាក់ស្តែង
- កំណត់ហេតុលើការស្តាប់ចម្លើយក្នុងការស៊ើបអង្កេតជាក់ស្តែង
- បទបញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង
- ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ
- កំណត់ហេតុស្តីពីការឃាត់ខ្លួន
- ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន
- ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង
- ថិរវេលានៃការស៊ើបអង្កេតជាក់ស្តែង
- និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ

នឹងនាំឱ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ។

### ១.២.ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជាការស្រាវជ្រាវប្រមូលភស្តុតាងដែលធ្វើឡើងនៅពេលដែលមានបទល្មើសមិនជាក់ស្តែង ។

[41] មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[42] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[43] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីដែលបានដឹងអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងជាបឋម ឬតាមការស្នើសុំ ( បញ្ជា ) របស់ព្រះរាជអាជ្ញា[44]។ ចំពោះថិរវេលានៃការស៊ើបអង្កេតបឋម គឺមិនមានថិរវេលាជាក់លាក់នោះទេ។ នៅក្នុងវិធានដែលទាក់ទងនឹងការស៊ើបអង្កេតនេះ គឺមានវិធានមួយចំនួនត្រូវបានអនុវត្តដូចគ្នានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ហើយមានវិធានមួយចំនួនមានលក្ខណៈខុសគ្នា និងការស៊ើបអង្កេតករណីជាក់ស្តែងដែរ ព្រោះថាអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងលក្ខខណ្ឌនៃការស៊ើបអង្កេតបឋមត្រូវបានកំណត់តឹងរឹងជាងការស៊ើបអង្កេតករណីជាក់ស្តែង ។

### ១.២.១.វិធាននៃការស្រាវជ្រាវ ក្នុងករណីបទល្មើសមិនជាក់ស្តែង

#### ១.២.១.១.ការឆែកឆេរ និងចាប់យកវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបានផងដែរ ក្នុងករណីនៃការស៊ើបអង្កេតបទល្មើសមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានការយល់ព្រម ដែលធ្វើឡើងដោយលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ។

ហើយក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធមិនឱ្យធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចធ្វើសំណើសុំដីកាអនុញ្ញាតឱ្យធ្វើការឆែកឆេរដែលចេញដោយប្រធានសាលាដំបូង ហើយការដឹកនាំនៃវិធានក្នុងការឆែកឆេរនេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា។ ការឆែកឆេរនេះត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

ចំពោះការឆែកឆេរនេះ មិនផ្តើមការឆែកឆេរនៅមុខម៉ោង០៦ ( ប្រាំមួយ ) ព្រឹក និងក្រោយម៉ោង១៨ ( ដប់ប្រាំបី ) ល្ងាចឡើយ[45]។

[44] មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[45] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីដែលមន្ត្រីនរគបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់ ( វត្ថុតាង ) យកនោះ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ។

**១.២.១.២.ការបញ្ជាឱ្យចូលខ្លួន និងស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងក្តីនេះបាន។ ការស្តាប់ចម្លើយ ( សួរយកចម្លើយ ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីដែលជនត្រូវបានស្តាប់ចម្លើយជាជនបរទេស គថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលបានរួមសហការក្នុងរឿងក្តីនេះឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយ រួចហើយត្រូវអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ ( និងអ្នកបកប្រែបើមាន ) ហើយឱ្យចុះហត្ថលេខា ឬផ្តិតខ្មៅដៃគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណីដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតម្រាមដៃទេនោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុអំពីហេតុការណ៍នេះ។

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនិងការកោះហៅនេះ មន្ត្រីនគរបាលអាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឱ្យចេញ ដីកាបញ្ជាឱ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួនបាន[46]។

**១.២.១.៣.ការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន**

វិធានពាក់ព័ន្ធនឹងការឃាត់ខ្លួន និងការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ក្នុងការស៊ើបអង្កេតជាក់ស្តែង ត្រូវបានយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋម។

[46] មាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

#### ១.២.២.វិធានពិសេសក្នុងការស៊ើបអង្កេតបឋម

មន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការស៊ើបអង្កេតបឋមខាងលើនេះទេ ដែលមាន [47]៖

- ការឃាត់ខ្លួន
- កំណត់ហេតុនៃការឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង
- ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា
- ការឆែកឆេរ
- ការបញ្ជាឱ្យចូលខ្លួន

នឹងនាំឱ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ។

## ផ្នែកទី២ នីតិវិធីនៃការស៊ើបសួរ

### ២.១.ការបើកការស៊ើបសួរ

#### ២.១.១.បែបបទនៃបណ្តឹង

##### ២.១.១.១.សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរ អាចធ្វើឡើងប្រឆាំងនឹងជនស្គាល់ឈ្មោះ ឬជនមិនស្គាល់ឈ្មោះ។ ក្នុងករណីដែលពុំមានចង្អុលប្រាប់ឈ្មោះ ការស៊ើបសួរត្រូវបើកប្រឆាំងនឹងអញ្ញត្រជន ជនមិនស្គាល់ឈ្មោះ[48]។ វាគឺជាវិធានការដែលត្រូវគោរព បើពុំនោះទេនឹងមានមោឃភាពនៃនីតិវិធី។ ដូចនេះដីកាសន្និដ្ឋាននេះ គឺជាលិខិតដែលបើកឱ្យមានបណ្តឹងអាជ្ញាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឱ្យធ្វើការស៊ើបសួរលើអង្គហេតុមួយ ឬច្រើនដែលអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលបញ្ជូនទៅចៅក្រមស៊ើបសួរ។ ក្នុងការអនុវត្តជាក់ស្តែង សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមានភ្ជាប់ជាមួយលិខិតផ្សេងៗ ដែលកំណត់ពីអង្គហេតុ។ ក្នុងករណីនេះ គ្រាន់តែអ្នកចុះហត្ថលេខា

[47] មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[48] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ផ្ដល់ទិដ្ឋាការលើលិខិតទាំងនោះ វាគ្រប់គ្រាន់ទៅហើយ ព្រោះវាមានតម្លៃស្មើនឹងការវិភាគលិខិតនេះ។ លិខិតភ្ជាប់ត្រូវបានសន្មត់ថាមានផ្ទុកនូវគ្រប់ការចង្អុលបង្ហាញ ដែលចាំបាច់នានាសម្រាប់បំភ្លឺដល់ចៅក្រមស៊ើបសួរ និងដើម្បីអនុញ្ញាតឱ្យគាត់កំណត់ពីកម្មវត្ថុពិតប្រាកដ ព្រមទាំងវិសាលភាពនៃបណ្ដឹងដោយផ្អែកទៅលើការចង្អុលបង្ហាញក្នុងលិខិតភ្ជាប់នោះ។

ជាទូទៅលិខិតភ្ជាប់ គឺជាលិខិតដែលចេញក្នុងពេលស៊ើបអង្កេតជាក់ស្ដែង ឬពេលស៊ើបអង្កេតបឋម។ ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ ជានិច្ចកាលជាលិខិតលាយលក្ខណ៍អក្សរដែលត្រូវតែមានចុះកាលបរិច្ឆេទ និងហត្ថលេខា បើពុំនោះទេនឹងនាំឱ្យមានមោឃភាពទាំងដីកា និងលិខិតផ្សេងៗទៀតដែលចេញក្រោយមកទៀត។

### ២.១.១.២.បណ្ដឹងរបស់ជនរងគ្រោះដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ចៅក្រមស៊ើបសួរ ក៏អាចទទួលបណ្ដឹងតាមរយៈបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យប្ដឹងទៅចៅក្រមស៊ើបសួរ ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលធ្វើឡើងដោយជនរងគ្រោះខ្លួនឯងផ្ទាល់ ឬ ដោយមេធាវីក្នុងនាមរបស់ជនរងគ្រោះ[49]។

បន្ទាប់ពីធ្វើការកត់សម្គាល់តាមដីកានូវការដាក់ពាក្យបណ្ដឹងរួចមក ចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្ដឹងទៅព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋាន។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចធ្វើឡើងប្រឆាំងជនស្គាល់ឈ្មោះ ឬជនមិនស្គាល់ឈ្មោះ។ គួរកត់សម្គាល់ថា ក្នុងគ្រប់ករណីទាំងអស់ ត្រូវមានលិខិតរបស់អយ្យការ។ ដូចនេះបណ្ដឹងអាជ្ញានឹងត្រូវបានបើកដោយត្រឹមត្រូវដោយដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ព្រះរាជអាជ្ញា។ មានន័យថាបណ្ដឹងនេះត្រូវបានបើកតាមផ្លូវធម្មតា ដោយដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ព្រះរាជអាជ្ញា។

ប៉ុន្តែព្រះរាជអាជ្ញាអាចសុំកុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយសារមានការរលត់បណ្ដឹងអាជ្ញា ឬដោយសារអវត្តមាននៃបទល្មើសព្រហ្មទណ្ឌ ព្រោះអំពើដែលបរិហារដោយជនរងគ្រោះមិនអាចត្រូវបានស្ដីបន្ទោសបាន។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនបន្តការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុដែលត្រូវជូនដំណឹងដល់ជនរងគ្រោះ។ ភាគីរដ្ឋប្បវេណី និងព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងឧទ្ធរណ៍ពីដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលអាចជាដីកាមិនព្រមស៊ើបសួរ ឬ

[49] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ដីកាប្រកាសមិនទទួលបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរធ្វើសេចក្តីសន្និដ្ឋានមិនស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធដោយសំអាងហេតុដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា[50]។

នៅពេលដែលចៅក្រមស៊ើបសួរ ទទួលពាក្យបណ្តឹងដោយពុំមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ពាក្យបណ្តឹងនេះ ត្រូវដោះស្រាយដូចជាបណ្តឹងដទៃទៀត ដោយមានការពិនិត្យវាយតម្លៃ ដោយសេរីរបស់ព្រះរាជអាជ្ញាទៅលើចំណាត់ការបន្ត។ គ្រប់ជនរងគ្រោះនៃបទល្មើសដែលបានប្តឹងទៅចៅក្រមស៊ើបសួរ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានគ្រប់ពេលវេលានៃនីតិវិធី ការតាំងខ្លួននេះធ្វើឡើងដោយគ្មានទម្រង់អ្វីទេ វាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។

ដើម្បីការពារកុំឱ្យមានពាក្យបណ្តឹងដោយបំពាន ចៅក្រមស៊ើបសួរកំណត់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី បង់ប្រាក់តម្កល់ទុក ដែលផ្អែកលើធនធាន និងបន្ទុករបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏កំណត់ពីរយៈដែលត្រូវបង់ប្រាក់តម្កល់ទុកនោះផងដែរ[51]។

ប្រាក់តម្កល់ទុកនេះ មិនត្រូវបានបង្វិលទៅសាមីខ្លួនវិញទេ ប្រសិនបើឃើញថាពាក្យបណ្តឹងធ្វើឡើងដោយបំពាន ឬក្នុងគោលបំណងអូសបន្លាយពេលវេលា។ ក្នុងករណីនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវផ្តន្ទាទោសឱ្យបង់ប្រាក់ពិន័យ ដែលមានចំនួនមិនអាចលើសពីចំនួនទឹកប្រាក់ដែលតម្កល់ទុកនោះទេ។ សេចក្តីសម្រេចដែលធ្វើពិន័យនេះ ដើមបណ្តឹងរដ្ឋប្បវេណី ឬព្រះរាជអាជ្ញាអាចធ្វើឧទ្ធរណ៍បានពីដីកាផ្តន្ទាទោសនេះ[52]។

### ២.១.២.អានុភាពនៃបណ្តឹង

#### ២.១.២.១.ភាតព្វកិច្ចស៊ើបសួរ

ចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្តឹងដោយត្រឹមត្រូវ មានករណីយកិច្ចត្រូវស៊ើបសួរលើបណ្តឹងនោះ។ ដូចនេះចៅក្រមស៊ើបសួរ មិនអាចបដិសេធការស៊ើបសួររឿងអ្វីមួយដោយសំអាងថាការស៊ើបសួរពុំមានប្រយោជន៍ ព្រោះរឿងក្តីនេះការស៊ើបសួររួចហើយ។ ចៅក្រមស៊ើបសួរមិនស៊ើបសួរ

[50] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[51] មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[52] មាត្រា ១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ដោយយកលេសថា ការស៊ើបសួរពុំអាចទទួលលទ្ធផល ព្រោះអំពើនោះមិនមែនជាបទល្មើសដែលចែងក្នុងសេចក្តីសន្និដ្ឋាន ទោះបីជាអំពើនោះល្មើសក៏ដោយ។

ប៉ុន្តែ កាតព្វកិច្ចនេះមានកំណត់ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចផ្ទៀងផ្ទាត់សមត្ថកិច្ចសម្ភារ និងសមត្ថកិច្ចដែនដី។ ជាអាទិ៍ ចៅក្រមស៊ើបសួរមិនអាចប្រកាសថាខ្លួនពុំមានសមត្ថកិច្ចខាងដែនដីដ៏វាបណាចៅក្រមស៊ើបសួរមិនទាន់បានធ្វើការស្រាវជ្រាវចាំបាច់នានា ដើម្បីផ្ទៀងផ្ទាត់សមត្ថកិច្ចរបស់ខ្លួន ជាពិសេសប្រសិនបើគាត់ទទួលបណ្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសរសេរថាម្នាក់ក្នុងចំណោមជនដែលសង្ស័យ និងដែលត្រូវបរិហារស់នៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ខ្លួនពុំមានសមត្ថកិច្ច គាត់ចេញដីកាអសមត្ថកិច្ច ប៉ុន្តែបើគាត់ទទួលពាក្យបណ្តឹងពីដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវតែសម្រេចដោយយោងតាមសេចក្តីសន្និដ្ឋានរបស់អយ្យការ។

ក្នុងករណីផ្សេងទៀត ថ្វីបើវាជាសមត្ថកិច្ចតាមសាច់រឿងក្តី និងតាមដែនដីរបស់គាត់ក៏ពិតមែន ប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេធមិនស៊ើបសួរបាន ដោយចេញដីកាដែលមានសំអាងហេតុក្នុងខណៈដែលការចោទប្រកាន់ហាក់មិនអាចធ្វើទៅបាន។ ឧទាហរណ៍ ករណីដែលរឿងមួយមិនអនុញ្ញាតឱ្យមានការស៊ើបសួរ ប្រសិនបើអំពើមិនអាចចាត់ទុកជាបទល្មើស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាផុតរលត់ ឬរឿងរ៉ាវត្រូវបានវិនិច្ឆ័យរួចហើយ។

### ២.១.២.២.វិសាលភាពនៃបណ្តឹង

ចៅក្រមស៊ើបសួរ ទទួលបណ្តឹងតែអំពីហេតុដែលជាបទល្មើសដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដូចនេះ ត្រូវចាត់ទុកថាចៅក្រមស៊ើបសួរបានប្រព្រឹត្តដោយការរំលោភបំពានអំណាច ដែលត្រូវផ្តន្ទាទោសដោយមោឃភាពដោយសារអសមត្ថភាព ប្រសិនបើចៅក្រមស៊ើបសួរធ្វើការស៊ើបសួរលើអង្គហេតុផ្សេងទៀត។ នេះជាការអនុវត្តការហាមឃាត់ស្វ័យបណ្តឹងរបស់ចៅក្រមស៊ើបសួរ។ ជួនកាលវាមានការលំបាកក្នុងការដឹងថា តើអំពើអ្វីខ្លះដែលមានក្នុង បណ្តឹង។ ក្នុងការអនុវត្តជាក់ស្តែង ចៅក្រមស៊ើបសួរ ទទួលពាក្យបណ្តឹងក្នុង ០៣ករណីដូចខាងក្រោមនេះ [53]៖

- អំពើដែលរៀបរាប់ក្នុងឯកសារភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមិនត្រូវស៊ើបសួរអំពើ ដែលមិនមាននៅក្នុងនីតិវិធី ទោះជាក្រោមរូបភាពណាក៏ដោយ។

[53] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

- អំពើដែលអយ្យការបញ្ជូនមកឱ្យចៅក្រមស៊ើបសួរ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់អនុញ្ញាតឱ្យព្រះរាជអាជ្ញា ជ្រើសរើសនូវអង្គហេតុណាដែលគាត់ចង់ឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរតែទៅលើអំពើដែលលើកឡើងដោយអយ្យការ។ ទោះជាអំពើលួច ឬ ទទួលផលចោរកម្ម គឺមានចុះក្នុងបណ្តឹងដំបូងក៏ដោយ តែប្រសិនបើអយ្យការចង់បើកការស៊ើបសួរ ទៅការកាន់កាប់អាវុធហាមឃាត់ ការចោទប្រកាន់មិនអាចត្រូវពង្រីកទៅលើបទល្មើសលួច ឬទទួលផលចោរកម្មទេ។ ដូចនេះព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការបញ្ជាក់ឱ្យច្បាស់លាស់ ដោយធ្វើការបញ្ជាក់អង្គហេតុនិងឈ្មោះបទល្មើស ព្រះរាជអាជ្ញាដាក់ចៅក្រមស៊ើបសួរឱ្យស្ថិតក្នុងស្ថានភាពមួយដែលអាចឱ្យចៅក្រមស៊ើបសួរដឹងថា តើថាចៅក្រមស៊ើបសួរទទួលបណ្តឹងពីអ្វី។

យើងបានឃើញរួចមកហើយថា មានដំណោះស្រាយផ្សេង ក្នុងករណីបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រោះចៅក្រមមានកាតព្វកិច្ចស៊ើបសួរគ្រប់អង្គហេតុទាំងអស់ដែលចង្អុលបង្ហាញដោយភាគីរដ្ឋប្បវេណី ប្រសិនបើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានបដិសេធចោល ទោះជាអង្គហេតុនោះ មិនបានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។

- អំពើដែលកើតឡើងមុខដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរពុំមានសមត្ថកិច្ចទៅលើអំពើដែលបានប្រព្រឹត្តបន្ទាប់ពីកាលបរិច្ឆេទ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ ដូចនេះ គាត់ត្រូវបញ្ជូនសំណុំរឿងរបស់ខ្លួនដើម្បីសុំដីកាសន្និដ្ឋានបន្ថែម។

ចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបរបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។

ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរមានសេរីភាពកំណត់ឈ្មោះបទល្មើស ទៅលើអង្គហេតុ។ ចៅក្រមស៊ើបសួរ អាចកំណត់ឈ្មោះបទល្មើសដោយសេរី ទៅលើអង្គហេតុដែលប្តឹងមកគាត់

តាមរយៈបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

ក្នុងពេលកំពុងស៊ើបសួរ ការចោទប្រកាន់គ្រាន់តែចង្អុលបង្ហាញ និងអាចត្រូវបានកែប្រែ។ ហេតុដូចនេះ វាមិនសំខាន់ទេ ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ឈ្មោះបទល្មើស លើអំពើដែលមានក្នុងបណ្ដឹងខុស ព្រោះវាជាកិច្ចការរបស់យុត្តាធិការស៊ើបសួរក្នុងការពិនិត្យវិភាគអង្គហេតុ ក្រោមគ្រប់ទម្រង់បទល្មើស។ ចៅក្រមស៊ើបសួរ ពុំមានកាតព្វកិច្ចបញ្ជូនរឿងទៅព្រះរាជអាជ្ញា មុនពេលដាក់ឈ្មោះបទល្មើសថ្មីមួយទៀតទៅលើអំពើដែលប្ដឹង និងពុំមានកាតព្វកិច្ចជូនដំណឹងពីការចោទប្រកាន់បទល្មើសបទនេះទេ។

មិនតែប៉ុណ្ណោះចៅក្រមស៊ើបសួរ មានសេរីភាពក្នុងការដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវគ្រប់បុគ្គលមិនស្គាល់ឈ្មោះ ក្នុងពាក្យបណ្ដឹង តែមានតម្រុយថាមានពិរុទ្ធភាព។ ដូចនេះ គាត់ពុំចាំបាច់សុំដីកាសន្និដ្ឋានបន្ថែមទេ។ ផ្ទុយទៅវិញ ទាក់ទងនឹងបុគ្គលដែលមានចែងចង្អុលបង្ហាញឈ្មោះក្នុងដីកាសន្និដ្ឋានគាត់ពុំមានសេរីភាពអ្វីទាំងអស់ ព្រោះមាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែង ចៅក្រមស៊ើបសួរត្រូវតែចោទប្រកាន់បុគ្គលទាំងនោះ។

### ២.២.ការបិទការស៊ើបសួរ

#### ២.២.១.ការជូនដំណឹងបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរ ពិនិត្យវាយតម្លៃដោយអធិបតេយ្យនូវខណៈពេលដែលត្រូវបញ្ចប់ការស៊ើបសួរជាអាទិ៍នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការរកភស្តុតាងមិនតម្រូវឱ្យមានកិច្ចការស្រាវជ្រាវអ្វីមួយ គាត់សម្រេចបិទការស៊ើបសួរដោយអធិបតេយ្យរបស់គាត់។

ក្រមនីតិវិធីព្រហ្មទណ្ឌពុំចែងពីចិរវេលានៃការស៊ើបសួរទេ។ ប៉ុន្តែយើងអាចគិតថាវាជាសមត្ថកិច្ចរបស់សភាស៊ើបសួរក្នុងការធានាវ៉ាប់រងឱ្យការស៊ើបសួរនេះ ធ្វើឡើងក្នុងចិរវេលាសមរម្យមួយដោយពុំទុកឱ្យសំណុំរឿងកក់ស្ទះនឹងភាពអសកម្មយូរពេក។

ទោះជាសេចក្ដីសម្រេចបញ្ឈប់ការស៊ើបសួរ ជានិច្ចការជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក៏ដោយក៏ភាគីវិវាទ មានសិទ្ធិសុំឱ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរ ក្នុងករណីដូចតទៅជនត្រូវចោទនិងជនរងគ្រោះ អាចសុំឱ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរនៅពេលផុតរយៈមួយឆ្នាំ បន្ទាប់ពីការចោទប្រកាន់ចំពោះជនត្រូវចោទ ឬបន្ទាប់ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះជនរងគ្រោះ។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី ហើយ ០២ (ពីរ)

ថ្ងៃក្រោយមកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ការជូនព័ត៌មានអំពីការបិទការស៊ើបសួរនេះ គឺទុកលទ្ធភាពឱ្យភាគីមានឱកាសផ្តល់ភស្តុតាងផ្សេងៗបន្ថែម ឬស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយដែលភាគីយល់ថាមានប្រយោជន៍ សម្រាប់រឿងក្តីរបស់ខ្លួន និងម្យ៉ាងទៀត ភាគីអាចមានសិទ្ធិក្នុងការប្តឹងសុំមោឃភាពនូវអនិយ័តភាពកិច្ចនីតិវិធីណាមួយ។ នៅចំណុចចុងក្រោយនេះ មានសារៈសំខាន់បំផុត និងការគោរពនូវសិទ្ធិ និងផលប្រយោជន៍របស់ភាគីផងដែរ ពីព្រោះពេលណាដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរួចហើយ ដីកានេះនឹងលុបលាងមោឃភាពនៃនីតិវិធីមុន ហើយគ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។

នៅពេលដែលទទួលសំណុំរឿងមកពិនិត្យ បើសិនយល់ឃើញថា ចាំបាច់ធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញា ត្រូវធ្វើតាមមាត្រា១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោល គឺនៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ បើសិនចៅក្រមស៊ើបសួរមិនព្រមធ្វើការសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ ដោយមានសំអាងហេតុ នៅក្នុងរយៈពេល ១៥ថ្ងៃ និងជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថិរវេលាយ៉ាងឆាប់បំផុត។ ក្នុងករណីដែលមិនបានសម្រេចក្នុងរយៈពេល ១៥ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើជនត្រូវចោទឃុំខ្លួន និងក្នុងរយៈ០១ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ គិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។

បើយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់[54]។

[54] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

**២.២.២.ការបិទការស៊ើបសួរតាមបណ្ដឹងរបស់ភាគី**

ដូចបានរៀបរាប់ខាងលើនេះមកហើយថា ការសម្រេចបិទការស៊ើបសួរ ជានិច្ចកាលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែថិរវេលានៃការបិទការស៊ើបសួរនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំមានចែងកំណត់ពេលមួយច្បាស់លាស់នោះទេ។ យុត្តិធម៌ដែលប្រកបដោយភាពយឺតយ៉ាវស្មើនឹងអយុត្តិធម៌។ កាលបើរឿងក្ដីមួយត្រូវបានអូសបន្លាយរយៈពេលយូរហួសហេតុវាជាផលវិបាកដែលធ្វើប៉ះពាល់ដល់សិទ្ធិភាគីផងដែរ។ ហេតុផលនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវបទបញ្ញត្តិមួយចំនួន ដែលអនុញ្ញាតឱ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុងដំណើការកិច្ចនីតិវិធីព្រហ្មទណ្ឌដើម្បីបញ្ចៀសភាពអសកម្មនៃកិច្ចនីតិវិធីស៊ើបសួរ។

ភាគីនៃរឿងក្ដីព្រហ្មទណ្ឌជាអាទិ៍ ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិធ្វើពាក្យស្នើសុំចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរបាន [55]៖

- នៅពេលផុតថិរវេលា ០១ឆ្នាំ គិតពិថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យបិទការស៊ើបសួរ។
- នៅពេលផុតថិរវេលា ០១ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំឱ្យបិទការស៊ើបសួរ។

ក្នុងរយៈពេល០១ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ អ្នកស្នើសុំអាចប្ដឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ញាចៅក្រមស៊ើបសួរសម្រេច។

ពាក្យសុំឱ្យបិទការស៊ើបសួរ អាចត្រូវប្រើប្រាស់ដោយមេធាវីបាន។

**២.២.៣.ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយដោយ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬជាដីកាលើកលែងចោទប្រកាន់។

កាលណាយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ដោយដីកាបញ្ជូននោះ ត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ហើយសំណុំរឿងត្រូវបញ្ជូនជាបន្ទាន់ទៅប្រធានតុលាការដើម្បីកំណត់ពេលវេលាសវនាការជំនុំជម្រះ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណី ដូចតទៅ ៖

[55] មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

១-អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

២-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

៣-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ ហើយដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។

ជានិច្ចកាល ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី[56]។

ដីកាដំណោះស្រាយអាចប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី[57]។ ហើយថិរវេលានៃការធ្វើបណ្តឹងឧទ្ធរណ៍មានរយៈពេល ០៥ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកា[58]។

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីកាប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក ( បទប្បញ្ញត្តិនៃមាត្រា១១៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានយកមកអនុវត្តផងដែរ )[59]។

ដីកាដំណោះស្រាយ មានអានុភាពបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ក្នុងករណីជនត្រូវចោទជាប់ឃុំខ្លួនះ ជនត្រូវចោទនឹងត្រូវដោះលែងឱ្យមានសេរីភាព ហើយមាត្រា២៧៦ ត្រូវយកមកអនុវត្ត។ ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ សេចក្តីសម្រេចរក្សាជនត្រូវចោទនេះ ត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយសេចក្តីសម្រេចនេះនឹងលែងមានអានុភាពក្នុងរយៈ ០៤ខែ។ ហេតុនេះ បើសិនជាជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈ ០៤ខែទេ ជនត្រូវចោទនេះ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។

[56] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[57] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[58] មាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[59] មាត្រា ២៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីជនត្រូវចោទជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយចៅក្រមស៊ើបសួរដាក់កំហិតឱ្យបង់ប្រាក់ធានា ឱ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬឱ្យប្រគល់អាវុធមិនទាក់ទិនបទល្មើស វត្ថុទាំងនេះ ត្រូវប្រគល់សងសាម៉ីខ្លួនវិញដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលទុកជាសម្គាល់។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ[60]។

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកផងដែរ។ បទប្បបញ្ញត្តិស្តីពីអាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ តាមមាត្រា១១៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ត្រូវយកមកអនុវត្តផងដែរ។

មួយវិញទៀត កាលបើចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ បើទោះបីដីកានេះចូលស្ថាពរក៏ដោយ ដីកានេះពុំមានអានុភាពអាជ្ញាអស់ជំនុំនោះទេ ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញាបានប្រសិនបើមានលេចឡើងនូវបន្ទុកថ្មី[61]។

❖ **ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពត**

កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង១៦ និង២០នាទី កម្លាំងអន្តរាគម៍ពិសេសឈុតខ្មៅសហការជាមួយកំលាំងអធិការនគរបាលក្រុងកំពត បានចុះបង្ក្រាបមុខសញ្ញា ជួញដូរ និងប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ មួយករណី ស្ថិតនៅភូមិសុវណ្ណសាគរ សង្កាត់កំពង់ កណ្តាលក្រុងកំពត ខេត្តកំពត ដែលប្រព្រឹត្តដោយជនត្រូវចោទចំនួន ០២នាក់ មានឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ ជាជនជាតិអូស្ត្រាលី និងសង្សារឈ្មោះ **គ** ភេទស្រី អាយុ ២៨ឆ្នាំ។ ក្នុងពេលចុះបង្ក្រាបជនត្រូវចោទសមត្ថកិច្ចបានឆែកឆេររកឃើញវត្ថុតាងជាអំពើល្មើសរួមមាន: ម្សៅ ក្រាមពណ៌សថ្លា ( ម៉ាទឹកកក ) ចំនួន ០៦កញ្ចប់ ទម្ងន់សរុប ១៩ក្រោម, ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១គ្រឿងញៀនចំនួន ០១គ្រឿង ថ្នាំគ្រាប់ផ្កាឈូកចំនួន ៥គ្រាប់កន្លះ ថ្នាំសម្រេបចំនួន ០៩កញ្ចប់ និងឧបករណ៍សម្រាប់ច្រក នឹងសម្រាប់ប្រើប្រាស់គ្រឿងញៀនមួយ ០១ចំនួនផ្សេងទៀត។

តាមរយៈការបើកស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ:៥២៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ មកឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនត្រូវចោទ ឈ្មោះ **ខ**

[60] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[61] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ភេទប្រុស អាយុ ៧២ឆ្នាំ ជនជាតិអូស្ត្រាលី និងឈ្មោះ **គ** ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ។ ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០,៤៥ នៃច្បាប់ស្តីពីត្រួតពិនិត្យគ្រឿងញៀន។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ខ** និង **គ** ហេតុដូច្នេះសម្រេចបញ្ជូនជនសង្ស័យទាំងពីរទៅតុលាការជំនុំជម្រះពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន[62]។

## ២.៣.អំណាចបទ្ទំរបស់ចៅក្រមស៊ើបសួរ

### ២.៣.១.ការស្វែងរកជាបឋមនូវជនល្មើស

#### ២.៣.១.១.ការចេញដីកា

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន[63]។

**១-ដីកាបង្គាប់ឱ្យចូលខ្លួន៖** ដីកានេះ គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួន អាចចេញទៅបានតែលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ ដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ[64]។ តាមរយៈដីកានេះសាមីខ្លួនបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ ដោយសេរី មានន័យថា ការបង្ហាញខ្លួនតាមរយៈដីកានេះ ពុំមានតម្លៃបង្ខំដោយកងកម្លាំងសាធារណៈនោះទេ។ ដីកានេះ គឺជាបញ្ជាឱ្យសាមីខ្លួនចូលបង្ហាញខ្លួនតាមផ្លូវធម្មតា ដែលជាទូទៅដីកានេះត្រូវបានប្រើប្រាស់នៅពេល ដែលសាមីជននោះមិនបានរត់គេចខ្លួន ហើយពុំឆ្លើយតបទៅនឹងការកោះហៅតាមផ្លូវរដ្ឋបាល។

**២-ដីកាបង្គាប់ឱ្យនាំខ្លួន៖** ដីកានេះ គឺជាបញ្ជាដែលមានតម្លៃបង្ខំ ដែលបង្គាប់ដល់កងកម្លាំងសាធារណៈឱ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យនាំខ្លួនអាចចេញទៅបានតែលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ[65]។ ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារកិច្ចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅចំពោះមុខចៅក្រមស៊ើបសួរ ក្រោយពេលចាប់ខ្លួនបាន។ ប៉ុន្តែក្នុង

[62] ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ

[63] មាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[64] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[65] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ករណីដែលចៅក្រមស៊ើបសួរមិនអាចសួរចម្លើយជន នោះភ្លាមៗ ឬដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបានភ្លាមៗទេ ដីកានេះបាន អនុញ្ញាតមន្ត្រីនគរបាលយុត្តិធម៌ នាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅរក្សាទុកនៅអង្គភាព ក្នុងមណ្ឌល ឃុំខ្លួន ឬពន្ធនាគារបានដែលមានថិរវេលាមិនអាចលើសពី០១ថ្ងៃបានឡើយ ពោលគឺត្រូវតែនាំខ្លួន បុគ្គលដែលពាក់ព័ន្ធនេះ ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួស យ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់។ ផ្ទុយពីនេះបើសិនជាការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវ បាន ដោះលែងឱ្យមានសេរីភាពវិញ[66]។

ក្នុងករណីចុងក្រោយនេះ ប្រសិនបើបុគ្គលត្រូវនាំមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះ អាសន្ននោះដែរ[67]។

**កំណត់សម្គាល់៖**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ចាស់ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនបាន ចំពោះសាក្សីដែលរឹងទទឹងមិនព្រមចូលខ្លួនតាមការកោះហៅ ប៉ុន្តែតាមក្រមនីតិវិធីព្រហ្មទណ្ឌដែល ចូលជាធរមាន ហើយត្រូវបានអនុវត្តនាពេលបច្ចុប្បន្ននេះ នៅក្នុងក្របខណ្ឌនៃការចេញដីកាបង្គាប់ ឱ្យនាំខ្លួនចៅក្រមស៊ើបសួរត្រូវបានកម្រិតទុកជាស្រេច ដែលមានសិទ្ធិអំណាចក្នុងការចេញដីកា ប្រភេទនេះបានតែទៅលើជនត្រូវចោទ និងបុគ្គលដែលមាន តម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ។ មាន ន័យថាចៅក្រមស៊ើបសួរពុំអាចចេញដីកានេះចំពោះសាក្សីបានឡើយ ប៉ុន្តែ មិនមែនមានន័យថា ចៅក្រមស៊ើបសួរពុំមានលទ្ធភាពក្នុងការបង្ខំឱ្យសាក្សីបង្ហាញខ្លួននោះទេ។ កាលបើសាក្សីណាម្នាក់ ដែលចៅក្រមស៊ើបសួរយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត ហើយរឹងទទឹង មិនព្រមចូលបង្ហាញខ្លួន ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចស្នើសុំឱ្យកងកម្លាំងសាធារណៈបង្ខំឱ្យ សាក្សីរូបនោះបង្ហាញខ្លួនចំពោះមុខខ្លួនបាន ប៉ុន្តែមិនមែនដីកាបង្គាប់ឱ្យនាំខ្លួននោះទេ គឺបញ្ជាឱ្យចូល មកបង្ហាញខ្លួន។ សិទ្ធិអំណាច នេះត្រូវបានផ្តល់ឱ្យដោយមាត្រា១៥៣ កថាខណ្ឌទី៥ នៃក្រម នីតិវិធីព្រហ្មទណ្ឌ។

[66] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[67] មាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

**៣-ដីកាបង្គាប់ឱ្យចាប់ខ្លួន៖** ដីកានេះ គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលណាម្នាក់ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំ ខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចតទៅ[68]៖

- ចេញបានទៅលើជនត្រូវចោទ និងបុគ្គលដែលមានតម្រុយពីពិរុទ្ធភាព
- បទល្មើសដែលត្រូវចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ( ត្រង់ចំណុចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានកំណត់អំពីកម្រិតទោសដាក់ពន្ធនាគារនោះទេ ពោល គឺទោសដាក់ពន្ធនាគារជាទូទៅ )។ ក្នុងក្របខណ្ឌនេះ **ចៅក្រមស៊ើបសួរពុំមានសិទ្ធិអំណាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបុគ្គល ដែលទទួលរងការចោទប្រកាន់ពីបទល្មើសមជ្ឈិមដែលមានទោសពិន័យជាប្រាក់នោះឡើយ។**
- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ចៅក្រមស៊ើបសួរត្រូវសុំយោបល់ពីព្រះរាជអាជ្ញាជាមុនសិន (យោបល់របស់ព្រះរាជអាជ្ញា មិនចងកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរត្រូវតែអនុវត្តតាមនោះឡើយ)[69]។

ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ដោយមានថែងមូលហេតុ ជាអាទិ៍៖ បានគេចខ្លួន ឬមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជអាជ្ញាជាអ្នកធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងករណីបន្ទាន់ ការផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវធ្វើតាមគ្រប់មធ្យោបាយ[70]។ ហើយបើក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាលក្ខណៈអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព[71]។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចស្វែងរកចាប់ខ្លួន និងនាំបុគ្គល ដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួស ចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់។ ក្នុងករណីដែលពុំអាចធ្វើដូច្នេះបាន បុគ្គលដែលពាក់ព័ន្ធ ត្រូវបានសួរ

[68] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[69] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[70] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[71] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ចម្លើយ ដោយព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួន ហើយព្រះរាជអាជ្ញាត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរនូវកំណត់ហេតុសួរចម្លើយនោះ។

ដូចគ្នានឹងការប្រតិបត្តិដីកាបង្គាប់ឱ្យនាំខ្លួនដែរ ប្រការដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង០៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចបានទេ។

ក្នុងករណីបុគ្គលដែលត្រូវចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវបានឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ននោះដែរ[72]។

**គួរកត់សម្គាល់ថា៖** ចំពោះដីកាទាំងបីខាងលើនេះ ចៅក្រមស៊ើបសួរ អាចចេញបានដោយថ្លឹងថ្លែងទៅ តាមស្ថានភាព និងកាលៈទេសៈនៃសំណុំរឿងនីតិវិធី ដោយមិនចាំបាច់មានលំដាប់លំដោយនោះទេ។

**៩-ដីកាបង្គាប់ឱ្យឃុំខ្លួន៖** ដីកានេះ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលត្រូវតែឱ្យទទួល និងឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលបានដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែមានសេចក្តីសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន ហើយអាចបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែជនត្រូវចោទនោះជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ[73]។ នៅត្រង់ចំណុចចុងក្រោយនេះ បញ្ជាក់យ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលតាមន័យនេះ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់ ដោយមិនមានដីកាសម្រេចឃុំខ្លួន បណ្តោះអាសន្ននោះឡើយ។

❖ **ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពត**

នៅក្នុងសំណុំរឿងលេខៈ៨៩៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត បានបង្គាប់ឱ្យប្រធានពន្ធនាគារខេត្តកំពត ឱ្យឃុំខ្លួនឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ សញ្ជាតិអូស្រ្តាលី និងឈ្មោះ **គ** ភេទស្រី អាយុ២៨ សញ្ជាតិខ្មែរ ទទួលនឹងឃុំខ្លួនជននោះជាបណ្តោះអាសន្ន ដែលចោទប្រកាន់ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នៅសារធាតុញៀន ប្រព្រឹត្តនៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧

[72] មាត្រា ២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[73] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ពីបទល្មើសព្រហ្មទណ្ឌ ដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៩០,៩៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន[74]។

**២.៣.១.២.ការអនុវត្តដីកា**

ដីកាត្រូវបានអនុវត្តនៅលើវិសាលភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដីកានេះអនុវត្តរហូតដល់មានលិខិតជាក់លាក់ពីអាជ្ញាធរតុលាការ ដែលដកយកមកវិញ ជំនួសមកវិញ ឬលុបចោលនូវដីកាទាំងនោះ។ ដូចនេះវិនិច្ឆ័យ ដែលសម្រេចពីជោគវាសនារបស់បុគ្គលដែលពាក់ព័ន្ធក្នុងការសម្រេចទុកដីកាទាំងនេះជាមោឃៈ ឬចេញដីកាផ្សេងទៀត។

គ្រប់ដីកាទាំងអស់មានលក្ខណៈរួមមួយ គឺបង្ខំឱ្យមានការសួរចម្លើយបុគ្គលដែលពាក់ព័ន្ធដោយចៅក្រមស៊ើបសួរ ដែលចេញដីកាក្នុងពេលណាមួយនៃនីតិវិធីក៏បាន។ ជាអាទិ៍ នៅក្នុងដីកាបង្គាប់ឱ្យចូលខ្លួនចៅក្រម ត្រូវសួរចម្លើយភ្លាមចាប់តាំងពីពេលបុគ្គលនោះបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។

ចំពោះដីកាបង្គាប់ឱ្យនាំខ្លួនវាធ្វើឡើងក្នុងលក្ខខណ្ឌតែមួយ នឹងដីកាបង្គាប់ឱ្យចូលខ្លួន មានន័យថា ការសួរចម្លើយដោយចៅក្រមស៊ើបសួរ ត្រូវធ្វើភ្លាម លើកលែងតែមានឧបសគ្គ។

ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន ចាប់ផ្ដើមពីការជូនដំណឹងទៅបុគ្គលដែលចៅក្រមស៊ើបសួរចង់ស្ដាប់ចម្លើយនៅក្នុងការិយាល័យ ឬមន្ទីរស៊ើបសួររបស់ចៅក្រមស៊ើបសួរ នៅថ្ងៃ និងម៉ោងដែលបានកំណត់ក្នុងដីកានោះ។ អត្ថប្រយោជន៍របស់ដីកានេះ មានតិចតួច បើប្រៀបធៀបទៅនឹងការកោះហៅធម្មតារបស់រដ្ឋបាល។ ចាប់ពីពេលនេះ បុគ្គលពាក់ព័ន្ធដឹងថាខ្លួនឯងត្រូវបានសង្ស័យ ហើយបើសិនជា មិនចូលបង្ហាញខ្លួននៅការិយាល័យរបស់ចៅក្រមស៊ើបសួរទេ ដំណាក់កាលបន្ទាប់ច្បាស់ជាដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួន។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវឱ្យដំណឹងដល់បុគ្គល ដែលជាកម្មវត្ថុនៃដីកាដោយអាជ្ញាសាលាដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ដែលត្រូវបានប្រគល់លិខិតចម្លងឱ្យបុគ្គលពាក់ព័ន្ធបន្ទាប់ពីបុគ្គលនេះបានចុះហត្ថលេខាលើសំណៅដើម ដែលត្រូវប្រគល់ឱ្យទៅចៅក្រមស៊ើបសួរវិញ។

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវប្រគល់ទៅឱ្យមន្ត្រីនគរបាលមន្ត្រីនគរបាលយុត្តិធម៌។ ដីការទាំងនេះត្រូវផ្សព្វផ្សាយតាមគ្រប់មធ្យោបាយក្នុងករណីបន្ទាន់។ ប៉ុន្តែ

[74] ដីកាបង្គាប់ឱ្យខ្លួននៅក្នុងឧបសម្ព័ន្ធ

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងផ្ទះដែលជនពាក់ព័ន្ធស្នាក់នៅមុនម៉ោង ០៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចឡើយ។

**២.៣.២.ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ**

ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតក្រោមការពិនិត្យ ក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត[75]។

**២.៣.២.១.បុគ្គលដែលអាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ**

ចៅក្រមស៊ើបសួរ វាយតម្លៃអំពីកាលានុវត្តភាពនៃការជូនដំណឹងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យជាយថាហេតុបន្ទាប់ពីបានធ្វើការស៊ើបសួរចាំបាច់ផ្សេងៗរួចមក។

ចៅក្រមស៊ើបសួរត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិនូវការគ្មានលទ្ធភាពក្នុងការសួរយកចម្លើយលើបុគ្គលដែលមានតម្រុយពិរុទ្ធក្នុងឋានៈជាសាក្សី ដោយអនុលោមតាមមាត្រា១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការបញ្ញត្តិបែបនេះ គឺជារក្សានូវការគោរពសិទ្ធិមនុស្សដែលអាចត្រូវបំពានយ៉ាងធ្ងន់ធ្ងរដោយកិច្ចស៊ើបសួរ ដែលជាគោលការណ៍ជនត្រូវចោទមានសិទ្ធិក្នុងការពឹងពាក់មេធាវីការពារសិទ្ធិរបស់ខ្លួន។

ក្រៅពីនេះ បុគ្គលដែលត្រូវបានកំណត់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបានតែក្នុងឋានៈជាជនត្រូវចោទតែប៉ុណ្ណោះ។

**២.៣.២.២.ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ**

ការដាក់ឱ្យស្ថិតក្រោមការពិនិត្យធ្វើឡើងនៅពេលដែលជនពាក់ព័ន្ធចូលបង្ហាញខ្លួនដំបូង នៅចំពោះមុខចៅក្រមស៊ើបសួរ។

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់

[75] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។

ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬ ក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។

ក្រោយពីការចូលបង្ហាញខ្លួនលើកទី០១ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា[76]៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន
- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាធ្វើឡើងដល់សាម៉ីខ្លួនផ្ទាល់។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្តីពីការផ្លាស់ប្តូរអាសយដ្ឋាន ត្រូវចុះក្នុងកំណត់នៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ជនត្រូវចោទអាចត្រូវបានបកដោយអ្នកបកប្រែ ដែលអ្នកបកប្រែត្រូវស្បថតាមជំនឿសាសនារបស់ខ្លួន ថានឹងជួយដល់តុលាការ និងបកប្រែបានត្រឹមត្រូវតាមចម្លើយទាំងឡាយរបស់ជនត្រូវចោទ[77]។

### ២.៣.២.៣.អានុភាពនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

បុគ្គលដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យរបស់តុលាការ នោះបុគ្គលនឹងទទួលបានឋានៈជាជនត្រូវចោទ ដែលក្លាយខ្លួនទៅជាភាគីនៃសំណុំរឿងក្តីព្រហ្មទណ្ឌ។ សិទ្ធិរបស់ជនត្រូវចោទមានសិទ្ធិការពារខ្លួនដែលស្តែងឡើងតាមសិទ្ធិទទួលបាននូវជំនួយមេធាវីតាមលក្ខន្តិកៈមេធាវី សិទ្ធិចូលរួមក្នុងការពារខ្លួន ដោយឆ្លើយ ឬមិនឆ្លើយ សិទ្ធិត្រូវបានស្តាប់ដោយចៅក្រម និងមិនមែនដោយមន្ត្រីនគរបាលយុត្តិធម៌ សិទ្ធិទទួលព័ត៌មានពីសកម្មភាពខាងផ្នែកតុលាការរបស់ចៅក្រមស៊ើបសួរ សិទ្ធិមោឃនីតិវិធី សិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើការស៊ើបសួរដែលសុំទៅឱ្យចៅក្រមស៊ើបសួរធ្វើ

[76] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[77] មាត្រា ១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ការស្រាវជ្រាវមួយចំនួន។ ជាអាទ៍ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយភាគីរដ្ឋប្បវេណី ឬសាក្សី ធ្វើការសួរចម្លើយតទល់ ឬចុះទៅទីកន្លែងណាមួយ។ ការស្នើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុដែលអនុញ្ញាតឱ្យបញ្ជាក់ពីប្រយោជន៍របស់វា។

❖ **ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពត**

នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ៨៩៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពត បានដាក់ជនជាប់ចោទឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ សញ្ជាតិអូស្ត្រាលី និងជនជាប់ចោទឈ្មោះ **គ** ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្ថិតនៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ពីបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅបញ្ញត្តិក្នុងមាត្រា ៩០,៩៥ នៃច្បាប់ត្រួតពិនិត្យគ្រឿងញៀន[78]។

### ២.៣.៣.ការរក្សាជនត្រូវចោទស្ថិតក្រោមការចាត់ចែងរបស់តុលាការ

ដើម្បីធានាឱ្យបាននូវការរក្សាជនត្រូវចោទ ឱ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិនូវវិធានការសំខាន់ពីរ ដែលផ្តល់ឱ្យចៅក្រមស៊ើបសួរនូវអំណាចបង្ខំច្រើន ឬតិច គឺការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

#### ២.៣.៣.១.ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការទប់ស្កាត់មួយដែលមានចរិករឹងពឹងបំផុតនៅក្នុងនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានតុលាការ ( ចៅក្រមស៊ើបសួរនៃមន្ទីស៊ើបសួរ ឬក្រុមប្រឹក្សាជំនុំជម្រះនៃសភាស៊ើបសួរ ) អនុវត្តចំពោះជនត្រូវចោទដែលត្រូវចោទពីបទល្មើសព្រហ្មទណ្ឌ ( បទឧក្រិដ្ឋ បទមជ្ឈិម ) ណាមួយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការឃុំខ្លួនបណ្តោះអាសន្ននេះបានកាត់ផ្តាច់ទំនាក់ទំនងជនដែលត្រូវឃុំខ្លួន ពីសង្គមមួយរយៈហើយថែមទាំងបានរារាំងនូវសិទ្ធិខ្លះៗ របស់ប្រជាពលរដ្ឋដែលច្បាប់បានកំណត់។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិមវិញការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើ

[78] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងឧបសម្ព័ន្ធ

បាន លុះត្រាតែជនត្រូវចោទត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទមជ្ឈិមដែលច្បាប់កំណត់ថិរវេលានៃការផ្តន្ទាទោសដាក់ ពន្ធនាគាស្មើ ឬលើសពី ០១ឆ្នាំ។

**ក-មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានសំអាងហេតុ ដែលជាករណីពិសេស និងជាភាពចាំបាច់ដើម្បី[79]៖

១-បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

២-រារាំងកុំឱ្យមានការកៀបសង្កត់លើសាក្សី ឬជនរងគ្រោះ

៣-រារាំងកុំឱ្យមានការត្រូវរូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត

៤-រក្សាភស្តុតាង ឬតម្រុយជាសម្ភារ

៥-ការពារសន្តិសុខឱ្យជនត្រូវចោទ

៦-ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

**ខ-លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន**

ដើម្បីអនុវត្តនូវវិធាននៃការឃុំខ្លួនបណ្តោះអាសន្នបាន ត្រូវតែគោរពនូវលក្ខខណ្ឌដាច់ខាតមួយចំនួន។ ជានិច្ចកាល ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបាន លុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិមវិញការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបាន លុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទមជ្ឈិមដែលច្បាប់កំណត់ថិរវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគាស្មើ ឬលើសពី១ឆ្នាំ[80]។ រយៈពេលស្មើ ឬលើសពី ០១ឆ្នាំនេះ សំដៅដល់អតិបរមានៃទោសនីមួយៗ ដែលមានបញ្ញត្តិក្នុងច្បាប់។

យោងតាមការវិភាគលើផ្នែកទី៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ននេះ ការអនុវត្តវិធាននៃការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចអនុវត្តបានឡើយ ចំពោះករណីដូចខាងក្រោម៖

- បទល្មើសលហុ

[79] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[80] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

- បទល្មើសមជ្ឈិម ដែលមានទណ្ឌកម្មពិន័យជាប្រាក់ ឬមានទណ្ឌកម្មដាក់ពន្ធនាគារតិចជាង ០១ឆ្នាំ។
- បុគ្គលដែលរងការចោទប្រកាន់ជាអនីតិជន អាយុតិចជាង ១៤ឆ្នាំ ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ។

ការសម្រេចថានឹងត្រូវឃុំខ្លួនជនត្រូវចោទ អាចផ្ដើមដោយគំនិតផ្ទាល់ខ្លួនរបស់ចៅក្រមស៊ើបសួរ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ( យោងតាមក្រមនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចប្ដឹងសុំវិធាននេះដោយផ្ទាល់ទៅចៅក្រមស៊ើបសួរទេ ប៉ុន្តែអាចធ្វើឡើងតាមរយៈព្រះរាជអាជ្ញា ) ហើយត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ និងឱ្យមេធាវីបង្ហាញមធ្យោបាយការពារខ្លួនបើសិនជាមាន។ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែមានសំអាងហេតុដោយយោងតាមបញ្ញត្តិមាត្រា២០៥ ស្ដីពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន[81]។ យោងតាមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដែលជាបញ្ជាដល់ប្រធានពន្ធនាគារឱ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ននេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញានិងដល់ជនត្រូវចោទ។

**គ-ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

ក្នុងករណីបទឧក្រិដ្ឋវិញការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវឱ្យលើសពី ០៦ខែបានទេ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលបណ្ដោះអាសន្នបានម្ដង ០៦ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចពន្យាពេលឃុំខ្លួនបណ្ដោះអាសន្នបានតែ ០២ដងគត់[82]។

ក្នុងករណីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវលើសពី ០៤ខែបានទេ។ ប៉ុន្តែ បើពេលវេលាផុតរយៈពេលនេះចៅក្រមស៊ើបសួរ អាចពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់មិនឱ្យលើសពី ០២ខែដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននេះ មិនត្រូវលើសពីពាក់កណ្ដាលនៃ អប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[83]។

[81] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[82] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[83] មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីដោយឡែកមួយទៀត នៅពេលដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ថិរវេលានៃការឃុំខ្លួនមានរយៈពេលស្មើ ០១ឆ្នាំ ហើយអាចពន្យាពេលបាន ០២ដង ដែលម្តងៗមានរយៈពេលស្មើ ០១ឆ្នាំដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់[84]។

ការពន្យាពេល និងត្រូវបានសម្រេចបន្ទាប់ពីមានការពិភាក្សាតទល់គ្នាចំពោះមុខចៅក្រមស៊ើបសួរដែលត្រូវទទួលស្គាល់ការកត់សម្គាល់របស់ជនត្រូវចោទ និងមេធាវី។ ដីកាពន្យាពេលក៏ត្រូវមានសំអាងហេតុដូចដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧[85]។

លើសពីនេះទៅទៀតក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានចែងអំពីរបបពិសេសសម្រាប់អនីតិជនដែរ ជាក់ស្តែងអនីតិជនដែលមានអាយុតិចជាង ១៤ឆ្នាំមិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ វិធានបែបបង្ខំតែមួយគត់ដែលអាចសម្រេចដោយចៅក្រមស៊ើបសួរ ចំពោះអនីតិជនប្រភេទនេះ គឺការបញ្ជូលពួកគេទៅឱ្យអាណាព្យាបាល ឬឪពុកម្តាយ។ បើក្នុងករណីគ្មានអ្នកអាណាព្យាបាលទេ ត្រូវប្រគល់ទៅឱ្យមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ[86]។

**ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងករណីត្រូវបានគេចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានដូចខាងក្រោម[87]៖**

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០៤ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ ពី ១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០៦ខែ បានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ឆ្នាំដល់ក្រោម ១៨ឆ្នាំ។

**ក្នុងករណីបទមជ្ឈិមថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំមានដូចតទៅ[88]៖**

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០២ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ ពី ១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំ។

[84] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[85] មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[86] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[87] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[88] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

- ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ០៤ខែ បានទេ កាលណាអនីតិជនមានអាយុតិចចាប់ពី ១៦ឆ្នាំដល់ក្រោម ១៨ឆ្នាំ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដែលត្រូវអនុវត្តទាំងពីរចំណុចខាងលើនេះ គឺមិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានចែងសម្រាប់អនីតិជននោះឡើយ។

**ឃ-អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន**

អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្នប្រែប្រួលទៅតាមស្ថានភាពដែលកើតមានបន្ត ដូចជាក្នុងករណីដែលមានការផ្ដន្ទាទោសដាក់ពន្ធនាគារ ការឃុំខ្លួនបណ្ដោះអាសន្ន គឺរាប់បញ្ចូលដោយស្វ័យប្រវត្តិនៅពេលសាលក្រមស្ថាពរ។ ការចោទប្រកាន់ព្រហ្មទណ្ឌត្រូវបញ្ចប់ការផ្ដន្ទាទោសផ្សេងៗក្រៅពីការដកហូតសេរីភាពដោយការឃុំខ្លួនបណ្ដោះអាសន្នមិនអនុញ្ញាតឱ្យទូទាត់អ្វីទាំងអស់។

**២.៣.៣.២.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ**

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ ហើយការដោះលែងក៏អាចធ្វើ តាមរយៈបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ឬបណ្ដឹងសុំរបស់ជនត្រូវចោទផងដែរ។

**ក-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ**

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរត្រូវ ជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ដោយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ហើយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ( មិនត្រូវលើសពី ០៥ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿងមកពិនិត្យ )។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងមកព្រះរាជអាជ្ញា។

ប៉ុន្តែមានករណីពិសេស ដែលមានភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងភ្លាមដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញាឡើយ តែចៅក្រមស៊ើបសួរត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃភាពបន្ទាន់នោះនៅក្នុងដីកាសម្រេចរបស់ខ្លួន[89]។

**ខ-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមការប្ដឹងសុំរបស់ព្រះអាជ្ញា**

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបាន ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ០៥ថ្ងៃ។ បើសិនជារយៈពេល៥ ថ្ងៃនោះកន្លងផុតទៅ

[89] មាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ[90]។

**គ-ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយជនត្រូវចោទ**

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទ នឹងសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាម ដើម្បីពិនិត្យ និងផ្តល់យោបល់ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី ០៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណុំរឿងមកពិនិត្យ)។ ចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ប្រសិនបើរយៈពេល ០៥ថ្ងៃកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ក្នុងករណីដែលមានការបដិសេធនឹងពាក្យសុំឱ្យនៅក្រៅឃុំ ជនត្រូវចោទអាចដាក់ពាក្យសុំសារជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ០១ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ត្រូវតែសម្រេចលើពាក្យនោះក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ទទួលពាក្យសុំ[91]។

នៅក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវឱ្យនៅក្រៅឃុំ ដីកាសម្រេចនោះត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា នឹងប្រធានពន្ធនាគារបញ្ញត្តិនៃមាត្រា២៧៦ ស្តីពីការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត។

កាលណាចៅក្រមស៊ើបសួរដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា២២៣ ដល់មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[92]។

**២.៣.៣.៣.ការត្រួតពិនិត្យតាមផ្លូវតុលាការ**

តាមក្រមនីតិវិធីព្រហ្មទណ្ឌមិនបានឱ្យនិយមន័យការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ប៉ុន្តែយើងអាចកំណត់បានថា វាជាវិធានការនិរន្តរាយមួយ ដូចករណីនៃការឃុំខ្លួនបណ្តោះអាសន្នដែរ

[90] មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[91] មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[92] មាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

គ្រាន់តែវាជាវិធានមួយដែលមានស្ថានភាពស្រាលជាង។ ចៅក្រមស៊ើបសួរបង្គាប់ជនត្រូវចោទ ដែលនៅក្រៅឃុំ ឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម[93]៖

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២-មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦-ប្រគល់ជូនដល់ការិយាល័យប្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧-មិនត្រូវបើកបររថយន្ត

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ដើម្បីអនុវត្តចំណុចទី១២ ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវសិទ្ធិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។

ដើម្បីអនុវត្តនូវវិធាននេះបានត្រូវគោរពលក្ខខណ្ឌពីរ៖

១-ជនត្រូវចោទមានអាយុចាប់ ១៨ឆ្នាំ ឡើងទៅ

២-ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

[93] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ស្របនឹងខ្លឹមសារនេះយើងអាចកំណត់បានថា ជនសង្ស័យដែលជាប់ពាក់ព័ន្ធនឹងបទល្មើសដែលមានអាយុក្រោម ១៨ឆ្នាំ និងទណ្ឌកម្មពិន័យជាប្រាក់សុទ្ធសាធមិនអាចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវ តុលាការបានឡើយ។

ចៅក្រមស៊ើបសួរអាចអនុវត្តនូវវិធានតាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ដីកាសម្រេចនេះត្រូវជូនដំណឹងរយៈពេលយ៉ាងខ្លីដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរ បដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញាអំពីការដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចក្នុងរយៈពេល ០៥ថ្ងៃ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលយ៉ាងខ្លីបំផុត។ បើសិនជារយៈពេល ០៥ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ[94]។

**ក-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[95]។

**ខ-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ០៥ថ្ងៃ។ បើសិនជារយៈពេល ០៥ ថ្ងៃនោះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញា ត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា[96]។

**គ-ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ**

ជនត្រូវចោទអាចពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនោះ និងសំណុំរឿងទៅព្រះរាជ-

[94] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[95] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[96] មាត្រា ២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

អាជ្ញាភ្លាម ដើម្បីពិនិត្យនឹងផ្តល់យោបល់។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទ។

កាលណាមានពាក្យសុំលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ០៥ថ្ងៃ នេះត្រូវចាប់ផ្តើមគិតពីពេលចេញសេចក្តីលើពាក្យសុំពីមុន។ ដីកាដែលសម្រេចមិនព្រមតាមគោលការណ៍ពាក្យសុំត្រូវតែមានសំអាងហេតុ។

ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ០៥ថ្ងៃនេះទេ ជនត្រូវចោទអាចធ្វើពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[97]។

**ឃ-ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ប្រសិនបើជនត្រូវចោទ បានគេចវេសដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ទោះក្នុងករណីដែលៈ

• ទោសជាប់ពន្ធនាគារដែលត្រូវរងនោះ មានថិរវេលាប៉ុន្មានក៏ដោយ ( មានន័យថាលក្ខខណ្ឌនៃមាត្រា២០៤ លែងជាឧបសគ្គនៃការឃុំខ្លួនបណ្តោះអាសន្នទៀតហើយ )។

• ជនត្រូវចោទ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមមាត្រា២០៨,២០៩,២១៣,និង២១៤ ក៏ដោយ។

កាលណាសម្រេចថា នឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ ហើយត្រូវឱ្យមេធាវីជូនមធ្យោបាយការពារ បើសិនជាមានមេធាវីអមផងនោះ។

ដីកាសម្រេចត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ មិនអាចឱ្យលើសពី ០៤ខែ ចំពោះនីតិជន និងមិនអាចលើសពី ០២ខែ ចំពោះអនីតិជនឡើយ។

ការត្រួតពិនិត្យតាមផ្លូវការ ត្រូវបានបញ្ចប់នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការនោះទេ[98]។

[97] មាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[98] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់នៅដែលតុលាការប្រកាសសាលក្រមដែរ[99]។

❖ **ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពត**

យោងតាមសំណុំរឿងលេខ:៨៩៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ ដីកាស៊ើបសួរលេខ:៥៣៤ ចុះថ្ងៃទី១៨ ខែធ្នូ ២០១៧ ចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នចំពោះឈ្មោះ **ខ** និង **គ** ដើម្បីរារាំងកុំឱ្យកៀបសង្កត់លើសាក្សី និងមានការត្រូវរូវរវាងជនត្រូវចោទ និងអ្នកផ្សំគំនិត។ ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។ ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។ ដោយសារមិនមានវិធានការត្រួតពិនិត្យ តាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងអាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនៅគោលការណ៍ខាងលើ[100]។

មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ ជនជាតិអូស្ត្រាលី និងឈ្មោះ **គ** ភេទស្រី អាយុ២៨ ឆ្នាំ បានស្នើសុំឱ្យដោះលែងកូនក្តីរបស់ខ្លួនឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយកូនក្តីរបស់ខ្ញុំមិនបានបង្កហេតុអ្វីទាំងអស់ដល់សមត្ថកិច្ច ឬទៅគំរាមកំហែងសាក្សី ឬរារាំងការស៊ើបសួររបស់តុលាការ ឬបង្កបញ្ហាលំបាកក្នុងការស៊ើបសួររបស់តុលាការ។ សូមលោកចៅក្រមមេត្តាសម្រេចអនុញ្ញាតិឱ្យកូន ក្តីខ្ញុំបាទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ជាពិសេសកូនក្តីខ្ញុំបាទបានសុំដាក់ប្រាក់តម្កល់ ចំនួន ១០.០០០.០០០ រៀល ដើម្បីធានានីតិវិធីរបស់ការស៊ើបសួររបស់តុលាការ[101]។

ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពតមិនអនុញ្ញាតិឱ្យឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ ជនជាតិអូស្ត្រាលី និងឈ្មោះ **គ** ភេទស្រី អាយុ២៨ ឆ្នាំ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នទេ[102]។

[99] មាត្រា ៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[100] ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ននៅក្នុងឧសម្ព័ន្ធ

[101] ពាក្យសុំកូនក្តីឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅក្នុងឧបសម្ព័ន្ធ

[102] ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅក្នុងឧបសម្ព័ន្ធ

### ២.៣.៤.អំណាចនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

#### ២.៣.៤.១.អំណាចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[103]។

ដូចនេះ មានន័យថា ចៅក្រមស៊ើបសួរដឹកនាំដោយសេរី និងឯករាជ្យកិច្ចស៊ើបសួររបស់ខ្លួន និងមិនទទួលអធិបញ្ញាពីភាគី ឬអាជ្ញាធរណាមួយឡើយ។

កិច្ចការស្រាវជ្រាវដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ មិនមានសភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលយុត្តិធម៌។

**ក-ការសួរចម្លើយជនត្រូវចោទ**

ជនត្រូវចោទដែលត្រូវបានបង្ហាញខ្លួនដំបូងនៅសាលាដំបូងនៃយុត្តាធិការស៊ើបសួរ ជនត្រូវចោទមានសិទ្ធិក្នុងការជ្រើសតាំងមេធាវីដោយខ្លួនឯង ឬដោយការចាត់តាំងរបស់ប្រធានសាលាដំបូងស្របតាមលក្ខន្តិកៈមេធាវី។

ជនត្រូវចោទដែលមានមេធាវី ចៅក្រមស៊ើបសួរទៅធ្វើការកោះហៅមេធាវីយ៉ាងតិចបំផុត ០៥ ថ្ងៃមុនពេលសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធីបាន។ ជនត្រូវចោទអាចត្រូវបានចៅក្រមស៊ើបសួរសួរយកចម្លើយបានតែចំពោះមុខមេធាវី ការពារសិទ្ធិរបស់ជនត្រូវចោទតែប៉ុណ្ណោះ។ ប៉ុន្តែបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរ អាចសួរយកចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវីបាន។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរក៏អាចយកចម្លើយជនត្រូវចោទបានផងដែរ ប្រសិនបើជនត្រូវចោទបានបោះបង់នូវសិទ្ធិការពារខ្លួន ឬបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួននោះ។ ការបោះបង់ចោលនេះត្រូវចុះក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានផងដែរ ដែលភាពបន្ទាន់បណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់

[103] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ជនត្រូវចោទអាចត្រូវអមដោយអ្នកបកប្រែ ឬត្រូវបានប្រធានសាលាដំបូងចាត់តាំងអ្នកបកប្រែឱ្យផងដែរ[104]។

ព្រះរាជអាជ្ញាត្រូវបានអញ្ជើញឱ្យចូលរួម ក្នុងនីតិវិធីនៃការសួរយកចម្លើយជនចោទផងដែ។ ក្នុងករណីដែលព្រះរាជអាជ្ញាបានចូលរួមក្នុងនីតិវិធីនៃការសួរយកចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីរបស់ជនត្រូវចោទ អាចតាំងសំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ហើយក្នុងករណីមិនត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរទេ ហេតុនេះត្រូវចុះក្នុងនិទ្ទេសនៃកំណត់ហេតុ[105]។

❖ **ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពត**

នៅក្នុងសំណុំរឿងលេខ ៨៩៥ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបង្ហាញខ្លួនជនជាប់ចោទឈ្មោះ **ខ** ភេទប្រុស អាយុ ៧២ឆ្នាំ សញ្ជាតិអូស្ត្រាលី និងជនជាប់ចោទ ឈ្មោះ **គ** ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ នៅចំពោះមុខមន្ទីរស៊ើបសួរចោទពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០,៤៥ នៃច្បាប់ត្រួតពិនិត្យគ្រឿងញៀន។

ឈ្មោះ **ខ** បានឆ្លើយ នៅចំពោះមុខចៅក្រមស៊ើបសួរថា ខ្ញុំបាទបានដឹងពីការចោទប្រកាន់គឺបទ ជួញដូរ និងប្រើប្រាស់។ ខ្ញុំបាទមិនបានជួញដូរគ្រឿងញៀនដូចការចោទប្រកាន់នោះទេ គឺខ្ញុំគ្រាន់តែប្រើប្រាស់ប៉ុណ្ណោះ។ មូលហេតុខ្ញុំទិញថ្នាំញៀនច្រើននេះ ពីព្រោះការទិញច្រើនវាមានតំលៃថោក ជាងការទិញតិច។ ខ្ញុំទិញនៅភ្នំពេញ ទិញម្តងអស់ទឹកប្រាក់ ២៥០ ដុល្លារ ទៅ៣០០ដុល្លារ ទម្ងន់ ១១ក្រាម។ ក្រោយពីទិញមក ខ្ញុំបានបំបែកជាកញ្ចប់តូចៗ មិនទុកសម្រាប់ចែកចាយទេ។ ខ្ញុំប្រើប្រាស់ថ្នាំញៀននេះតែពីរនាក់ឈ្មោះ **គ** តែប៉ុណ្ណោះ និងពេលខ្លះប្រើជាមួយសង្សារផ្សេងទៀត។ ខ្ញុំសុំរក្សាចម្លើយដែលបានឆ្លើយនៅអយ្យការ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង។ ចំពោះរបាយការណ៍នៅស្នងការដ្ឋាននគរបាល ដែលធ្វើមកនេះគឺមានភាពមិនត្រឹមត្រូវទេ។

ឈ្មោះ **គ** បានឆ្លើយ នៅចំពោះមុខចៅក្រមស៊ើបសួរថា នាងខ្ញុំបាទបានដឹងពីការចោទប្រកាន់គឺបទ ជួញដូរ និងប្រើប្រាស់។ នាងខ្ញុំមិនបានជួញដូរគ្រឿងញៀនដូចការចោទប្រកាន់នោះទេ គឺនាងខ្ញុំគ្រាន់តែប្រើប្រាស់ប៉ុណ្ណោះ។ នាងខ្ញុំសុំរក្សាចម្លើយដែលបានឆ្លើយនៅអយ្យការ កាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង។ នាងខ្ញុំពិតជាមិនបានជួញដូរគ្រឿងញៀនទេ គឺគ្រាន់តែបានប្រើប្រាស់គ្រឿងញៀន។ ក្នុងរឿងនេះ នាងខ្ញុំសុំឱ្យតុលាការកុំឃុំខ្លួនខ្ញុំ ពីព្រោះនាងខ្ញុំ

[104] មាត្រា ១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[105] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

មានជំងឺប្រចាំកាយ ម្យ៉ាងទៀត គ្មានអ្នកណារកស៊ីចិញ្ចឹមគ្រួសារ នាងខ្ញុំ និងប្តីបានប្រើប្រាស់ថ្នាំញៀនជារៀងរាល់ថ្ងៃ ហើយបានប្រើប្រាស់រយៈពេល ០៣ឆ្នាំមកហើយ ។ ជនជាប់ចោទទាំងពីរបានជ្រើសរើសមេធាវីដោយខ្លួនឯង[106]។

**ខ-ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី**

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃការស៊ើបសួរ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលជំនួយពីមេធាវីក្នុងពេលកំពុងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ ដូច្នេះមេធាវីត្រូវទទួលការកោះហៅក្នុងចិរវេលា ៥ថ្ងៃ មុនការស្តាប់ចម្លើយ មានសិទ្ធិពិនិត្យមើលសំណុំរឿងក្នុងចិរវេលានេះ និងអាចទទួលបាននូវឯកសារចម្លង និងលិខិតផ្សេងៗនៃនីតិវិធី ដោយចេញសោហ៊ុយខ្លួនឯង ដោយមានការអនុញ្ញាតពីចៅក្រម។ ការស្តាប់ចម្លើយអាចធ្វើដោយពុំចាំបាច់មានវត្តមានរបស់មេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីរបស់ខ្លួន និងពុំចាំបាច់កោះហៅមេធាវីក្នុងករណីបន្ទាន់ ( គ្រោះថ្នាក់ដល់អាយុជីវិត ហានិភ័យនៃការបាត់បង់តម្រុយភស្តុតាង )[107]។

ចំពោះបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃការចោទប្រកាន់ និងអាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ដល់ការបង្ហាញការពិតទៅចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរអាចកោះហៅបុគ្គលទាំងនោះមកសាកសួរជាសាក្សី។

សាក្សីមានកាតព្វកិច្ច ០៣យ៉ាង ចូលមកបង្ហាញខ្លួន ធ្វើពាក្យសម្បថ ( ត្រូវរួចផុតពីសម្បថបុគ្គលដែលជិតស្និទ្ធជាមួយជនត្រូវចោទ ដូចជាបុព្វញាតិ បច្ឆាញាតិ បងប្អូន សហព័ទ្ធ និងកូនដែលមានអាយុចាប់ពី ១៦ឡើងទៅ ) និងផ្តល់ចម្លើយ[108]។ សាក្សីបដិសេធមិនបង្ហាញខ្លួន ចៅក្រមស៊ើបសួរសុំឱ្យកម្លាំងសាធារណៈបង្ខំសាក្សីឱ្យចូលមកបង្ហាញខ្លួន ដោយចេញបញ្ជាឱ្យចូលបង្ហាញខ្លួនដែលមានចុះពីអត្តសញ្ញាណរបស់សាក្សី កាលបរិច្ឆេទចេញ បញ្ជាហត្ថលេខា និងត្រារបស់ចៅក្រម[109]។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចកោះហៅអ្នកបកប្រែដើម្បីស្តាប់សាក្សី[110]។

[106] កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងនៅក្នុងឧបសម្ព័ន្ធ

[107] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទ៦ ខសីហា ឆ្នា២០០៧

[108] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[109] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[110] មាត្រា ១៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

បើសាក្សីមានជំងឺ ឬមិនអាចធ្វើដំណើរមកបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចទៅកាន់ផ្ទះរបស់សាក្សី ឬកន្លែងដែលសាក្សីនោះនៅដើម្បីទទួលយកចម្លើយ[111]។

សាក្សីមិនមែនជាភាគីនៃការស៊ើបសួរ គាត់មិនទទួលបាននូវសិទ្ធិការពារខ្លួន ដូច្នេះសាក្សីត្រូវបានស្តាប់ចម្លើយតែម្នាក់ឯង ដោយចៅក្រមស៊ើបសួរ។ ប៉ុន្តែគាត់អាចជាកម្មវត្ថុនៃការសួរតទល់គ្នាជាមួយនឹងភាគីក្នុងសំណុំរឿង។

**គ-ការសួរតទល់**

ការសួរតទល់គ្នាអាចឱ្យនិយមន័យបានថាជាការសួរចម្លើយ ឬការស្តាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅធ្វើឱ្យលេចចេញនូវធាតុនៃការពិត តាមរយៈយោបល់ និងជំហររបស់បុគ្គលម្នាក់ៗដែលចៅក្រមដាក់តទល់គ្នានោះ។ បទបញ្ញត្តិដែលគ្រប់គ្រងការសួរចម្លើយជនត្រូវចោទត្រូវយកមកអនុវត្ត។

**ឃ-ការចុះដល់ទីកន្លែងកើតហេតុ**

ដើម្បីបំពេញគ្រប់កិច្ចស៊ើបសួរ ចៅក្រមអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពនៃ សមត្ថកិច្ចដែនដីរបស់សាលាដំបូងដើម្បីបំពេញកិច្ច ស៊ើបសួរដែលខ្លួន យល់ឃើញថាមានប្រយោជន៍។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដែលអាចចូលរួមដំណើរជាមួយខ្លួនបាន។ ក្រឡាបញ្ជីជាជំនួយក្នុងការចុះដល់ទីកន្លែងចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីការចុះដល់ទីកន្លែង និងស្តីពីកិច្ចដែលបានបំពេញនៅនឹងកន្លែង។

ម្យ៉ាងទៀត បើការចាំបាច់នៃការស៊ើបសួរតម្រូវ ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយនឹងក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូល ដោយជូនដំណឹងជាមុនទៅព្រះរាជអាជ្ញាអមសាលាដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ[112]។

**ខ-ការឆែកឆេរ**

មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ផ្ទុយពីគំនិតដែលទទួលបានជារួម ការស៊ើបសួរមិនអនុញ្ញាតឱ្យធ្វើការឆែកឆេរគ្រប់កន្លែង ដោយពុំមានលក្ខខណ្ឌដូចក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងនោះទេ។

ក្នុងក្របខណ្ឌនៃការស៊ើបសួរ ការឆែកឆេរត្រូវគោរពតាមម៉ោងដែលច្បាប់កំណត់ដូចមានចែងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង។ គោលការណ៍នេះត្រូវបានលើកលែងក្នុងករណីឆែកឆេរ

[111] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[112] មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

កន្លែងបើកឱ្យសាធារណៈជន កន្លែងដែលបុគ្គលប្រព្រឹត្តពេស្យាកម្ម និងកន្លែងលក់ ឬប្រើប្រាស់គ្រឿងញៀន។

ដូចគ្នានេះដែរ ការឆែកឆេរការិយាល័យមេធាវីត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។

អ្នកកាន់កាប់ទីកន្លែងត្រូវមានវត្តមាន ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវមានសាក្សីពីនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសាក្សីនោះមិនអាចជាអារុធហត្ថ ឬនគរបាល។

ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ដែលត្រូវមានចុះហត្ថលេខាអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ និងជាយថាហេតុ អត្តសញ្ញាណរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។ ជាចុងក្រោយកំណត់ហេតុនេះត្រូវមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី[113]។

**ច-ការចាប់យកវត្ថុតាង**

ច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរចាប់យកវត្ថុតាង និងបិទស្លាកបោះត្រា លើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលបានចាប់យកដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី ០២ (ពីរ) នាក់ រួចមក ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់ ដែលរួមមានបញ្ជីសារពើភណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្ដីពីការចាប់ ត្រូវមានចុះហត្ថលេខា ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ០២ (ពីរ) នាក់[114]។

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ចៅក្រមស៊ើបសួរមានអំណាចប្រគល់វត្ថុដែលចាប់យកនោះវិញ។ ចៅក្រមស៊ើបសួរអាចធ្វើដោយឯកឯង បន្ទាប់ពីមានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬពីគ្រប់បុគ្គលទាំងអស់ដែលអះអាងថាមានសិទ្ធិលើវត្ថុដែលចាប់។ គាត់អាចបដិសេធប្រគល់សងវត្ថុចាប់យក នៅពេលដែលការប្រគល់សងជាឧបសគ្គដល់ការសម្ដែងឱ្យឃើញការពិត វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលកាន់កាប់មិនស្របច្បាប់ ចៅក្រមស៊ើបសួរមិនត្រូវប្រគល់សងឱ្យសាម៉ីខ្លួនវិញទេ វត្ថុទាំងនោះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ[115]។

[113] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[114] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[115] មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

**ឆ-កោសល្យវិច័យ**

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសល្យវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។

កាលណាចៅក្រមស៊ើបសួរ បដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ០៥ថ្ងៃប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង០១ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំបន្ទាន់[116]។

កាលណាចៅក្រមស៊ើបសួរ បដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសល្យវិច័យបន្ថែម ឬប្រតិកោសល្យវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ០៥ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង០១ខែប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំបន្ទាន់[117]។

**ជ-ការស្តាប់ទូរស័ព្ទ**

គឺជាការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារហ្វាក់ ឬសារអេឡិចត្រូនិចជាដើម។ មានតែចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្តឹងដោយស្របច្បាប់តែប៉ុណ្ណោះ ដែលមានអំណាចបញ្ជាឱ្យមានការចាប់ថត និងការចម្លងមកជាអក្សរនៃការឆ្លើយឆ្លងគ្នាតាមមធ្យោបានទូរគមនាគមន៍។ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងដែលធ្វើការចាប់ និងការថតនោះ។ ប៉ុន្តែ វិធានស៊ើបសួរនេះត្រូវតែចាំបាច់ដើម្បីបង្ហាញការពិត និងត្រូវមានគ្រប់ធាតុនៃការកំណត់អត្តសញ្ញាណនៃការទាក់ទងដែលចាប់បទល្មើសដែលជាមូលហេតុនាំឱ្យមានការចាប់ និងថិរវេលានៃការចាប់នេះ។ សេចក្តីសម្រេចនៃការចាប់បើកផ្លូវតវ៉ា។

ចៅក្រមស៊ើបសួរក៏អាចកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ[118]។

[116] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[117] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[118] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

**២.៣.៤.២.ការផ្ទេរអំណាច ឬដីកាចាត់ឱ្យស៊ើបសួរជំនួស**

ដីកាចាត់ឱ្យស៊ើបសួរជំនួសអាចឱ្យនិយមន័យបានថា ជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឱ្យទៅចៅក្រមផ្សេង ឬមន្រ្តីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាល ដើម្បីអនុវត្តកិច្ចស៊ើបសួរមួយ ឬច្រើនដែលចៅក្រមស៊ើបសួរកំណត់[119]។

ដោយមានន័យថាជាប្រតិភូកម្មអំណាច ដីកាចាត់ឱ្យស៊ើបសួរជំនួសអាចចេញតែដើម្បីផ្ទេរអំណាចដែលចៅក្រមមានប៉ុណ្ណោះ។ ដីកាចាត់ឱ្យសួរសាក្សីក៏ត្រូវគ្រប់គ្រងដោយគោលការណ៍មួយដែលចែងថា ដីកាមិនអាចមានលក្ខណៈទូទៅទេ។ ព្រោះថាក្នុងករណីនេះ គឺវាដោះបន្ទុកចៅក្រមស៊ើបសួរពីសំណុំរឿងក្តី។ ចៅក្រមអាចបញ្ឈប់ដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា និងមុនពេលដែលការអនុវត្តដីកានេះត្រូវបញ្ចប់។

ដីកាចាត់ឱ្យស៊ើបសួរជំនួសដែលត្រូវតែពិសេសសជាដាច់ខាត ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់នូវកិច្ចដែលអនុញ្ញាត ព្រមទាំងថិរវេលានៃកិច្ចទាំងនេះ។ កិច្ចដែលសុំឱ្យធ្វើត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាត្រូវតែមានចុះកាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់ចៅក្រម[120]។

ការភ្លេចនិទ្ទេសមួយក្នុងចំណោមនិទ្ទេសទាំងអស់នេះ អាចបណ្តាលឱ្យមានមោឃភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួស និងមោឃភាពនៃគ្រប់កិច្ចដែលបានធ្វើបន្តបន្ទាប់។

នៅពេលដែលដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឱ្យចៅក្រម ចៅក្រមរូបនេះមានគ្រប់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[121]។

ក្នុងចំណោមនគរបាល និងអាវុធហត្ថ មានតែមន្រ្តីនគរបាលយុត្តិធម៌ប៉ុណ្ណោះ ដែលអាចទទួលការផ្ទេរបែបនេះ។ ចៅក្រមស៊ើបសួរអាចចាត់តាំងមន្រ្តីនគរបាលយុត្តិធម៌ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនព្រមទាំងគ្រប់មន្រ្តីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល។ មន្រ្តីនគរបាលនេះស្ថិតនៅក្រោមអំណាចផ្ទាល់របស់ចៅក្រមស៊ើបសួរ ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចរបស់ខ្លួនបានទេ។ អំណាចដែលមិនអាចត្រូវបានផ្ទេរទៅឱ្យមន្រ្តីនគរបាលយុត្តិធម៌ គឺជាអំណាចចោទប្រកាន់បុគ្គលណាម្នាក់ អំណាចសួរចម្លើយជន

[119] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[120] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧
[121] មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណាចសួរតទល់បុគ្គលខាងលើជាមួយមនុស្សផ្សេងទៀត ឬអំណាចចេញដីកា ឬធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ។

អំណាចដែលអាចផ្ទេរបានគឺៈ

- ស្តាប់ចម្លើយសាក្សី បើក្នុងពេលស្តាប់ចម្លើយ មានលេចចេញនូវតម្រុយពិរុទ្ធភាពប្រឆាំងនឹងសាក្សីការស្តាប់ចម្លើយត្រូវបញ្ចប់ ដើម្បីឱ្យមន្ត្រីនគរបាលផ្តល់ដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។
- ការឆែកឆេរ និងការចាប់វត្ថុ ដោយគោរពលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៥៩ និង១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបសួរអង្កេតតាមផ្លូវតុលាការត្រូវធ្វើដោយចៅក្រមស៊ើបសួរនៅពេលឃាត់ខ្លួនក្នុងក្របខណ្ឌនៃការចាត់ឱ្យស៊ើបសួរជំនួស។
- ការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ នឹងការចាប់ការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍។

ជាការពិតណាស់ ត្រូវធ្វើកំណត់ហេតុស្តីអំពីគ្រប់កិច្ចដែលបំពេញដោយអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលត្រូវប្រគល់ឱ្យចៅក្រមស៊ើបសួរដើម្បីបញ្ចូនក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវបានបំពេញចប់។

### ២.៣.៤.៣.មោឃភាពកិច្ចស៊ើបសួរ

មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពលិខិតនៃនីតិវិធី ប៉ុន្តែការធ្វើមោឃកម្មចំពោះកិច្ច[122] ឬនីតិវិធីណាមួយចំពោះនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម និងនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជាសមត្ថកិច្ចរបស់តុលាការជាន់ដំបូងមាត្រា៣៨២ និងមាត្រា៤៩៣។

ការស្នើសុំធ្វើមោឃកម្មចំពោះកិច្ចនីតិវិធីស៊ើបសួរ ធ្វើបានតែមុនយុត្តាធិការជំនុំជម្រះប៉ុណ្ណោះ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុនដោយគ្មានមោឃភាពនីតិវិធីណាមួយ អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ[123]។

[122] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[123] មាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ដីកាដែលអាចធ្វើបណ្ដឹងឧទ្ធរណ៍បាន មិនអាចជាកម្មវត្ថុនៃការសុំធ្វើមោឃកម្មបានទេ។ តាមមាត្រា២៥៣ កថាខណ្ឌ៦ បានកំណត់ថា « **ដីកាដែលអាចត្រូវប្ដឹងឧទ្ធរណ៍បាន មិនអាចជាកម្មវត្ថុនៃបណ្ដឹងសុំមោឃភាពបានឡើយ** »។

វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោមនេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំនោះទេ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី៖

១-មាត្រា១២២ ( ការបើកការស៊ើបសួរត្រូវតែធ្វើចំពោះបទឧក្រិដ្ឋ )

២-មាត្រា១២៣ ( សមត្ថកិច្ចដែនដីចៅក្រមស៊ើបសួរ )

៣-កថាខណ្ឌទី០៣ នៃមាត្រា១២៤ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ

៤-កថាខណ្ឌទី០១ និងទី០២ នៃមាត្រា១២៥។

- ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ។
- បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីដែលលេចឡើងនោះឡើយ។

៥-មាត្រា១២៨៖ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីអមជានិច្ច។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជី មិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។

បន្ថែមលើចំណុចខាងលើនេះ ការដែលនាំឱ្យមានមោឃភាព កាលណាការបំពានវិធាន ឬទម្រង់ការ សំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះ មានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន[124]។

**ក-អ្នកដែលមានសិទ្ធិសុំមោឃភាពក្នុងកិច្ចនីតិវិធី**

១-ចៅក្រមស៊ើបសួរ អាចប្ដឹងទៅសភាស៊ើបសួរតាមដីកាដែលមានសំអាងហេតុ និងជូនដំណឹងដល់ព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី

[124] មាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

២-ព្រះរាជអាជ្ញា អាចធ្វើពាក្យសុំដោយមានសំអាងហេតុបញ្ជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅចៅក្រមស៊ើបសួរ

៣-ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើពាក្យសុំដោយមានសំអាងហេតុ ជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅចៅក្រមស៊ើបសួរ ពាក្យសុំនេះ អាចធ្វើដោយមេធាវីបាន។

ពាក្យសុំឱ្យធ្វើមោឃកម្ម ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ភ្លាមនោះ ក្រឡាបញ្ជីសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឱ្យខ្លួនភ្លាម[125]។

កាលណាមានការលះបង់នូវការបំពានវិធាន ឬទម្រង់ការសំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួននៃភាគីណាមួយ វាមានអានុភាពកែប្រែនីតិវិធីនេះឱ្យមានភាពប្រក្រតីឡើងវិញ ការលះបង់នេះ ត្រូវធ្វើការពិនិត្យដោយចៅក្រមស៊ើបសួរនៅក្នុងកំណត់ហេតុ។ បើមានមេធាវីត្រូវកោះហៅមេធាវីយ៉ាងតិច ០៥ថ្ងៃ មុនកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ[126]។

បណ្តឹងសុំមោឃភាពកិច្ចនីតិវិធី ពុំមានអានុភាពបង្អាក់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរឡើយលើកលែងតែមានសេចក្តីផ្ទុយរបស់ប្រធានសភាស៊ើបសួរ [127]។

**ខ-ភាពដែលមិនអាចទទួលយកបាននៃពាក្យសុំមោឃភាព**

១-ពាក្យប្តឹងសុំគ្មានសំអាងហេតុ ( ផ្ទុយនឹងមាត្រា២៥៣ កថាខណ្ឌទី២,៣ និងទី៤ )

២-ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍ ( មាត្រា២៥៣ កថាខណ្ឌទី៦ )

៣-ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង។

សេចក្តីសម្រេចប្រកាសមិនទទួលពាក្យសុំរបស់សភាស៊ើបសួរមិនអាចតវ៉ាបាន[128]។

អានុភាពនៃការធ្វើមោឃកម្ម កាលណាបានទទួលបណ្តឹងមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យសុំ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរ ឬទេ ហើយកិច្ច និងលិខិតដែលត្រូវធ្វើមោឃកម្មទាំងនោះ ត្រូវដកចេញពីសំណុំរឿង ដោយត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[129]។

---

[125] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[126] មាត្រា ២៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[127] មាត្រា ២៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[128] មាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

[129] មាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

ក្រោយពីបានធ្វើមោឃកម្មរួចហើយ សភាស៊ើបសួរអាច[130]៖

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ឬ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត
- បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ។

ក្នុងករណីចុងក្រោយនេះ សភាស៊ើបសួរអាចប្រគល់ភារកិច្ចទៅសមាជិកខ្លួនម្នាក់ ដែលត្រូវប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែការបិទការស៊ើបសួរ ដែលត្រូវបើកសវនាការចេញសាលដីកាដំណោះស្រាយ ដោយអនុវត្តតាមមាត្រា២៥៩ ( ការពិគ្រោះសំណុំរឿង និងសារណា ) និងមាត្រា២៤៧ ( ដីកាដំណោះស្រាយ ) ដល់មាត្រា២៥០ ( ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ )។ ក្នុងករណីដែលសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនោះត្រូវមានអានុភាពអនុវត្តភ្លាម ឯបទប្បញ្ញត្តិនៃមាត្រា២៧៦ ( ការដោះលែងឱ្យមានសេរីភាព ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តនោះទេ ( មាត្រា២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )[១១៥]។ បានសេចក្តីថា ជនត្រូវចោទត្រូវបានដោះលែងភ្លាមៗ ដោយមិនចាំបាច់រង់ចាំរហូតទាល់តែផុតរយៈពេលនៃបណ្តឹងរបស់ព្រះរាជអាជ្ញានោះឡើយ ហើយក៏គ្មានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ដែលមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចនេះដែរ។

[130] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ

## ផ្នែកទី១ បញ្ហាប្រឈម នៃនីតិវិធីស៊ើបអង្កេត និងការស៊ើបសួរ

### ១.១.បញ្ហាប្រឈមនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

#### ១.១.១.ការធ្វេសប្រហែសគួបផ្សំនឹងការខ្វះសម្ភារ និងមធ្យោបាយ

ការធ្វេសប្រហែសរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយមានភាពមិនច្បាស់លាស់ក្នុងការកំណត់បទល្មើសជាក់ស្តែង ជាមួយបទល្មើសមិនជាក់ស្តែង។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង ផ្ទុយទៅវិញកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសមិនជាក់ស្តែង អ្វីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើទាំងអស់ត្រូវទុកជាកម្មវត្ថុនៃការស្នើសុំមោឃភាព[131]។

ការងាមួយចំនួនអសកម្ម ដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានសភាពការណ៍កើតឡើង។

ការចាត់តាំងអនុវត្តរបស់អង្គភាពពាក់ព័ន្ធនៅមានការយឺតយ៉ាវ ខ្វះការទទួលខុសត្រូវ គួបផ្សំនឹងការមិនបានត្រួតពិនិត្យសកម្មភាពការងាររបស់មន្ត្រីថ្នាក់ក្រោមឱ្យបានត្រឹមត្រូវនោះ ធ្វើឱ្យប្រសិទ្ធភាពនៃការអនុវត្តផែនការ មិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។

ការងារស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស ការគ្រប់គ្រងមុខសញ្ញានៅក្នុងមូលដ្ឋានដូចជាមុខសញ្ញាក្មេងទំនើង ប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញាសេសសល់ មុខសញ្ញាករណីតស៊ូ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។

ខ្វះមធ្យោបាយ សម្ភារ ថវិកា ដើម្បីបម្រើឱ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឱ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា ប៉ុន្តែពេលខ្លះមានមធ្យោបាយខ្វះប្រេង អាគុយខូចជាដើម។

#### ១.១.២.មន្ត្រីនគរបាលយុត្តិធម៌មានអាណាព្យាបាលពីរ

នៅក្នុងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ នៅក្នុងការបំពេញបេសកកម្ម មន្ត្រីនគរបាលយុត្តិធម៌ទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការរហូតដល់ចប់កិច្ចប្រតិបត្តិការខ្លួន។ ទន្ទឹមនឹងនោះមន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវរាយការណ៍តាមឋានានុក្រម ដល់

[131] មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

មេកើយខ្លួន អំពីរឿងហេតុកើតឡើងនិងសុំយោបល់អ្នកដឹកនាំ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានអាណាព្យាបាលពីរ ទីមួយតាមឋានានុក្រមការងាររដ្ឋបាលស្ថិតក្រោមការត្រួតរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ និងទីពីរការងារនីតិវិធីព្រហ្មទណ្ឌ ស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញា។

**១.១.៣.សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ**

គោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៦០ បានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីនៃកងរាជអាវុធហត្ថ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ មន្ត្រីនគរបាល មន្ត្រីកងរាជអាវុធហត្ថចុះដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សីមន្ត្រីកងរាជអាវុធហត្ថចុះដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សីជនរងគ្រោះ ស្រង់ចម្លើយជនសង្ស័យ ព្រមទាំងឃាត់ខ្លួនជនសង្ស័យ និងធ្វើការឆែកឆេររហូតដល់ចប់កិច្ចប្រតិបត្តិការរៀងៗខ្លួន។ គ្រប់បេសសកម្មរបស់អង្គភាពទាំងពីរ មានគោលដៅរួម មានគោលបំណងតែមួយដើម្បីការពារផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិ អាយុជីវិត មិនចាំបាច់ឱ្យគាត់បំពេញភារកិច្ចជាន់គ្នានាំឱ្យខាងបង់ពេលវេលា បាត់បង់ថវិកាជាតិ។

**១.២.បញ្ហាប្រឈមនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ**

**១.២.១.ការធ្វេសប្រហែស និងភាពយឺតយ៉ាវ**

ជាគោលការណ៍ចៅក្រមស៊ើបសួរ មានតួនាទីស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា ពេលនោះចៅក្រមស៊ើបសួរមានសិទ្ធិស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាចៅក្រមស៊ើបសួរពុំបានចុះទៅដល់ទីកន្លែងនៃកន្លែងកើតហេតុក្នុងការស៊ើបសួរនៅ បទល្មើសព្រហ្មទណ្ឌដែលកើតឡើងដែនដីសមត្ថកិច្ចរបស់ខ្លួននោះទេ ច្រើនតែការស៊ើបសួរដែលធ្វើឡើងតាម រយៈកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុបញ្ជូនមកព្រះរាជអាជ្ញា ហើយបញ្ជូនមកដល់ដៃចៅក្រមស៊ើបសួរ។ ហើយជាពិសេសទៅទៀតនោះ ដោយសារតែការខ្វះខាតនូវចៅក្រមនៅក្នុងសាលាដំបូងខេត្តកំពត ចៅក្រមស៊ើបសួរមានការងារមមាញឹកធ្វើរឿងក្តីច្រើនគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើការសាកសួរ ចៅក្រមភាគច្រើនប្រគល់សិទ្ធិអំណាចឱ្យក្រឡាបញ្ជី ឬក៏មន្ត្រីលេខាធិការដ្ឋាន ឬជំនួយការណាមួយក្នុងការសាកសួរទៅលើជនល្មើស ជនត្រូវចោទ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណីជំនួសខ្លួន នេះជាការប្រគល់សិទ្ធិមួយដែលធ្វើឡើងដោយចៅក្រមស៊ើបសួរយើងគួរតែមានការកែប្រែ។

ការប្ដឹងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ទៅសភាស៊ើបសួរ គឺមានភាពយឺតយ៉ាវក្នុងការសម្រេចនឹងបញ្ជូនទៅសភាស៊ើបសួរ។

**១.២.២.ការឃុំខ្លួនបណ្ដោះអាសន្ន**

ការឃុំខ្លួនបណ្ដោះអាសន្នខុសនីតិវិធី ពេលខ្លះចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយគ្មានដីកាឃុំខ្លួនបណ្ដោះអាសន្នហួសពេលកំណត់ វាជាការសម្រេចមួយដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ។

ករណីខ្លះចៅក្រមស៊ើបសួរ តែងតែធ្វើតាមដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់តំណាងអយ្យការ ដែលភ្ជាប់ជាមួយនឹងដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

ការសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ដោយមិនពិនិត្យមើលស្ថានភាពរបស់ជនត្រូវចោទ ដែលមានជីវភាពខ្វះខាតហើយគ្រួសារពឹងផ្អែកលើជនត្រូវចោទក្នុងការរកស៊ីចិញ្ចឹមគ្រួសារ។

## ផ្នែកទី២ ដំណោះស្រាយ

### ២.១.ដំណោះស្រាយផ្នែកស៊ើបអង្កេត

**២.១.១.យន្តការបណ្ដុះបណ្ដាលជំនាញ និងច្បាប់**

គោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានមនុស្ស និងការបង្កើនសមត្ថភាព វិជ្ជាជីវៈនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមរយៈនៃការបណ្ដុះបណ្ដាលប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ក្រសួងមហាផ្ទៃ បានដាក់ចេញនូវយន្តការកំណែទម្រង់កងកម្លាំងនគរបាលជាតិឱ្យក្លាយជាកងកម្លាំងមួយដែលមានវិជ្ជាជីវៈពិតប្រាកដបំពាក់ដោយបច្ចេកទេសទំនើប មានអត្តចរិកសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវខ្ពស់ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស រក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ ដើម្បីអនុវត្តយន្តការនេះក្រសួងមហាផ្ទៃ បានប្រគល់ភារកិច្ចទៅឱ្យបណ្ឌិត្យសភានគរបាលកម្ពុជាធ្វើជាសេនាធិការក្នុងការបណ្ដុះបណ្ដាលកងកម្លាំងនគរបាលជាតិនៅទូទាំងប្រទេស។ ដើម្បីឱ្យបណ្ឌិត្យសភានគរបាលកម្ពុជា អនុវត្តបានតាមផែនការបណ្ដុះបណ្ដាលកងកម្លាំងនគរបាលជាតិទទួលបានជោគជ័យ ត្រូវមានការគាំទ្រពីរាជរដ្ឋាភិបាលពីក្រសួងមហាផ្ទៃ និងមានការចូលរួមសហការគ្រប់អង្គភាព គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិមានការគាំទ្រ និងមានយន្តការតាមដានចំពោះនិស្សិតសិក្ខាកាម ដែលបណ្ឌិត្យសភានគរ បាលកម្ពុជាបានដាក់វិន័យ ឬបណ្ដេញចេញពីការសិក្សា។

### ២.១.២.បែងចែកសមត្ថកិច្ចរវាងមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថ

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៨១ បានចង្អុលបង្ហាញពីការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថនៅក្នុងវិស័យនគរបាលយុត្តិធម៌។ ទោះបីជាក្រមនេះ បានចង្អុលបង្ហាញទៅលើអនុក្រឹត្យ ស្តីពីការបែងចែកភារកិច្ចរវាងមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថក៏ដោយ ប៉ុន្តែរហូតមកដល់ពេលនេះ នៅពុំទាន់ឃើញមានអនុក្រឹត្យក្នុងការបំពេញមុខងារជានគរបាលយុត្តិធម៌នៅឡើយ។

នៅពេលមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថចុះទៅដល់កន្លែងកើតហេតុដំណាលគ្នា ព្រះរាជអាជ្ញាត្រូវតែបែងចែកសមត្ថកិច្ចឱ្យបានច្បាស់លាស់ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលជាតិ ឬជាសមត្ថកិច្ចរបស់មន្ត្រីកងរាជអាវុធហត្ថ ដើម្បីការពារផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិ អាយុជីវិត មិនចាំបាច់ឱ្យគាត់បំពេញភារកិច្ចជាន់គ្នានាំឱ្យខាតបង់ពេលវេលា បាត់បង់ថវិកាជាតិ។

### ២.១.៣.យន្តការពង្រឹងការអនុវត្តច្បាប់

#### ២.១.៣.១.ការលុបបំបាត់អំពើពុករលួយ

ជាគោលការណ៍នគរបាលយុត្តិធម៌ មិនត្រូវយកតួនាទីខ្លួន ទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តអំពើអបាយមុខ អំពើពាលាអាវាសែ ដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួនទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តបទល្មើស ជនប្រព្រឹត្តសកម្មភាពចាប់ជំរិត លួចឆក់ ប្លន់កេងសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមកំហែងប្រជាពលរដ្ឋ ដើម្បីសំណូកការពារជនល្មើស និងប្រើប្រាស់សម្ភាររបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បំបាំងសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាងដើម្បីប្រយោជន៍បុគ្គល ។

#### ២.១.៣.២.ការលុបបំបាត់វប្បធម៌អន្តរាគមន៍

បរិបទនៃសង្គមខ្មែរបច្ចុប្បន្ន តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ វាគឺជាទម្លាប់ពលរដ្ឋខ្មែរក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គម ប៉ុន្តែបញ្ហាទាំងនេះបានក្លាយជាទម្លាប់មិនអាចប្រែបានសូម្បីតែអ្នករត់ម៉ូតូឌុបម្នាក់ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ពេលដែលខ្លួនត្រូវការជាយថាហេតុ មិនថាមានរឿងរ៉ាវតូច ឬធំនោះទេ តែងតែចូលខ្លួនមកដោះស្រាយបញ្ចប់បញ្ហា ដោយមិនទុកឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធីនិងច្បាប់ឡើយ។ អ្នកដែលមានអំណាចមានឋានៈនៅក្នុងសង្គមមួយចំនួនតែងតែលូកលាន់នៅក្នុងការអនុវត្តច្បាប់ និងមិនមានយុត្តិធម៌ក្នុងអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់

មិនបានប្រតិបត្តិតាមច្បាប់ត្រូវតែទទួលវិន័យ និងទណ្ឌកម្មជាដាច់ខាតមិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលធ្វើឱ្យមានកំហុសឆ្គងក្នុងការបំពេញតួនាទីនោះទេ។

**២.១.៣.៣.ការលុបបំបាត់វប្បធម៌និទណ្ឌភាព**

កាលណាគ្មានយុត្តិធម៌ វានឹងមាននូវនិទណ្ឌភាពបើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នាចំពោះមុខច្បាប់ឡើយ។ និទណ្ឌភាព គឺគ្មានការចាប់ខ្លួន និងនាំខ្លួនជនប្រព្រឹត្តបទល្មើសមកធ្វើការវិនិច្ឆ័យទោស ពីព្រោះតែមុខតំណែងឥទ្ធិពល ឬទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវបញ្ហាទាំងនេះ នគរបាលជាតិត្រូវមានភក្ដីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ។ នគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗនូវខណៈពេលដែលខ្លួនបានដឹងពីការប្រព្រឹត្តបទល្មើស មិនត្រូវរង់ចាំឱ្យនរណាម្នាក់ធ្វើពាក្យបណ្ដឹងជាមុននោះទេ មុនពេលដែលខ្លួន ចាប់ផ្ដើមស៊ើបអង្កេត។

ជាគោលការណ៍បើមានបទល្មើសព្រហ្មទណ្ឌ បទឧក្រិដ្ឋ ឬបទមជ្ឈិមកើតឡើង ទោះបីជាគ្មានបណ្ដឹងក៏ដោយ ក៏មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើកការស៊ើបអង្កេត ស្រាវជ្រាវ ស្វែងរកជនប្រព្រឹត្តបទល្មើស ដើម្បកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ បើមិនដូច្នោះទេ បញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់តែមានច្រើនឡើងៗ ធ្វើឱ្យសង្គមច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ គ្មានសុវត្ថិភាព ក្លាយទៅជាសង្គមមួយអនាធិបតេយ្យ។

**២.២.ដំណោះស្រាយផ្នែកស៊ើបសួរ**

**២.២.១.បង្កើតឱ្យមានវគ្គបណ្ដុះបណ្ដាលបច្ចេកទេស**

ចៅក្រមស៊ើបសួរ ត្រូវតែមានវគ្គមានបណ្ដុះបណ្ដាល ជាពិសេសទៅលើបច្ចេកទេសស៊ើបសួរ និងបង្កើតឱ្យមានមន្ទីរពិសោធន៍មួយនៅមន្ទីរស៊ើបសួរ និងមានមន្ត្រីជំនាញប្រចាំការ ដើម្បីជាជំនួយបច្ចេកទេសធ្វើកោសលវិច័យទៅ លើវត្ថុតាំងដែលពាក់ព័ន្ធនឹងបទល្មើស ។

ចៅក្រមស៊ើបសួរគួរសិក្សា នៅយន្តការនានាដែលច្បាប់បានអនុញ្ញាតចៀសវាងធ្វើការឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទដោយខុសនីតិវិធីច្បាប់ និងធ្វើតាមដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់តំណាងអយ្យការ ដែលធ្វើឱ្យមានការកើនឡើងនៃការឃុំខ្លួនជនត្រូវចោទ និងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ។

**២.២.២.ការពង្រឹងការអនុវត្តច្បាប់**

ចៅក្រមស៊ើបសួរត្រូវគោរពតួនាទីរបស់ខ្លួនក្នុងការស៊ើបសួរ ត្រូវធ្វើការស្រាវជ្រាវស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ក្នុងការធានាស្វែងរកការពិតណាមួយ ដើម្បីផ្ដល់យុត្តិធម៌ជូនជនសង្ស័យ ឬជនរងគ្រោះ ឬជនដែលមានការពាក់ព័ន្ធក្នុងរឿងព្រហ្មទណ្ឌដែល បានកើតឡើងចៀសវាងធ្វើតាមតែឯកសារមួយចំនួនកសាងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលនាំឱ្យផ្ទុយនឹងគោលការណ៍ស្វែងរកភស្តុតាងដាក់បន្ទុក និង ដោះបន្ទុករបស់ចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរត្រូវគោរពតួនាទីរបស់ខ្លួន ដឹកនាំនីតិវិធីស៊ើបសួរដោយខ្លួនឯងមិនត្រូវប្រើប្រាស់ក្រឡាបញ្ជីឱ្យធ្វើកិច្ចការជំនួសខ្លួន ព្រោះក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។

លុបបំបាត់អំពើពុករលួយ ជាគោលការណ៍ចៅក្រមស៊ើបសួរ ត្រូវតែមានមនសិការក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌដោយមិនកុបាកភូតភរ ឬលាក់បាំងនូវតម្រុយភស្តុតាងដែលធ្វើឱ្យការពិតទៅជារឿងមិនពិត ក្រោមការកែប្រែ ឬមិនបង្ហាញនូវអ្វីដែលមានប្រយោជន៍របស់ភាគីណាម្ខាងដោយទទួលនូវអំពើពុករលួយដោយភាគីណាមួយ ឬតតិយជន ឬដើម្បីទម្លាក់កំហុស ឬជួយឱ្យរួចផុតពីការទទួលខុសត្រូវ។ ចៅក្រមស៊ើបសួរត្រូវតែឯករាជ្យ គឺត្រូវតែបង្ហាញនូវអ្វីដែលរកឃើញក្រោយពីការស្រាវជ្រាវ បទល្មើសរបស់ចៅក្រមស៊ើបសួរ ដោយមិនទទួលរងក្រោមសម្ពាធពីភាគីណាមួយរួមមាន ជនត្រូវចោទ តំណាងអយ្យការ ជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី លើសពីនេះទៅទៀតការសម្រេច និងការស្រាវជ្រាវរបស់ចៅក្រម ស៊ើបសួរត្រូវធ្វើឡើង ដោយស្របនិងសម្បជញ្ញៈជាអ្នកស្រាវជ្រាវបទល្មើសប្រកប ដោយតម្លាភាព ភាពទៀងត្រង់ និងស្រឡាញ់យុត្តិធម៌នៅក្នុងសង្គម។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា នីតិវិធីនៃការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ ហាក់បីដូចជាជាន់សមត្ថកិច្ច និងនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ តើមូលហេតុអ្វីបានជាក្រមនីតិវិធីព្រហ្មទណ្ឌបង្កើតឱ្យមានការស៊ើបអង្កេត ហើយតម្រូវឱ្យមានការស៊ើបសួរទៀត ជាធម្មតានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការសាកសួរនៅដំណាក់កាលអយ្យការ ពុំទាន់អាចប្រមូលបានអង្គហេតុនឹងភស្តុតាង គ្រប់ជ្រុងជ្រោយដែលអាចបញ្ជូនជនសង្ស័យទៅជំនុំជម្រះបានឡើយ។ ហេតុដូចនេះហើយ ទើបតម្រូវឱ្យមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីស្វែងរកធាតុចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់ ស្វែងរកភស្តុតាង និងពិរុទ្ធភាព សម្រាប់អង្គហេតុចោទប្រកាន់ និងធានានូវនិរន្តរភាពសម្រាប់ដំណើរការកាត់សេចក្តី។ ប៉ុន្តែការបើកការស៊ើបសួរនេះមិនមែនអនុវត្តទៅលើគ្រប់សំណុំរឿងព្រហ្មទណ្ឌទាំងអស់នោះទេ គឺវាអាស្រ័យទៅលើភាពស្មុគស្មាញ ឬភាពចាំបាច់នៃរឿងក្តី។ បទឧក្រិដ្ឋគឺច្បាប់បានកំណត់យ៉ាងច្បាស់ថាដាច់ខាតត្រូវតែបើកការស៊ើបសួរ ប៉ុន្តែក្នុង បទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរក៏បាន ឬមិនបើកក៏បានអាស្រ័យទៅលើភាពស្មុគស្មាញនៃបទល្មើស។

ទំនាក់ទំនងការងាររវាងមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ មានភាពប្រទាក់គ្នាជាប់ឥតដាច់ក្នុងស៊ើបអង្កេត និងការស៊ើបសួរ ស្វែងរកការពិតនៃរឿង។

មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីសំខាន់ណាស់នៅក្នុងសង្គម ដោយហេតុថា ពួកគាត់គឺជាបុគ្គលដែលពេលខ្លះ ត្រូវបំពេញការងារស្ថិតនៅក្នុងភាពប្រថុយប្រថាន និងគ្រោះថ្នាក់ដល់អាយុជីវិតដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខស្ថេរភាព និងយុត្តិធម៌សង្គមជូនពលរដ្ឋ និងប្រទេសជាតិ។ មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ។ នៅដំណាក់កាលស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ ជាសេនាធិការ និងស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញាមានសមត្ថកិច្ច។ តួនាទីចម្បងរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត យើងអាចចែកចេញជាពីរ ការពិនិត្យស្វែងរកបទល្មើស និងការស៊ើបអង្កេតស្វែងរកភស្តុតាង។ នៅដំណាក់កាលស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ជាជំនួយការរបស់ចៅក្រមស៊ើបសួរ នាពេលដែលចៅក្រមស៊ើបសួរបានផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌តាមរយៈដីកាចាត់ឱ្យស៊ើបជំនួស ក្នុងការបំពេញតួនាទីដូចជាការកោះហៅ និងការស្តាប់ចម្លើយសាក្សី ការឆែកឆេរ និងការចាប់យកវត្ថុតាង ការឃាត់ខ្លួនជាអាទិ៍។ តួនាទីរបស់មន្ត្រីនគរបាល

ត្រូវបំពេញ គឺត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ក្នុងដីកាចាត់ឱ្យស៊ើបជម្រះដោយចៅក្រមស៊ើបសួរ។ ប៉ុន្តែចៅក្រមស៊ើបសួរ មិនអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌សួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ ព្រោះមន្ត្រីនគរបាលយុត្តិធម៌នឹងរក្សាចម្លើយរបស់ខ្លួនដែលបានកសាងកន្លងមក ហើយវានឹងនាំឱ្យផ្ទុយនិងគោលការណ៍ស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុករបស់ចៅក្រមស៊ើបសួរ។

ព្រះរាជអាជ្ញា ជាអ្នកដឹកនាំនឹងសម្របសម្រួលដល់នគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាមានតួនាទីចំនួន០៤ (បួន) គឺការចោទប្រកាន់ ការធ្វើសេចក្តីសម្រេចសន្និដ្ឋានឱ្យតុលាការ ការធានារ៉ាប់រងការអនុវត្តច្បាប់ និងការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ តួនាទីរបស់ព្រះរាជអាជ្ញានៅដំណាក់កាលស៊ើបអង្កេត គឺចង្អុលបង្ហាញឱ្យនរគបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតស្រាវជ្រាវ ការអនុញ្ញាតឱ្យធ្វើការឆែកឆេរ ការអនុញ្ញាតឱ្យធ្វើការឃាត់ខ្លួន ការដឹកនាំឆែកឆេរ និងការផ្តល់យោបល់នានា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌សុំយោបល់ពីព្រះរាជអាជ្ញា។ បន្ទាប់ពីស្រាវជ្រាវ ប្រមូលបានតម្រុយបទល្មើសជាបឋមរួចមក ព្រះរាជអាជ្ញា ត្រូវធ្វើចំណាត់ការលើសំណុំរឿងឱ្យបានក្នុងរយៈ ពេល០២ (ពីរ) ថ្ងៃគិតចាប់ពីថ្ងៃចុះបញ្ជីបណ្តឹង ក្នុងការសម្រេចតម្កល់រឿងឥតចាត់ការ ឬសម្រេចចោទប្រកាន់។ ប្រសិន បើព្រះរាជអាជ្ញា បានធ្វើការចោទប្រកាន់តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ព្រះរាជអាជ្ញា មានតួនាទី ក្នុងការឃ្លាំមើលការអនុវត្តរបស់ចៅក្រមស៊ើបសួរ តើការសម្រេចដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬការសម្រេចឃុំបណ្តោះអាសន្នជារឿងសមហេតុផល និងចាំបាច់ដែរ ឬទេ? តើត្រូវស្នើសុំឱ្យស៊ើបសួរបន្ថែមដែរឬទេ? តើការសម្រេចតាមរយៈដីកាដំណោះស្រាយត្រឹមត្រូវ ឬទេ? កាលណា ចៅក្រមស៊ើបសួរមិនធ្វើតាមការស្នើសុំ ឬទុកការស្នើសុំចោលក្នុងចិរវេលាកំណត់ក្នុងច្បាប់ ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរ មានតួនាទីស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ក្នុងការធានាស្វែងរកការពិតលាតត្រដាង ដើម្បីទុកជូនចៅក្រមជំនុំជម្រះធ្វើការពិចារណា និងសម្រេច។ ដើម្បីស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុកប្រកបដោយប្រសិទ្ធិភាព ក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់ភារកិច្ចមួយចំនួនដល់ចៅក្រមស៊ើបសួរដូចជា៖ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ការឆែកឆេរ ការចាប់យកវត្ថុតាង ការប្រគល់វត្ថុចាប់យក ការស្នើសុំធ្វើកោសល្យវិច័យ ការស្តាប់ទូរស័ព្ទ ការចាត់ឱ្យស៊ើបសួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌ ការប្រើប្រាស់អំណាចបង្ខំតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។ នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាអ្នកទទួលខុសត្រូវរាល់ការ

សម្រេចរបស់ខ្លួនដោយឯករាជ្យ ដើម្បីឱ្យដល់គោលដៅនៃការបង្ហាញការពិតសម្រាប់យុត្តិធម៌សង្គម។ ភារកិច្ចរបស់ចៅក្រមស៊ើបសួរ និងត្រូវបញ្ចប់ទៅវិញចាប់ពីពេលដែលចៅក្រមស៊ើបសួរសម្រេចចេញដីកាដំណោះស្រាយ ( **ដីកាបញ្ជូនទៅជម្រះ ដីកាលើកលែងការចោទប្រកាន់** ) ដោយបញ្ជូលសំណុំរឿងនោះទៅតុលាការជំនុំជម្រះ។

យ៉ាងណាមិញ ការស៊ើបអង្កេត និងការស៊ើបសួរ គឺមានគោលបំណងធ្វើឱ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនទូទៅ។ ហេតុដូច្នេះ ទាមទារឱ្យមន្ត្រីដែលមានសមត្ថកិច្ចទាំងអស់ ត្រូវបំពេញមុខងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ និងគោរពទៅតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវក្នុងប្រធានបទនេះរួចមក ក្រុមយើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួន ដើម្បីពង្រឹងប្រសិទ្ធភាពព្រមទាំងកែតម្រូវចំណុចខ្វះខាតដូចខាងក្រោម ៖

- សំណូមពរឱ្យប្រជាពលរដ្ឋគ្រប់រូប សហការជាមួយមន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលមានបទល្មើសកើតឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ហើយប្រជាពលរដ្ឋត្រូវយល់ដឹងអំពីច្បាប់ជាពិសេសយល់ដឹងអំពីបទល្មើស ដើម្បីកុំឱ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗ។
- ស្នើសុំឱ្យក្រសួងយុត្តិធម៌ ធ្វើអធិការកិច្ចទៅលើមន្ត្រីតុលាការជាពិសេសចៅក្រមស៊ើបសួរក្នុងការស៊ើបសួរ ថាតើការស៊ើបសួររបស់ចៅក្រមធ្វើឡើងតាមនីតិវិធីច្បាប់ដែរឬទេ? ស្នើសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើអធិការកិច្ចទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែលបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់លំដាប់ថ្នាក់។
- សូមឱ្យក្រសួងស្ថាប័ន ជាពិសេសក្រសួងមហាផ្ទៃ ឬកងរាជអាវុធហត្ថផ្ទៃប្រទេស ដាក់កម្មទៅលើមន្ត្រីនគរបាលយុត្តិធម៌ណា ដែលមានការប្រព្រឹត្តខុសនីតិវិធីច្បាប់ ឬក៏អនុវត្តច្បាប់ខុសមុខការរបស់ខ្លួនក្នុងការបំពេញបង្ក្រាបនៅបទល្មើសព្រហ្មទណ្ឌក្នុងដែនដីរបស់ខ្លួន។
- រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលជំនាញ និងវិធីសាស្ត្រល្អៗ ក្នុងការស៊ើបអង្កេតដល់មន្ត្រីដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតទទួលបាននូវប្រសិទ្ធិភាពច្បាស់លាស់។
- ស្នើសុំឱ្យរាជរដ្ឋាភិបាលក៏ដូចជា ក្រសួងយុត្តិធម៌ផ្តល់នៅសម្ភារបច្ចេកទេសដល់មន្ត្រីតុលាការគ្រប់លំដាប់ថ្នាក់។ សូមឱ្យក្រសួងស្ថាប័នមានសមត្ថកិច្ច ជាពិសេសក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិផ្តល់នៅសម្ភារ ដូចជាម៉ូតូ ឡាន កុំព្យូទ័រ ឬក៏ម៉ាស៊ីនស្កេនម្រាមដៃ និងឧបករណ៍ផ្សេងៗដែលជំនួយមន្ត្រីនគរបាលយុត្តិធម៌ការបង្ក្រាបបទល្មើស ឬឱ្យមានភាពងាយស្រួលក្នុងការបង្ក្រាប។
- សូមឱ្យមន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយ គោរពឱ្យបានហ្មត់ចត់នូវក្រមសីលធម៌ ព្រមទាំងគោលការណ៍ទាំងឡាយណាដែលបានចែងក្នុងច្បាប់ឱ្យបានម៉ឺងម៉ាត់។ មិនត្រូវប្រើអំណាចគំរាម-កំហែងប្រជាពលរដ្ឋ ដើម្បីសំណូកការពារជនល្មើស និងប្រើប្រាស់សម្ភាររបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បំបាំងសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាងដើម្បីប្រយោជន៍បុគ្គល ។
- បង្កើតឱ្យមានវគ្គមានវគ្គបណ្តុះបណ្តាល ជាពិសេសទៅលើបច្ចេកទេសស៊ើបសួរ និងត្រូវបង្កើតឱ្យមានមន្ទីរពិសោធន៍មួយនៅមន្ទីរស៊ើបសួរ និងមានមន្ត្រីជំនាញប្រចាំការ ដើម្បីជាជំនួយបច្ចេកទេស ធ្វើកោសល្យវិច័យទៅ លើវត្ថុតាំងដែលពាក់ព័ន្ធនឹងបទល្មើស ។

- ត្រូវមានការផ្លាស់ប្តូរចៅក្រម ឱ្យបានទៀងទាត់ពីតុលាការមួយទៅតុលាការមួយទៀត និងដោយមានការយល់ព្រមជាមុនពីសាមីខ្លួននៅពេលតែងតាំង ដើម្បីកាត់បន្ថយឱកាសប្រព្រឹត្តអំពើពុករលួយ ព្រោះប្រជាជនក្នុងមូលដ្ឋានអាចស្គាល់ចៅក្រមច្បាស់ ហើយងាយស្រួលក្នុងការសូកប៉ាន់។
- ចៅក្រមស៊ើបសួរ ត្រូវតែមានមនសិការក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌដោយមិនកុហកភូតភរ ឬលាក់បាំងនូវតម្រុយភស្តុតាងដែលធ្វើឱ្យការពិតទៅជារឿងមិនពិត ក្រោមការកែប្រែ ឬ មិនបង្ហាញនូវអ្វីដែលមានប្រយោជន៍របស់ភាគីណាម្ខាង ដោយទទួលនូវអំពើពុករលួយដោយភាគីណាមួយ ឬតតិយជន ឬដើម្បីទម្លាក់កំហុស ឬជួយឱ្យរួចផុតពីការទទួលខុសត្រូវ។ ចៅក្រមស៊ើបសួរត្រូវតែឯករាជ្យ គឺត្រូវតែបង្ហាញនូវអ្វីដែលរកឃើញក្រោយពីការស្រាវជ្រាវ បទល្មើសរបស់ចៅក្រមស៊ើបសួរ ដោយមិនទទួលរងក្រោមសម្ពាធពីភាគីណាមួយរួមមានជនត្រូវចោទ តំណាងអយ្យការជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ លើសពីនេះទៅទៀត ការសម្រេច និងការស្រាវជ្រាវរបស់ចៅក្រម ស៊ើបសួរ ត្រូវធ្វើឡើង ដោយស្របនិងសម្បជញ្ញៈ ជាអ្នកស្រាវជ្រាវបទល្មើសប្រកបដោយតម្លាភាព ភាពទៀងត្រង់ និងស្រឡាញ់យុត្តិធម៌នៅក្នុងសង្គម។
- ការសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ចៀសវាងការឃុំខ្លួនបណ្តោះអាសន្ន ដែលមិនមែនជាការចាំបាច់ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ។

# ឯកសារពិគ្រោះ

## ១-លិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩១៤
- អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០៧។


## ២-សៀវភៅ និងស្នាដៃនិពន្ធ


- វចនានុក្រម សម្តេចព្រះសង្ឃរាជជោតញ្ញាណោ **ជួន ណាត** ភាគទី០១ ដល់ភាគទី០២
- សៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ របស់សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៥-២០១៦
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ សម្រាប់នគរបាលយុត្តិធម៌
- សៀវភៅ ក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ
- សៀវភៅ មគ្គុទេសក៍ស្តីពីនីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ របស់លោកស្រី **ឌី លីឡា** និងលោក **ខាន់ សុខា**
- និងសារណារបស់និស្សិតរៀមច្បងជំនាន់មុន នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

# ឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | កំណត់ហេតុឆែកឆេរលំនៅដ្ឋាន និងចាប់យកវត្ថុតាំង |
| ០២ | កំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង |
| ០៣ | កំណត់ហេតុបិទផ្ទះបណ្តោះអាសន្ន |
| ០៤ | កំណត់ហេតុឃាត់ខ្លួនជាក់ស្តែង |
| ០៥ | កំណត់ឃាត់ខ្លួនពីបទល្មើសជាក់ស្តែង |
| ០៦ | កំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន |
| ០៧ | កំណត់ហេតុលើការស្តាប់ចម្លើយ (ជនសង្ស័យ) នៅមន្ត្រីនគរបាលយុត្តិធម៌ |
| ០៨ | ដីកាអម |
| ០៩ | របាយការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តកំពត |
| ១០ | ពាក្យសុំពឹងពាក់ និងប្រគល់សិទ្ធិដល់មេធាវី |
| ១១ | លិខិតជូនដំណឹង ស្តីពី ការការពារក្តី |
| ១២ | កំណត់ហេតុសួរចម្លើយ (អ្នកបកប្រែ ឱ្យជនសង្ស័យ) នៅអយ្យការ |
| ១៣ | កំណត់ហេតុសួរចម្លើយ (ជនសង្ស័យ) នៅអយ្យការ |
| ១៤ | កំណត់ហេតុស្តីពីការធ្វើសម្បថ របស់ (អ្នកបកប្រែ) |
| ១៥ | កំណត់ហេតុទទួល និងប្រគល់វត្ថុតាង |
| ១៦ | កំណត់ទទួលវត្ថុតាង |
| ១៧ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| ១៨ | ដីកាចាត់តាំងចៅក្រមស៊ើបសួរ |
| ១៩ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង |
| ២០ | កំណត់ស្តីពីការពិភាក្សដេញដោលចំពោះមុខ |
| ២១ | ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន |
| ២២ | ដីកាសម្រេចរក្សាទុកជនត្រូវចោទនៅក្នុងឃុំរង់ចាំការជំនុំជម្រះ |
| ២៣ | ដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទក្នុងឃុំរង់ចាំការជំនុំជម្រះ |
| ២៤ | ពាក្យសុំកូនក្តីនៅក្រៅឃុំបណ្តោះអាសន្ន |

| | |
|---|---|
| ២៥ | ដីកាបញ្ជូនឱ្យឆ្លើយ |
| ២៦ | ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន |
| ២៧ | ពាក្យសុំដឹកកូនក្ដីទៅមន្ទីរពេទ្យ |
| ២៨ | ដីការបញ្ជូនឱ្យឆ្លើយ |
| ២៩ | ដីកាសម្រេច |
| ៣០ | លិខិតជូនព័ត៌មានស្ដីពីការបិទការស៊ើបសួរ |
| ៣១ | ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ |
| ៣២ | ដីកាសន្និដ្ឋានស្ថាពរ |
| ៣៣ | បញ្ជីរាយនាមជនដែលទាក់ទិន |
| ៣៤ | ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ៣៥ | បញ្ជីរាយនាមជនទាក់ទិន |
| ៣៦ | ពាក្យសុំលើកលែងចោទប្រកាន់ |